ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

C.D.R.I
វ.ប.ស.អ

ឆ្នាំទី១២ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០០៨ | តម្លៃ ១.៥០០៛

# ចំណាកស្រុករបស់យុវជន នៅក្នុងប្រទេសកម្ពុជា

ដោយលោក លឹម សុវណ្ណារ៉ា*

## ១. សេចក្តីផ្តើម

ចាប់តាំងពីចុងទសវត្សរ៍១៩៩០ ដោយសារប្រទេសកម្ពុជាបានបើកចំហសេដ្ឋកិច្ចទីផ្សារសេរី និងដោយមានកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ យុវជនវ័យក្មេងនៅជនបទកម្ពុជា បានធ្វើចំណាកស្រុកកាន់តែច្រើនមកកាន់ទីក្រុង ដើម្បីរកការងារធ្វើ ។ ការផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត រមែងមានហានិភ័យជាពិសេស ចំពោះកម្មករវ័យក្មេងដែលភាគច្រើនមានការអប់រំមូលដ្ឋានទាប និងគ្មាន រឺមានជំនាញតិចតួច ហើយពុំធ្លាប់ចាកចេញពីភូមិកំណើតសោះ ។ ដំណើរការចំណាកស្រុក បណ្តាញផ្សេងៗ លក្ខខណ្ឌរស់នៅនិងធ្វើការងារ ព្រមទាំងផលប៉ះពាល់នៃការផ្ញើប្រាក់ទៅផ្ទះ និងចំណាកស្រុក ទៅលើក្រុមគ្រួសារ និងសហគមន៍ គេនៅមិនទាន់បានស្វែងយល់អោយស៊ីជម្រៅនៅឡើយទេ ។ ឯកសារនេះ សិក្សាអំពីចំណាកស្រុករបស់យុវជននៅតាមជនបទទៅកាន់ទីក្រុង ព្រមទាំងផលប៉ះពាល់នៃការធ្វើចំណាកស្រុកទៅលើការកាត់បន្ថយភាពក្រីក្រ ក្នុងសហគមន៍របស់ពួកគេ ដោយពិនិត្យមើលលើៈ (ក) សាវតារសេដ្ឋកិច្ច-សង្គមកិច្ចនៃគ្រួសាររបស់យុវជនចំណាកស្រុក (ខ) កត្តាជំរុញអោយមានចំណាកស្រុក (គ) តួនាទីនៃទំនាក់ទំនងសង្គមក្នុងការសម្រួលដល់ការធ្វើចំណាកស្រុក (ឃ) សមាហរណកម្មនៃយុវជនចំណាកស្រុកទៅក្នុងការរស់នៅក្នុងទីក្រុង (ង) ប្រាក់ផ្ញើទៅផ្ទះ និងផលប៉ះពាល់ទៅលើការកាត់បន្ថយភាពក្រីក្រក្នុងគ្រួសារ និងសហគមន៍របស់យុវជនចំណាកស្រុក ។




*កម្មករ ផ្តុំគ្នារៀនភាសាអង់គ្លេស នៅពេលសំរាកពីការងារសំណង់ នៅឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ*

ការសិក្សាមុនៗបានបង្ហាញឡើងថា ចំណាកស្រុកនៅក្នុងប្រទេស មានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានដល់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ។ ទោះបីជាផលប៉ះពាល់សុទ្ធនៃការធ្វើចំណាកស្រុក នៅតែស្ថិតក្នុងការពិភាក្សាវែកញែកក្តី ក៏ការធ្វើចំណាកស្រុកនេះអាចជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតដ៏សំខាន់មួយសំរាប់ប្រជាជនក្រីក្រជាច្រើន ហើយវាក៏រួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចជាតិដែរ (DFID 2004) ។ ការអះអាងនេះ បានទទួលការគាំទ្រពីលោក Laczko (2005) ដែលបានចង្អុលបង្ហាញថា ចំណាកស្រុកក្នុងប្រទេស មានសក្តានុពលជួយជំរុញការអភិវឌ្ឍបានច្រើនបែបយ៉ាង ។ តាមរយៈប្រាក់ចំណូលបន្ថែមបានពី

## មាតិកា

ចំណាកស្រុករបស់យុវជន នៅក្នុងប្រទេសកម្ពុជា ..........១
សុខុមាលភាពសហគមន៍ និងចលនាគ្រួសារនៅកម្ពុជាក្រោយពេលបញ្ចប់ជំម្លោះ.......៦
សន្តិសុខសង្គម និងគោលនយោបាយសង្គមនៅកម្ពុជា..........១១
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស .......... ១៧
– ស្ថានភាពក្នុងប្រទេស ..........១៩
– សន្ទស្សន៍សេដ្ឋកិច្ច .......... ២១
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI .......... ២៤

* លោក លឹម សុវណ្ណារ៉ា ជាអតីតអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។ អត្ថបទនេះជាសង្ខេបនៃការរកឃើញគន្លឹះ ពីការស្រាវជ្រាវពីចំណាកស្រុករបស់យុវជន និងនគរូបនីយកម្មនៅកម្ពុជា ដែលធ្វើឡើងដោយ CDRI ក្រោមការឧបត្ថម្ភពីមូលនិធិប្រជាពលរដ្ឋសហរដ្ឋអាមេរិក នៅកម្ពុជា ។

ការងារមិនមែនកសិកម្មនៅតាមតំបន់ទីក្រុង គ្រួសារនៅជនបទបានបង្កើនប្រភពចំណូល និងប្រមូលបង្គរមូលធនរបស់ខ្លួន ។ ក្នុងរយៈពេលខ្លី ចំណាកស្រុកអាចធ្វើអោយបាត់បង់ហិរញ្ញវត្ថុ និងមូលធនមនុស្សក្នុងតំបន់ ប៉ុន្តែក៏អាចរួមចំណែកផងដែរដល់ការអភិវឌ្ឍរយៈពេលវែងនៃតំបន់ជនបទ ។ លើសពីនេះ ប្រាក់ផ្ញើរបស់ជនចំណាកស្រុកក្នុងប្រទេស អាចមានសារៈសំខាន់សំរាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ។ ប្រាក់ផ្ញើបានមកពីការងារនៅទីក្រុង វាបំពេញបន្ថែមលើប្រាក់ចំណូលនៅជនបទ ហើយជួយបង្កើនចំនាយប្រើប្រាស់នៅជនបទ ជួយបង្កើនប្រាក់សន្សំរបស់គ្រួសារ ព្រមទាំងអាចជំរុញសេដ្ឋកិច្ចក្នុងតំបន់ ។ ក្នុងរយៈពេលវែង សហគមន៍របស់យុវជនចំណាកស្រុក គឺទទួលផលចំណេញជាសំខាន់តាមរយៈប្រាក់ផ្ញើ ។ ក្នុងករណីភាគច្រើន ចំណាកស្រុកផ្តល់ផលប៉ះពាល់វិជ្ជមានច្រើនជាងផលអវិជ្ជមាន ។

## ២. សាវតារសេដ្ឋកិច្ច_សង្គមកិច្ច នៃគ្រួសាររបស់យុវជនចំណាកស្រុក

លទ្ធភាពរកប្រាក់បានច្រើនជាកត្តាទាក់ទាញសំខាន់បំផុត ហើយប្រាក់ផ្ញើហាក់ដូចជាផលប្រយោជន៍តែម្យ៉ាង ដែលគ្រួសាររបស់យុវជនចំណាកស្រុកទទួលបាន។ ការធ្វើចំណាកស្រុក គួរតែជាសកម្មភាពរបស់អ្នកក្រីក្រ និងក្រីក្របំផុត ជាជាងអ្នកមធ្យម និងអ្នកមាន ។ ផ្ទុយទៅវិញ ការសិក្សាបង្ហាញថា គ្រួសាររបស់យុវជនចំណាកស្រុកចំនួន ៥៤%ជាគ្រួសារប្រភេទមធ្យម ៤០% ជាគ្រួសារក្រីក្រ និង ៦% ក្រីក្របំផុត (គេបែងចែកគ្រួសារជា អ្នកមាន មធ្យម ក្រ និងក្របំផុត) ។ គ្រួសារអ្នកក្រ និងមធ្យម មានដល់ ៩៤% នៃគ្រួសាររបស់យុវជនចំណាកស្រុកសរុបដែលបានសំភាសន៍ ។ គ្រួសារក្រីក្របំផុតលំបាកនឹងធ្វើចំណាកស្រុក ដោយសារពួកគេមិនមានមូលធនហិរញ្ញវត្ថុ និងសង្គមគ្រប់គ្រាន់ ។ ក្នុងករណីខ្លះទៀត ក្មេងៗក្នុងគ្រួសារក្រីក្របំផុត ត្រូវនៅថែរក្សាឪពុកម្តាយចាស់ជរា រឺពិការ ហើយស្ថានភាពនេះបណ្តាលអោយមានភាពក្រីក្រ ។ ម្យ៉ាងទៀត យុវជនក្នុងគ្រួសារអ្នកមានមិនធ្វើចំណាកស្រុកទេ (នៅផ្ទះ) ។ គ្រួសារអ្នកមានភាគច្រើន អាចមានប្រភពចំណូលច្រើនពីការផ្តល់កំចីទៅឱ្យអ្នកភូមិ ការជួលទ្រព្យផលិតកម្មផ្សេងៗ (ដូចជា ត្រាក់ទ័រ គោយន្ត និងម៉ាស៊ីនកិនស្រូវ) រឺការបង្កើតមុខរបរតូចៗ នៅតាមភូមិរបស់ពួកគេ ។ សកម្មភាពទាំងនេះអាចធ្វើអោយពួកគេជៀសផុតពីហានិភ័យ និងបញ្ហាប្រឈមនានាក្នុងការធ្វើចំណាកស្រុក ។

## ៣. មូលហេតុនៃការធ្វើចំណាកស្រុក

ចំណាកស្រុកកំលាំងពលកម្មយុវជន បណ្តាលជាសំខាន់ពីកត្តារុញច្រាន និងទទួលរងឥទ្ធិពលពីកត្តាទាក់ទាញផង ។ ភាពក្រីក្ររ៉ាំរ៉ៃ ភាពគ្មានដីធ្លី ការហិនហោចធនធានធម្មជាតិ រឺធនធានទ្រព្យរួម កង្វះការងារពេញមួយឆ្នាំ បំណុល និងគ្រោះធម្មជាតិ បានបង្ខំអោយយុវជនជាច្រើននៅជនបទកម្ពុជា ធ្វើចំណាកស្រុក ។ តំរូវការខ្ពស់នូវកម្មករគ្មានជំនាញក្នុងវិស័យកាត់ដេរ និងសំណង់ ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ព្រមទាំងទស្សនៈល្អពីការងារមានប្រាក់កំរៃ និងសេចក្តីសង្ឃឹមថានឹងមានជីវភាពប្រសើរឡើង វាបង្កើតបានជាកត្តាទាក់ទាញអោយធ្វើចំណាកស្រុក ។ លើសពីនេះ យុវជនមួយចំនួនបានធ្វើចំណាកស្រុកជាមួយគ្រួសារពួកគេ ។ ក្នុងករណីខ្លះ ការទាក់ទាញខាងសំភារៈនិយមវាខ្លាំងក្លាពេកមិនអាចទប់ចិត្តបានទេ សំរាប់យុវជនចំណាកស្រុកមួយចំនួនមកពីគ្រួសារអ្នកមធ្យមដែលមានការហូបចុកគ្រប់គ្រាន់ ប៉ុន្តែចង់បានឯករាជ្យខាងហិរញ្ញវត្ថុ រឺចង់បានប្រាក់បន្ថែមសម្រាប់ការកំសាន្តសប្បាយ ។

តាមរយៈការសិក្សា យុវជនចំណាកស្រុកជិត ៥០% បានសំរេចចិត្តធ្វើចំណាកស្រុក ដោយសារនៅក្នុងភូមិរបស់ពួកគេ គ្មានការងារធ្វើឱ្យបានពេញមួយឆ្នាំ ។ កង្វះការងារពេញមួយឆ្នាំ ជាកត្តារុញច្រានដ៏សំខាន់ឆ្លើយតបនឹងចំណូលចិត្តរបស់យុវជនវ័យក្មេង ដែលមិនចង់ធ្វើការងារជាប្រពៃណី (ដូចជា ធ្វើស្រែចំការ និងរកត្រី) ហើយទៅរកការងារមានប្រាក់កំរៃពេញមួយឆ្នាំវិញ ដោយសារស្លុងចិត្តតាមដំណើររឿងជោគជ័យរបស់សាច់ញាតិ មិត្តភក្តិ រឺយុវជនផ្សេងទៀត ដែលបានធ្វើចំណាកស្រុកចេញពីភូមិ ។ យុវជនចំណាកស្រុក ១៧% ផ្សេងទៀតនិយាយថា កង្វះខាតម្ហូបអាហារជាកត្តានាំអោយពួកគេធ្វើចំណាកស្រុក ហើយ ១០% ទៀតថាមកពីគ្មានដីគ្រប់គ្រាន់ ។ "ការធ្វើចំណាកស្រុកដោយសារបញ្ហាគ្រួសារ" គឺជាកត្តាទីបួន ប៉ុន្តែចំណុចដែលគួរអោយភ្ញាក់ផ្អើល គឺមានយុវជនចំណាកស្រុកត្រឹមតែ ៤,២% ដែលឆ្លើយថាពួកគេធ្វើចំណាកស្រុកដោយសារកត្តាគ្រោះធម្មជាតិ និង ៣,២% ឆ្លើយថា ដោយសារជំពាក់បំណុលគេ ។

## ៤. ទំនាក់ទំនងសង្គម និងចំណាកស្រុក

ទ្រឹស្តីស្តីពីទំនាក់ទំនង បានកំណត់ថា ចំណាកស្រុកផុសចេញពីទំនាក់ទំនងផ្ទាល់ខ្លួន ទំនាក់ទំនងខាងវប្បធម៌និង/រឺសង្គមផ្សេងទៀត ។សំរាប់យុវជនដែលកំពុងរស់នៅក្នុងតំបន់រឺប្រទេសខ្លួន គេអាចទទួលព័ត៌មានស្តីពីការងារ និងលក្ខខណ្ឌរស់នៅក្នុងតំបន់រឺប្រទេសគោលដៅចំណាកស្រុក តាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន ដូចជាមិត្តភក្តិ និងអ្នកជិតខាងដែលបានធ្វើចំណាកស្រុក ។ សាច់ញាតិរបស់ជនចំណាកស្រុក ជាញឹកញាប់ជួយពួកគេអោយរកបានការងារ និងចេះសម្របខ្លួនទៅនឹងបរិយាកាសរស់នៅថ្មី (Oishi Nana 2002 ដកស្រង់ពី Kim 2005) ។

ការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ទោះបីទៅតាមរដូវ រឺទៅជាអចិន្ត្រៃយ៍ក្តី គឺមានហានិភ័យ និងមានបន្ទុកចំណាយខាងហិរញ្ញវត្ថុ និងសង្គម ។ ព័ត៌មានទទួលបានត្រឹមត្រូវ និងគ្រប់គ្រាន់ អាចជួយកាត់បន្ថយហានិភ័យក្នុងការចំណាកស្រុកបានច្រើន និងបង្កើនឱកាសទទួលបានជោគជ័យ ។ ការសិក្សាបង្ហាញថា យុវជនជាកម្មករចំណាកស្រុកភាគច្រើន ទទួលបានព័ត៌មានតិចតួច រឺគ្មានសោះពីការងារល្អ ការរស់នៅ និងបរិយាកាសការងារនៅទីក្រុង ។ ពួកគេពឹងផ្អែកខ្លាំងលើប្រភពព័ត៌មានក្រៅផ្លូវការ ហើយអ្វីដែលពួកគេទទួលបានមុនពេលសម្រេចចិត្តធ្វើចំណាកស្រុក គឺជាព័ត៌មានពាក់ព័ន្ធនឹងការងារដែលអាចរកបាន មិនមែនព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ រឺលក្ខខណ្ឌរស់នៅទេ ។

ជិត ៥០% នៃយុវជនចំណាកស្រុក ទទួលបានព័ត៌មានដំបូងស្តីពីកាលានុវត្តិភាពការងារ អំពីសាច់ញាតិ ហើយ ជាង ៥០%ទៀតបានដឹងពីសមាជិកគ្រួសារ អ្នកជិតខាង អ្នកភូមិ រឺមិត្តភក្តិ ។ ចំនុចគួរកត់សំគាល់ គឺ ប្រព័ន្ធផ្សព្វផ្សាយស្ទើរតែគ្មានតួនាទីអ្វីសោះ ក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីការងារដល់ទីជនបទ

កម្ពុជា ។ ចំណុចនេះបានគូសរំលេចពី ទំនាក់ទំនងសង្គមរវាងកម្មករចំណាកស្រុក និងភូមិ/ស្រុកដើមរបស់ពួកគេ ។ មេការសំណង់ម្នាក់ក្នុងភូមិសិក្សាមួយ គាត់តែងទូរស័ព្ទទៅភូមិកំណើតរបស់គាត់នៅពេលគាត់ត្រូវការកម្មករបន្ថែម ។ ដូច្នេះ កម្មករគ្មានជំនាញភាគច្រើន ជាយុវជនមកពីភូមិរបស់គាត់ ។ ដូចគ្នាដែរ អ្នកបម្រើប្រុស-ស្រីក្នុងភោជនីយដ្ឋានមួយ ច្រើនមកពីភូមិកំណើតផ្ទាល់របស់ម្ចាស់ភោជនីយដ្ឋាន រឺភូមិជិតៗភូមិនោះ ។ ករណីមានបងប្អូន រឺមិត្តភក្តិមកពីភូមិតែមួយ ចូលធ្វើការនៅក្នុងរោងចក្រ ភោជនីយដ្ឋាន រឺកន្លែងលាងរថយន្តតែមួយ គឺជាករណីទូទៅ ។ ការសិក្សាក៏បង្ហាញពីអវត្តមានរបស់អន្តរការី នៅក្នុងចលនាចំណាកស្រុកក្នុងប្រទេសដែរ ប៉ុន្តែចំពោះចំណាកស្រុកឆ្លងប្រទេសវិញអន្តរការីដើរតួនាទីសំខាន់ណាស់ ។

ទំនាក់ទំនង អាចជាកត្តាចំបងដែលកំណត់ជោគជ័យអោយកម្មករចំណាកស្រុក ពីព្រោះទំនាក់ទំនងល្អ ជួយបង្កើនឱកាសទទួលបានការងារមានសុវត្ថិភាព និងកាត់បន្ថយលទ្ធភាពត្រូវគេបោកប្រាស់ ។ អវត្តមានទំនាក់ទំនងផ្លូវការ និងវត្តមានទំនាក់ទំនងក្រៅផ្លូវការ គឺជាលក្ខណៈសំគាល់មួយនៃចំណាកស្រុករបស់យុវជនកម្ពុជា ។ ការសិក្សាបង្ហាញថា លក្ខណៈទូទៅជាងគេនៃចំណាកស្រុករបស់យុវជន គឺដំបូងមានយុវជនម្នាក់ រឺពីរនាក់ ធ្វើចំណាកស្រុកចេញពីភូមិ ។ មួយឆ្នាំ-ពីរឆ្នាំក្រោយមក ពួកគេត្រឡប់មកភូមិវិញ ហើយផ្សព្វផ្សាយព័ត៌មានពីការងារ និងផលប្រយោជន៍ទទួលបានពីចំណាកស្រុក ។ ក្នុងករណីភាគច្រើន យុវជនឈានមុខទាំងនេះ តែងធ្វើជាអ្នកសម្របសម្រួលដល់អ្នកភូមិដទៃទៀត ។ ក្នុងសង្គមបែបប្រពៃណីដូចនៅកម្ពុជា ទំនាក់ទំនងសង្គមមានមូលដ្ឋាននៅក្នុងភូមិ និងប្រទាក់គ្នាជាសំណាញ់ ប៉ុន្តែដោយមានចំណាកស្រុករបស់យុវជនចេញពីតំបន់ជនបទ ខ្សែទំនាក់ទំនងត្រង់ថ្មីៗក៏ចាប់ផ្តើមចាក់ឫស ដោយភ្ជាប់តំបន់ទីក្រុងទៅនិងតំបន់ជនបទ ។ ទំនាក់ទំនងថ្មីនេះ ជួយជំរុញដល់ការធ្វើចំណាកស្រុកចេញពីជនបទ ។ នៅពេលដែលទំនាក់ទំនងបែបប្រពៃណីនៅមានដដែល តែចុះខ្សោយបន្តិចនេះ ទំនាក់ទំនងថ្មីវាកាន់តែរឹងមាំឡើង និងដើរតួយ៉ាងសំខាន់នៅក្នុងចំណាកស្រុកពីជនបទទៅទីក្រុង ។ អ្នកនៅក្រៅខ្សែរយៈទំនាក់ទំនងថ្មីនេះ ត្រូវជួបការលំបាកច្រើនជាងក្នុងការធ្វើចំណាកស្រុក ។

## ប្រភពហិរញ្ញវត្ថុ

តាំងពីដើមរៀងមក គេតែងចាត់ទុកចំណាកស្រុក ជាវិនិយោគមួយប្រភេទ ។ នៅជនបទកម្ពុជា ជាទូទៅគេត្រូវខំប្រមូលដើមទុន ដើម្បីអោយសមាជិកគ្រួសារអាចធ្វើចំណាកស្រុក ។ ទាក់ទិននឹងប្រភពហិរញ្ញវត្ថុ មានមួយភាគបីបានឆ្លើយថាបានពីប្រាក់សន្សំគ្រួសារ ។ ប្រភពទីពីរ ដែលគេឆ្លើយប្រាប់គឺ ប្រាក់សន្សំផ្ទាល់ខ្លួន ទីបី ប្រាក់កម្ចី និង ទីបួន ការលក់ទ្រព្យសម្បត្តិ ។ ម្យ៉ាងទៀត មាន ៥% ទទួលបានប្រាក់ពីសាច់ញាតិ និង ៣% ទទួលបានប្រាក់ពីអនាគតថៅហ្វាយនាយ ។ រឿងជាក់ស្តែងដែលមាន ៣៧% បានខ្ចីប្រាក់គេ រឺលក់ទ្រព្យសម្បត្តិដើម្បីធ្វើចំណាកស្រុក វាជួយបំភ្លឺពីមូលហេតុដែលគ្រួសារមួយចំនួនមានជីវភាពកាន់តែដុនដាបទៅ ក្រោយពេលបរាជ័យក្នុងការធ្វើចំណាកស្រុក ។

នៅជនបទកម្ពុជា អ្នកក្រ និងអ្នកក្របំផុត ខ្វះទុនសូម្បីតែសំរាប់ធ្វើវិនិយោគដ៏តូចៗបំផុត ។ ជាទូទៅពួកគេពឹងផ្អែកលើប្រាក់កម្ចី ពីអ្នកចងការប្រាក់ រឺស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ។ ការខ្ចីប្រាក់ពីអ្នកចងការប្រាក់ ជាមធ្យោបាយបុរាណ រីឯការខ្ចីប្រាក់ពី MFIs ដែលទើបតែចូលទៅដល់តំបន់ជនបកម្ពុជានាពេលថ្មីៗ គឺជាជម្រើសមួយបន្ថែមទៀតសំរាប់អ្នកក្រ ។ ប្រាក់កម្ចី គឺជាការសម្រេចចិត្ត ដ៏ធ្ងន់ធ្ងរមួយសម្រាប់អ្នកក្រនៅជនបទ ។ ជារឿយៗអ្នកចងការប្រាក់មិនត្រូវការរបស់បញ្ចាំទេ ប៉ុន្តែពួកគេគិតការប្រាក់ខ្ពស់ មិនតិចជាង ១០% ក្នុងមួយខែទេ ។ ផ្ទុយទៅវិញ MFIs គិតការប្រាក់ត្រឹមតែ ៣% ក្នុងមួយខែ ប៉ុន្តែតម្រូវអោយអ្នកខ្ចីមានដាក់របស់បញ្ចាំ ដែលធម្មតាគឺជាដីស្រែ ។

## ៥. សមាហរណកម្មចូលក្នុងបរិយាកាសទីក្រុង

### ការសំរបខ្លួនចូលសង្គម

តើជនចំណាកស្រុកវ័យក្មេងមកពីតំបន់ជនបទ សំរបខ្លួន (ធ្វើសមាហរណកម្ម) ចូលទៅក្នុងជីវភាពនៅទីក្រុងយ៉ាងដូចម្តេច? យុវជនចំណាកស្រុកភាគច្រើនឆ្លើយថា ការធ្វើដំណើរទៅរកការងារធ្វើនៅទីក្រុង គឺជាការធ្វើដំណើរលើកទីមួយរបស់ពួកគេ ។ ការសិក្សាបង្ហាញថា ការធ្វើសមាហរណកម្មរបស់ពួកគេចូលទៅក្នុងជីវភាពទីក្រុង មានលក្ខណៈ "រាក់កំភែល" គួរឱ្យសោកស្តាយ ។ ពួកគេបានស្គាល់មិត្តភក្តិថ្មីដែល មកពីតំបន់ជនបទផ្សេងទៀតនៃប្រទេសកម្ពុជា ជាជាងអ្នកនៅទីក្រុងដែលពួកគេកំពុងរស់នៅ ។ ដូច្នេះវាជាទំនាក់ទំនងអ្នកជនបទ និងជនបទ ជាជាងទំនាក់ទំនងរវាងអ្នកជនបទ និងអ្នកទីក្រុង ហើយទំនាក់ទំនងរវាងកម្មករចំណាកស្រុកជនបទ និងម្ចាស់ផ្ទះជួល ក៏នៅមានតិចតួចដែរ ។ ពួកគេរវល់ការងារខ្លាំងពេក រឺខ្លាចពេកមិនហ៊ានចេញដើរខាងក្រៅ និងមិនចង់ចំណាយប្រាក់ដើម្បីស្គាល់ពីទីក្រុងឡើយ ។ តួយ៉ាងដូចជា អ្នកបម្រើតាមភោជនីយដ្ឋានតែងឃុំខ្លួនឯងនៅតែក្នុងកន្លែងធ្វើការ និងកម្រចេញទៅក្រៅណាស់ ចំណែកឯអ្នកលាងរថយន្តក៏ដូចគ្នាដែរ ។ កម្មករសំណង់ភាគច្រើន ស្នាក់នៅតែនៅក្នុងខ្ទមនៅក្នុង រឺនៅជុំវិញកន្លែងសាងសង់ ហើយកម្មករកាត់ដេរក៏ស្គាល់តែផ្លូវទៅកាន់កន្លែងធ្វើការប៉ុណ្ណោះ ។

### បៀវត្សរ៍ និងប្រាក់ចំណូល

ជាមធ្យមកម្មករជាយុវជនចំណាកស្រុកម្នាក់ រកចំណូលបាន ៣០៧.៤០០រៀលក្នុងមួយខែ ។ ចំណូលជាមធ្យមនេះ មានកម្រិតខ្ពស់បន្តិចដោយសារប្រាក់បៀវត្សរ៍របស់កម្មករកាស៊ីណូជាមធ្យមគឺ ៦២១.៧០០រៀលក្នុងមួយខែ ។ ចំពោះមុខរបរផ្សេងៗទៀត ប្រាក់កំរៃបានតិចតួចជាង ។ អ្នកលាងរថយន្តបានបៀវត្សរ៍ជាមធ្យម ១០២.២០០រៀលក្នុងមួយខែ ចំណែកឯអ្នកបម្រើប្រុសស្រីនៅភោជនីយដ្ឋាន គឺ ១០០.០០០រៀលក្នុងមួយខែ ប៉ុន្តែបូករួមនឹងប្រាក់ដែលភ្ញៀវឱ្យក្រៅទៀតនោះ (ធីប) អាចកើនរហូតដល់ ១៦៨.៩០០រៀលក្នុងមួយខែ ។ កម្មករកាត់ដេររកចំណូលបាន ២៧៩.៣០០រៀលក្នុងមួយខែ រីឯកម្មករសំណង់រកបាន ២៩២.៧០០រៀល ក្នុងមួយខែ ។ អ្នកលក់ដូរតូចតាច អ្នកអូសរទេះ និងអ្នករត់ម៉ូតូឌុប រកចំណូលបានជាង ១០.០០០ រៀលក្នុងមួយថ្ងៃ ។

### ការចំណាយ

ការចំណាយជាង ៥០% របស់កម្មករជាយុវជនចំណាកស្រុក គឺទៅលើម្ហូបអាហារ ។ ម្ហូបអាហារស្ថិតនៅលំដាប់ទីមួយ សំរាប់ការចំណាយរបស់ក្រុមគំរូតាងទាំងអស់ លើកលែងតែអ្នកលាងរថយន្ត ដែលទទួលបានអាហារដោយឥតគិតថ្លៃពីម្ចាស់យានដ្ឋាន ។ យុវជនចំណាកស្រុកចំណាយត្រឹមតែ ១៩០០រៀលក្នុងមួយខែ សម្រាប់ការធ្វើដំណើរ ដែលបង្ហាញថា ពួកគេមិនបានធ្វើដំណើរច្រើនទេក្នុងតំបន់ដែលគេរស់នៅ ។ ចំណាយជាមធ្យមលើការបរិភោគខាងក្រៅនៅចុងសប្តាហ៍ គឺ ៧៨០០រៀលក្នុងមួយខែ ។សរុបមក ជាមធ្យមយុវជនជាកម្មករចំណាកស្រុកម្នាក់ចំណាយ ១៤៥.៦០០រៀលក្នុងមួយខែ នៅទីក្រុងដែលការរស់នៅមានតំលៃថ្លៃ ។

## ៦. ប្រាក់ផ្ញើ

ការពិភាក្សាតាមក្រុមគោលដៅ ដែលធ្វើឡើងជាមួយឪពុកម្តាយ និងសាច់ញាតិរបស់យុវជនជាកម្មករចំណាកស្រុក បានបង្ហាញថា ភាគច្រើននៃការសម្រេចចិត្តធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តរបស់គ្រួសារ ច្រើនជាងការសម្រេចចិត្តរបស់ជនចំណាកស្រុកផ្ទាល់ ។ ដូច្នេះ យុវជនចំណាកស្រុកចាកចេញទៅរកប្រាក់ដើម្បីគ្រួសារ ច្រើនជាងសម្រាប់ខ្លួនឯង ។

គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលមានកម្មករជាយុវជនចំណាកស្រុកច្រើនលើសលប់ដល់ទៅ ៩៣,៤% បានផ្ញើប្រាក់ទៅផ្ទះ ។ ម្យ៉ាងទៀតក្នុងចំណោមអ្នកដែលមិនបានផ្ញើប្រាក់ទៅផ្ទះ មានមួយចំនួនកំពុងរស់នៅជាមួយគ្រួសាររបស់ខ្លួនស្រាប់ ដូច្នេះភាគរយកម្មករចំណាកស្រុកជាយុវជនដែលផ្តល់ប្រាក់ដល់គ្រួសារខ្លួន គឺសឹងតែដល់ ១០០% ។

អង្កេតគ្រួសារ បានផ្តល់លទ្ធផលស្ទើរតែដូចគ្នាទាំងស្រុង ពោលគឺគ្រួសារឆ្លើយសំភាសន៍ ៩០,១២% បានរាយការណ៍ថា បានទទួលប្រាក់ពីសមាជិកគ្រួសារខ្លួនដែលបានធ្វើចំណាកស្រុក ។

### ចំនួនទឹកប្រាក់ផ្ញើទៅផ្ទះ

កម្មករជាយុវជនចំណាកស្រុក បានផ្ញើប្រាក់ទៅគ្រួសារជាមធ្យម ១.០១២.៤០០ រៀលក្នុងមួយឆ្នាំ ដែលជាចំនួនប្រាក់ដ៏ច្រើនសម្រាប់ប្រជាជននៅតាមជនបទកម្ពុជា ហើយក្នុងករណីខ្លះ ប្រាក់នេះអាចផ្គត់ផ្គង់គ្រួសារបានទាំងស្រុងទៀតផង ។ ប្រាក់ផ្ញើ មានពី ៧៧៩.២០០រៀលក្នុងមួយឆ្នាំ (ប្រាក់ផ្ញើរបស់ក្រុមអ្នកបម្រើ) ដល់ ២.៧៣៩.៧០០រៀលក្នុងមួយឆ្នាំ (ប្រាក់ផ្ញើរបស់ក្រុមកម្មករកាស៊ីណូ) ។ ចំណែកឯទិន្នន័យបានពីអង្កេតគ្រួសារ បង្ហាញថា កម្មករចំណាកស្រុកផ្ញើប្រាក់ជាមធ្យម ៩១៨.៩០០រៀលក្នុងមួយឆ្នាំ ទៅអោយគ្រួសាររបស់ពួកគេ ។

ជាមធ្យម យុវជនជាកម្មករចំណាកស្រុកផ្ញើប្រាក់ទៅផ្ទះអស់ ២៧,៤៤% នៃចំណូលសរុបរបស់ពួកគេ ។ ភាគរយនេះ ប្រែប្រួលខ្លាំងអាស្រ័យលើមុខរបររបស់កម្មករ ដោយមានចាប់ពី ១៥,៧៧% (ផ្ញើដោយពួកអ្នករត់ម៉ូតូឌុប) ដល់ ៧២,៩៦% (ផ្ញើដោយពួកអ្នកលាងរថយន្ត) ។ចំណុចនេះបង្ហាញម្តងទៀតពីទំនាក់ទំនងយ៉ាងខ្លាំងរវាងតំបន់ប្រភពដើម និងតំបន់គោលដៅនៃចំណាកស្រុក និងការពឹងផ្អែករបស់គ្រួសារនៃជនចំណាកស្រុកទៅលើប្រាក់ដែលពួកគេផ្ញើទៅផ្ទះ ។

### ច្រកផ្ញើប្រាក់

កម្មករចំណាកស្រុកផ្ញើប្រាក់ទៅផ្ទះជាទៀងទាត់ ដូចនេះ ការជ្រើសរើសច្រកផ្ញើប្រាក់ដែលអាចទុកចិត្តបាន គឺជាបញ្ហាសំខាន់ណាស់សំរាប់ពួកគេ ។ ការសិក្សាបង្ហាញថា ស្ថាប័នមីក្រូហិរញ្ញវត្ថុដើរតួនាទីតិចតួចក្នុងការផ្ញើប្រាក់ ដោយមានកម្មករឆ្លើយសំភាសន៍តែ ៦,២៦% ប៉ុណ្ណោះដែលប្រើប្រាស់ច្រកនេះដើម្បីផ្ញើប្រាក់ ។ ច្រកមិនផ្លូវការបានគ្របដណ្តប់លើករណីភាគច្រើន ក្នុងនេះ ការផ្ញើតាមសាច់ញាតិ អោយយកទៅដោយផ្ទាល់នៅពេលទៅលេងផ្ទះ ការផ្ញើតាមមិត្តភក្តិ និងការផ្ញើតាមអ្នកភូមិ មាន ២៥%ស្មើៗគ្នា ។ យុវជនជាកម្មករចំណាកស្រុកចំនួន ២,០២% មានសមាជិកគ្រួសារនៅឯភូមិ ឡើងមកយកប្រាក់ដោយផ្ទាល់ នៅកន្លែងដែលពួកគេធ្វើការ ។

មូលហេតុដែលស្ថាប័នមីក្រូហិរញ្ញវត្ថុដើរតួនាទីតិចតួច គឺដោយសារវាមានថ្លៃសេវាខ្ពស់ និងមានទំរង់បែបបទសាំញ៉ាំ ។ ផ្ទុយទៅវិញ ការផ្ញើប្រាក់តាមរថយន្តតាក់ស៊ី និងតាមសេវាហាងទូរស័ព្ទ មានភាពឆាប់រហ័ស និងបែបបទសាមញ្ញ ដែលជា មូលហេតុនាំអោយពួកគេជ្រើសរើសការផ្ញើតាមវិធីនេះ ។

### ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ

ទំនាក់ទំនងរវាងភាពក្រីក្រ និងចំណាកស្រុកនៅតែស្មុគស្មាញជាខ្លាំង ។ ពិតហើយភាពក្រីក្រគឺជាកត្តាដ៏សំខាន់មួយដែលធ្វើអោយមានចំណាកស្រុក ហើយចំណាកស្រុកក៏ជាកត្តាជួយកាត់បន្ថយភាពក្រីក្រដែរ ។ ការយល់ដឹងពីរបៀបដែលគ្រួសារយុវជនចំណាកស្រុកប្រើប្រាស់ប្រាក់ផ្ញើ គឺសំខាន់ណាស់ដើម្បីស្វែងយល់ថាតើចំណាកស្រុកជួយកាត់បន្ថយភាពក្រីក្រ និងកែលំអសុខមាលភាពគ្រួសារ/សហគមន៍បានយ៉ាងដូចម្តេច ។ ការប្រើប្រាស់ប្រាក់ផ្ញើសម្រាប់គោលដៅផលិតកម្ម រឺគោលដៅផ្សេងទៀត វាមានផលប៉ះពាល់រយៈពេលវែងមិនត្រឹមតែសំរាប់ក្រុមគ្រួសារ រឺសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់កម្មករចំណាកស្រុកខ្លួនឯងផងដែរ នៅពេលពួកគេត្រឡប់មកផ្ទះវិញ ។ គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលនៅពេលពិភាក្សាតាមក្រុមគោលដៅ មានយុវជនជាកម្មករចំណាកស្រុកមួយចំនួនមិនបានដឹងច្បាស់ទេថា តើគ្រួសាររបស់ខ្លួនប្រើប្រាស់ប្រាក់ដែលខ្លួនផ្ញើទៅផ្ទះនោះយ៉ាងដូចម្តេច ។

ការសិក្សាលើទិន្នន័យអង្កេតកម្មករចំណាកស្រុក និងអង្កេតគ្រួសារ បានបង្ហាញថា គេប្រើប្រាស់ប្រាក់ផ្ញើជាសំខាន់ទីមួយសំរាប់ទិញម្ហូបអាហារ និងទីពីរសំរាប់ទិញទ្រព្យផលិតកម្ម (ដូចជា គ្រាប់ពូជ ជី និងគោក្របី) ។ ចំណាយក្នុងមុខងារសង្គម (ដូចជា អាពាហ៍ពិពាហ៍ និងសាសនា) គឺជាមុខចំណាយទីបីក្នុងអង្កេតទាំងពីរខាងលើ ព្រោះនៅជនបទកម្ពុជា មុខងារបែបនេះកើតមានឡើងជាញឹកញាប់ណាស់ ។ ចំណាយមួយទៀតដែលអាចចាត់ទុកថាសំរាប់ផលិតកម្មរយៈពេលវែងដែរ គឺចំណាយលើការសិក្សារបស់បង/ប្អូនបង្កើត ដែលជាមុខចំណាយទីបួននៅក្នុងអង្កេតពីកម្មករចំណាកស្រុក និងមុខចំណាយទីប្រាំនៅក្នុងអង្កេតគ្រួសារ ។ ចំពោះការសងបំណុល វាជាមុខចំណាយទីបួន នៅក្នុងអង្កេតគ្រួសារ និងមុខចំណាយទីប្រាំនៅក្នុងអង្កេតកម្មករចំណាកស្រុក ។ ការសន្សំមានតិចជាង ៤% ក្នុងអង្កេតពីកម្មករចំណាកស្រុក ហើយតិចជាង ២% ក្នុងអង្កេត

គ្រួសារ ។ ការចាប់ផ្ដើមមុខរបរថ្មី ការទិញ/ពង្រីកដីស្រែ ការជួសជុលផ្ទះ និងការទិញសំភារៈប្រើប្រាស់យូរឆ្នាំ (ដូចជា ទូរទស្សន៍ ម៉ូតូ កង់ ... ដែលនៅតែជារបស់ប្រណិតសំរាប់ប្រជាជននៅជនបទ) មានតិចជាង ១% នៅក្នុងអង្កេតទាំងពីរ ។

### ផលប៉ះពាល់នៃប្រាក់ផ្ញើទៅលើគ្រួសារ និងសហគមន៍របស់យុវជនជាកម្មករចំណាកស្រុក

ការសិក្សាបានបង្ហាញច្បាស់ថា គ្រួសារយុវជនចំណាកស្រុកភាគច្រើនទទួលបានផលប្រយោជន៍ពីចំណាកស្រុករបស់សមាជិកគ្រួសារ ប៉ុន្តែផលប៉ះពាល់នៃចំណាកស្រុកទៅលើចីរភាពនៃការចិញ្ចឹមជីវិត រឺការកាត់បន្ថយភាពក្រីក្រ នៅតែមានលក្ខណៈស្មុគស្មាញខ្លាំងនៅឡើយ ។ ចាប់តាំងពីកំណើនយ៉ាងគំហុកនៃចំណាកស្រុកយុវជនពីជនបទទៅទីក្រុងនៅចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍ ២000 គេឃើញមានលំហូរប្រាក់ផ្ញើយ៉ាងច្រើនពីទីក្រុងទៅតំបន់ជនបទ ។ ពិតហើយប្រាក់ផ្ញើបានជួយរក្សាលំនឹងការចិញ្ចឹមជីវិតនៅជនបទកម្ពុជា ប៉ុន្តែវាមាននិន្នាការមិនល្អមួយដោយគ្រួសារនៅជនបទមួយចំនួន បានចាប់ផ្ដើមពឹងផ្អែកខ្លាំងពេកលើចំណាកស្រុករបស់កូនៗ ។ នៅពេលធ្វើអង្កេតគ្រួសារ ក្រុមអ្នកស្រាវជ្រាវបានអង្កេតឃើញ គ្រួសារមួយចំនួននៅក្នុងសហគមន៍យុវជនចំណាកស្រុកមិនបានធ្វើការងារអ្វីទាំងអស់ ហើយរង់ចាំតែប្រាក់ផ្ញើមកពីទីក្រុង ។ ក្នុងករណីនេះ ចំណាកស្រុកមិនមែនជាប្រភពចំណូលបន្ថែមសម្រាប់គ្រួសារទេ ។ វាជាប្រភពចំណូលតែមួយគត់សំរាប់គ្រួសារ ។ ការសិក្សាជាច្រើនទៀតធ្វើឡើងដោយវិទ្យាស្ថាន CDRI បានបង្ហាញថា អ្នកក្រអាចចាកផុតពីភាពក្រីក្រ នៅពេលពួកគេមានប្រភពចំណូលច្រើន ដូច្នេះការបោះបង់ចោលការងារធ្វើស្រែចំការ ហើយរង់ចាំប្រាក់ដែលសមាជិកចំណាកស្រុកផ្ញើមក អាចមានផលប៉ះពាល់អវិជ្ជមានលើស្ថានភាពហិរញ្ញវត្ថុគ្រួសារ ។ បញ្ហាសំខាន់មួយទៀតគឺ យុវជនចំណាកស្រុកភាគច្រើនជាកម្មករគ្មានជំនាញ រឺមានជំនាញតិចតួច ដូច្នេះការងាររបស់ពួកគេមិនសូវបានជាប់លាប់ល្អទេ ហើយការពឹងផ្អែកខ្លាំងពេកលើប្រាក់ផ្ញើអាចជាអន្ទាក់មួយ ។

សរុបមក ចំណាកស្រុករបស់យុវជនមានផលប៉ះពាល់វិជ្ជមានយ៉ាងខ្លាំងលើសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ។ បើសិនរកការងារធ្វើមិនបាន រឺក៏ត្រូវគេបោកប្រាស់ គ្រួសារយុវជនចំណាកស្រុកត្រូវទទួលផលប៉ះពាល់អវិជ្ជមាន ប៉ុន្តែចំណាកស្រុកទទួលបរាជ័យបែបនេះមិនកើតមានញឹកញាប់ដូច ចំណាកស្រុកឆ្លងប្រទេសទេ ទោះបីគ្មានទំនាក់ទំនងសង្គមផ្លូវការ និងប្រព័ន្ធការពារសមស្របក្ដី ។ គ្រួសារដែលមានយុវជនធ្វើកម្មករចំណាកស្រុក អាចមានស្ថិរភាពហិរញ្ញវត្ថុល្អជាង និងពេលខ្លះអាចកែលំអសុខមាលភាពគ្រួសារបានទៀតផង ។ ប៉ុន្តែអ្នកក្របំផុត មិនមែនជាអ្នកដែលមានអត្រាចំណាកស្រុកខ្ពស់ជាងគេនោះទេ ។ ប្រាក់ដែលយុវជនចំណាកស្រុកផ្ញើមកផ្ទះ ក៏មានផលប៉ះពាល់វិជ្ជមានយ៉ាងច្បាស់ទៅលើសេដ្ឋកិច្ចរបស់សហគមន៍ដែរ ។ វាជួយជំរុញសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការបង្កើតអាជីវកម្ម/ពាណិជ្ជកម្មតូចៗថ្មីៗជាច្រើន និងការបង្កើនចំណាយប្រើប្រាស់របស់គ្រួសារ ។ ភូមិដែលមានយុវជនធ្វើចំណាកស្រុកច្រើន តែងមានសកម្មភាពសេដ្ឋកិច្ចច្រើនជាងភូមិដែលមានយុវជនធ្វើចំណាកស្រុកតិច ។

## ៧. សេចក្ដីសន្និដ្ឋាន

ចំណាកស្រុកកម្លាំងពលកម្ម មានផលប៉ះពាល់យ៉ាងខ្លាំង និងមានតួនាទីកាន់តែច្រើនក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ដែលសព្វថ្ងៃមានប្រជាជន ៣៥% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ និងរកចំណូលបានតិចជាង 0,៥0 ដុល្លារ/ថ្ងៃ ។ ប្រាក់ដែលជនចំណាកស្រុកផ្ញើមកផ្ទះ មានចំនួនច្រើនគួរឱ្យកត់សំគាល់ ហើយក្នុងករណីខ្លះវាអាចផ្គត់ផ្គង់គ្រួសារនៅជនបទបានពេញៗមួយឆ្នាំ ។ កាលពីមុនគេបានចាត់ទុកចំណាកស្រុកជាប្រភពទីពីរ រឺទីបី នៃប្រាក់ចំណូលគ្រួសារ និងគ្រាន់តែជាប្រភពចំណូលបន្ថែមប៉ុណ្ណោះ ប៉ុន្តែសព្វថ្ងៃវាបានក្លាយជាប្រភពចំណូលសំខាន់ជាងគេសំរាប់គ្រួសារមួយចំនួន ។ ចំណាកស្រុកធ្វើអោយមានប្រភពចំណូលច្រើន និងជួយអោយប្រជាជននៅជនបទអាចសន្សំប្រាក់បានខ្លះដើម្បីទុកប្រើការនៅពេលមានវិបត្តិអ្វីមួយកើតឡើងភ្លាមៗ ។

សំណួរជាគោលនយោបាយសំខាន់មួយគឺ តើចំណាកស្រុកកំលាំងពលកម្មអាចជំនួសអោយការអភិវឌ្ឍនៅជនបទកម្ពុជាបានដែររឺទេ ។ ចំណាកស្រុកជាដំណោះស្រាយរយៈពេលខ្លី រឺមធ្យម ជាជាងរយៈពេលវែង ។ ចំណាកស្រុកកំលាំងពលកម្មមិនអាចដោះស្រាយ កង្វះការងារមិនមែនកសិកម្មនៅតាមជនបទកម្ពុជាបានភ្លាមៗទេ ។ ការងារប្រភេទផ្សេងទៀតនៅជនបទត្រូវតែបង្កើតឡើង ដើម្បីឱ្យការអភិវឌ្ឍនៅជនបទមានចីរភាពល្អ ប៉ុន្តែការអភិវឌ្ឍតែងផ្សារភ្ជាប់ដោយកំណើនប្រជាជននៅទីក្រុង និង ការថយចុះចំនួនប្រជាជននៅជនបទ ។ ចំណាកស្រុកត្រូវតែមានលក្ខណៈជាអចិន្ត្រៃយ៍ដើម្បីអោយប្រទេសរីកលូតលាស់ ប៉ុន្តែចំណាកស្រុកអចិន្ត្រៃយ៍មិនមែនសុទ្ធតែនាំឱ្យមានការអភិវឌ្ឍនោះទេ ។ អ្នកប្រាជ្ញខាងអភិវឌ្ឍន៍ជាច្រើននាក់មានជំនឿថា វិស័យឧស្សាហកម្ម ត្រូវតែមានសកម្មភាពខ្លាំងក្លា ដើម្បីអាចស្រូបយកជនចំណាកស្រុកបានច្រើន ៕

### ឯកសារយោង


Department for International Development (2004), “Migration and Development: How to Make Migration Work for Poverty Reduction”, written evidence to the International Development Committee, House of Commons, sixth report, session 2003–04, Vol. II House of Commons, DFID, the Stationery Office

Kim S.K. (2005), Rural-Urban Migration in Cambodia. A Case Study: Migration to Phnom Penh (Phnom Penh: Dept. of Sociology, Royal University of Phnom Penh).

Laczko, F. (2005), “Migration, Development and Poverty in Asia”, International Organization for Migration. Geneva

Oishi Nana (2002), “Gender and Migration and Integration Approach” Working Paper 49, (San Diego: University of California)

# សុខុមាលភាពសហគមន៍ និងចលនាគ្រួសារនៅកម្ពុជា ក្រោយពេលបញ្ចប់ជម្លោះ[១]

*ដោយបណ្ឌិត Brett Ballard*[២]

## ១. សេចក្តីផ្តើម

ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅបណ្តាប្រទេសដែលធ្លាប់ឆ្លងកាត់ភាពវឹកវរខាងនយោបាយ និងជម្លោះហិង្សា ច្រើនតែយឺតយ៉ាវជាងនៅបណ្តាប្រទេសមានសុខសន្តិភាព និងស្ថិរភាព ។ ប៉ុន្តែគេនៅមិនទាន់យល់ច្បាស់លាស់នៅឡើយទេពីចំណងទាក់ទង នៅក្នុងមូលដ្ឋានរវាងជម្លោះ និងការអភិវឌ្ឍ ។ អត្ថបទនេះ មានគោលដៅចែករំលែកការយល់ដឹងពីចំណងទាក់ទងនេះ តាមការវិភាគពីបែបបទដែលជម្លោះ និងការទទួលបានសន្តិភាព វាជះឥទ្ធិពលទៅលើកត្តាផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងសុខុមាលភាពរបស់សហគមន៍ និងចលនាឈានឡើងរបស់គ្រួសារតាមភូមិចំនួន ៩ នៅកម្ពុជា ។

ភូមិទាំង ៩ ខុសប្លែកគ្នាតាំងពីទីតាំង និងលក្ខណៈអំណោយផលភូមិសាស្ត្រ ។ កត្តាទាំងនេះ បានកំណត់ពីយុទ្ធសាស្ត្រចិញ្ចឹមជីវិត និងសមត្ថភាពរបស់គ្រួសារក្នុងការធ្វើចំរុះកម្មប្រភពចំណូល និងការទទួលបាន សេវាកម្ម ព័ត៌មាន និងទីផ្សារសំរាប់ការធ្វើពាណិជ្ជកម្ម និងការងារ ។ ភូមិនីមួយៗធ្លាប់ឆ្លងកាត់ជម្លោះតាមផ្លូវអាវុធក្នុងកំរិតខុសៗគ្នា ហើយក៏ទទួលបានសន្តិភាពនៅពេលខុសៗគ្នាដែរ ។ បើមើលមួយភ្លែត ភូមិដែលបានបញ្ចប់ជម្លោះតាំងពីមុន រឺនៅដើមគ្រានៃការសិក្សា (១៩៩៣-២០០៣/០៤) ហាក់ដូចជាមានដំណើរការល្អជាង ភូមិដែលមានការប្រយុទ្ធគ្នាខ្លាំងជាង និងអូសបន្លាយយូរជាង ។ ប៉ុន្តែតាមការពិនិត្យល្អិតល្អន់បង្ហាញថា កាលបរិច្ឆេទនៃការបញ្ចប់ជម្លោះតាមផ្លូវអាវុធមិនមែនជាសូចនាករដ៏សំខាន់សំរាប់ប៉ាន់ស្មានពី សុខុមាលភាពរបស់សហគមន៍ និងចលនាឈានឡើងរបស់គ្រួសារនោះឡើយ ។

ផ្នែកខាងក្រោមនេះ បង្ហាញយ៉ាងសង្ខេបអំពីភូមិទាំង ៩ ដែលបានសិក្សាលើការចាកផុតភាពក្រីក្រ (MOPS) ។ ផ្នែកទី៣ តាមដានថា តើវត្តមាន រឺអវត្តមាននៃជម្លោះតាមផ្លូវអាវុធ មានទាក់ទងនឹងកត្តាសំខាន់ៗទាំង ៤ ដែលជះឥទ្ធិពលលើសុខុមាលភាពរបស់សហគមន៍ និងចលនាគ្រួសារដែររឬទេ ។ កត្តាទាំង ៤ មាន: ការទទួលបានដី និងលក្ខណៈដីពេលបញ្ចប់ជម្លោះ ជំនួយអភិវឌ្ឍន៍ និងទីតាំង និងការទទួលបានជំនួយផ្សេងៗ ។ ផ្នែកទី ៤ សន្និដ្ឋាន ដោយផ្តល់ការពិភាក្សាលើការកំណត់អាទិភាពទិសដៅ និងដំណាក់កាលផ្សេងៗនៃជំនួយអភិវឌ្ឍន៍ក្នុងសហគមន៍ក្រោយពេលបញ្ចប់ជម្លោះ ព្រមទាំងមធ្យោបាយនានាដើម្បីធានាចីរភាពនៅពេលដែលការអភិវឌ្ឍបានចាប់ផ្តើម "ស្ទុះឡើង" ។

## ២. ភូមិនានាក្នុងការសិក្សាពីការចាកផុតភាពក្រីក្រ

ភូមិចំនួន ៩ ក្នុងការសិក្សាអំពីការចាកផុតភាពក្រីក្រ ដើមឡើយបានជ្រើសយកនៅឆ្នាំ២០០១ សំរាប់ការសិក្សាមួយ ស្តីពីការចិញ្ចឹមជីវិតនៅជនបទដោយផ្អែកតាមតំបន់កសិ-អេកូឡូស៊ីផ្សេងៗ ។ នៅអំឡុងឆ្នាំ២០០៤-០៥ បានធ្វើអង្កេតលើ ៨៩០គ្រួសារក្នុងចំណោមគ្រួសារពីដំបូងចំនួន ១០១០គ្រួសារ ហើយបង្កើតបានជាទិន្នន័យមួយឈុត ដែលជួយអោយអ្នកស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI អាចវាស់វែងបានពីការប្រែប្រួលខាង សុខុមាលភាពរបស់សហគមន៍ និងចលនារបស់គ្រួសារក្នុងរយៈពេល ៣ឆ្នាំ ។

គេបានបែងចែកភូមិនានាជា ៣ កញ្ចុំសុខុមាលភាព ដោយផ្អែកលើចំណាយប្រើប្រាស់ ចំណូល និងអត្រាភាពក្រីក្រ ។ ភូមិដែលដំណើរការខ្លាំង មានចំណូល និងចំណាយប្រើប្រាស់ កើនឡើង ព្រមទាំងថយចុះអត្រាភាពក្រីក្រ ។ ជាលក្ខណៈសំគាល់ ភូមិទាំងនេះមានផ្លូវចូលទៅភូមិល្អជាង ភូមិសាស្ត្រអំណោយផលទំនាក់ទំនងទៅទីផ្សារល្អជាងសំរាប់ពាណិជ្ជកម្មនិងការងារ ជំនួយអភិវឌ្ឍន៍ច្រើន និងផលិតភាពកសិកម្មខ្ពស់ ។ ភូមិដែលដំណើរការបង្គួរ មាន កំណើនចំណូល និង/រឺកំណើនចំណាយប្រើប្រាស់ រឺក៏មានការកាត់បន្ថយភាពក្រីក្រខ្លះៗ (មានមួយអត់មួយ) ។ ទោះជាភូមិទាំងនេះមានលក្ខណៈខុសប្លែកគ្នាខ្លះៗក៏ដោយ ប៉ុន្តែជាទូទៅមានផ្លូវចេញចូលពិបាកជាង ត្រូវពឹងផ្អែកខ្លាំងលើធនធានទ្រព្យរួម និងមានដីធ្លីធ្វើកសិកម្មតិចជាង ។ ភូមិដែលដំណើរការអន់ខ្សោយ ពុំមានកំណើនអ្វីគួរកត់សំគាល់ទៅលើចំណូល ចំណាយប្រើប្រាស់ រឺការកាត់បន្ថយភាពក្រីក្រទេ ។ ភូមិនៅដាច់ស្រយាល ត្រូវពឹងផ្អែកលើធនធានធម្មជាតិ មានដីកសិកម្មតិច ដីធ្លីមិនសូវមានជីជាតិ និងទទួលបានជំនួយអភិវឌ្ឍន៍តិចជាងគេបង្អស់ ។

ក្រាហ្វិក ១ បង្ហាញពីការបែងចែកចលនាក្រុម នៅតាមភូមិដែលបានសិក្សាទាំង ៩ ។ ភូមិដែលដំណើរការខ្លាំង មានភូមិក្រសាំង បាបោង និងអណ្តូងត្រាច និងមានគ្រួសារមានជីវភាពគ្រាន់បើ និងគ្រួសារធូរធារច្រើនជាង ។ ភូមិដែលដំណើរការអន់ខ្សោយ មានភូមិកំពង់ត្នោត ដងក្តារ និងខ្សាច់ជីរស់ និងមានគ្រួសារធ្លាក់ចុះក្រីក្រ និង គ្រួសារក្រីក្ររហូតច្រើនជាង ។ នៅភូមិដែលដំណើរការបង្គួរទាំង ៣ គឺភូមិកញ្ជរ ព្រៃកក្ទេង និងត្រពាំងប្រិយ៍ គ្រួសារហាក់មានចលនាផ្ទុយគ្នា ដោយសារគ្រួសារដែលមានជីវភាពធូរធារ និងគ្រួសារដែលមានជីវភាពគ្រាន់បើ គឺមានចំនួនប្រហាក់ប្រហែលគ្នានឹង គ្រួសារដែលធ្លាក់ចុះក្រ និងគ្រួសារក្រីក្ររហូត ។

---

១ ភស្តុតាង និងការវិភាគមួយផ្នែកធំនៅក្នុងអត្ថបទនេះ ដកស្រង់ចេញពីរបាយការណ៍របស់ CDRI ស្តីពី ការចាកផុតភាពក្រីក្រ?: និន្នាការសុខុមាលភាពសហគមន៍ និងចលនាគ្រួសារក្នុងភូមិសិក្សាចំនួន៩នៅកម្ពុជា (FitzFerald, So *et al. 2007*) ។ អត្ថបទនេះផ្តល់ពត៌មាន និងការវិភាគបន្ថែមទាក់ទងនឹងតួនាទីនៃជម្លោះក្នុងការកំណត់ពីកំរិតសុខុមាលភាពរបស់សហគមន៍ និងចលនាគ្រួសារនៅភូមិសិក្សាទាំង ៩ ។

២ បណ្ឌិត Brett Ballard ជាទីប្រឹក្សាផ្នែកអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា (AusAID) ។ អត្ថបទនេះជាសេចក្តីសង្ខេបនៃជំពូកមួយក្នុងឯកសារបោះពុម្ពផ្សាយពី ការសិក្សាពីការចាកផុតភាពក្រីក្រជាសាកលរបស់ធនាគារពិភពលោក ទាក់ទងនឹងជម្លោះ និងចលនាគ្រួសារ ។ បណ្ឌិត Ballard បានចងក្រង អត្ថបទនេះ នៅពេលបំរើការជាទីប្រឹក្សាផ្នែកស្រាវជ្រាវជាន់ខ្ពស់នៅវិទ្យាស្ថាន CDRI ។ យោបល់ និងការបកស្រាយផ្សេងៗជារបស់អ្នកនិពន្ធផ្ទាល់ និងមិនមែនជារបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលីទេ ។

រូបភាពទី ១.០: ការបែងចែកក្រុមចលនទីមួយៗក្នុងភូមិសិក្សាទាំង ៩




ប្រភព: ៨៩០ក្រុមគ្រួសារ នៅឆ្នាំ២០០៤/០៥

## ៣. ជម្លោះ និងសុខុមាលភាពរបស់សហគមន៍

តារាង ១ បានបែងចែកភូមិទាំង ៩ ទៅតាមប្រភេទដំណើរការរបស់សហគមន៍ និងប្រភេទជម្លោះ ។ ចំពោះ ភូមិស្ថិតក្នុងតំបន់បៃតង ជម្លោះតាមផ្លូវអាវុធបានបញ្ចប់តាំងពីមុនពេល រឺនៅពេលចាប់ផ្ដើមដំណើរការសិក្សាមកម្ល៉េះ ។ ចំណែកភូមិក្នុងតំបន់ក្រហម ជម្លោះតាមផ្លូវអាវុធបានបន្តរហូតដល់អំឡុងពេលសិក្សា ។ ម៉ាទ្រីស លើកឡើងពីទំនាក់ទំនងមួយចំនួន រវាងសុខុមាលភាពរបស់សហគមន៍ និងជម្លោះតាមផ្លូវអាវុធ ។ ឧទាហរណ៍ ពីរភូមិក្នុងចំណោមភូមិទាំងបី ដែលដំណើរការអន់ គឺភូមិខ្សាច់ជីរស់ និងដងក្ដារ ស្ថិតក្នុងតំបន់ក្រហមដែល

**តារាង១: ម៉ាទ្រីស នៃជម្លោះ និងដំណើរការរបស់សហគមន៍ (ឆ្នាំបញ្ចប់ជម្លោះ)**

| | ពណ៌បៃតង | ពណ៌ក្រហម |
|---|---|---|
| ភូមិដំណើរការខ្លាំង | បាបោង (១៩៨៤)<br>អណ្ដូងត្រាច (១៩៩៤) | ក្រសាំង (១៩៩៨) |
| ភូមិដំណើរការបង្គួរ | ព្រែកក្មេង (១៩៨៤)<br>ត្រពាំងព្រីយ៍ (១៩៩៣) | កញ្ជរ (១៩៩៨) |
| ភូមិដំណើរការអន់ | កំពង់ត្នោត (១៩៩៣) | ខ្សាច់ជីរស់ (១៩៩៧)<br>ដងក្ដារ (១៩៩៨) |

ការប្រយុទ្ធគ្នានៅតែខ្លាំង និងអូសបន្លាយរហូតដល់ឆ្នាំ១៩៩៧ រឺ ១៩៩៨ ។ ទន្ទឹមនេះ ក្នុងចំណោមភូមិទាំងបីដែលដំណើរការខ្លាំង មាន ២ភូមិ គឺភូមិបាបោង និងអណ្ដូងត្រាច ស្ថិតក្នុងតំបន់បៃតងដោយបានបញ្ចប់ជម្លោះរួចរាល់ តាំងពីមុន រឺនៅដើមគ្រានៃការសិក្សា ។

ផ្ទុយទៅវិញ ម៉ាទ្រីសបង្ហាញថា ភូមិនៅតំបន់ក្រហម គឺភូមិក្រសាំងមានដំណើរការខ្លាំង តែភូមិមួយទៀតនៅតំបន់ក្រហមដែរ គឺភូមិកញ្ជរមានដំណើរការបង្គួរប៉ុណ្ណោះ ។ ភូមិកំពង់ត្នោត ជាភូមិនៅក្នុងតំបន់បៃតង តែមានដំណើរការអន់ខ្សោយ ។ ករណីនេះបង្ហាញថា ជម្លោះតាមផ្លូវអាវុធ និងពេលបញ្ចប់ជម្លោះ មិនមែន ជាកត្តាព្យាករណ៍គួរអោយទុកចិត្តបានច្បាស់លាស់ពីសុខុមាលភាពសហគមន៍នោះទេ ហើយដំណើរការភូមិត្រូវពឹងផ្អែកលើ កត្តាជាច្រើនទៀត ។ តទៅនេះ ជាការពិនិត្យពីកត្តាសំខាន់ៗទាំង ៤ ដែលផ្សារភ្ជាប់ជម្លោះ ជាមួយនឹងសុខុមាលភាពសហគមន៍ និងចលនាគ្រួសារ គឺមានការទទួលបានដីនិងលក្ខណៈដីពេលបញ្ចប់ជម្លោះ ជំនួយអភិវឌ្ឍន៍ និងទីតាំងនិងការទទួលបានជំនួយផ្សេងៗ ។

### *៣.១. ការទទួលបានដី និងលក្ខណៈដី*

ការទទួលបានដី គឺជាគ្រឹះសំរាប់អោយគ្រួសារនានាប្រមូលបង្គរទ្រព្យធន ធ្វើចំរុះកម្មប្រភពចំណូល និងជាកត្តាគន្លឹះសំរាប់ការឈានឡើងនៃជីវភាពគ្រួសារ ។ នៅទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ ការបែងចែកដីធ្លីនៅតាមមូលដ្ឋាន

និងសមត្ថភាពរានយកដីរបស់គ្រួសារ បានទទួលរងឥទ្ធិពលមកពីវិសាលភាព និងកំរិត នៃជម្លោះតាមផ្លូវអាវុធ និងមកពីកាលៈទេសៈនៃការបញ្ចប់ជម្លោះនៅតាមតំបន់នីមួយៗ ។ គេបានបង្កើតឡើងនូវក្រុមសាមគ្គីនៅក្នុងភូមិទាំង ៩ ហើយបន្ទាប់មក ក៏មានការបែងចែកដីកសិកម្មទៅឱ្យគ្រួសារនានាដែលជាសមាជិកក្រុមសាមគ្គី ។ នៅក្នុងភូមិចំនួនពីរ គេបានអនុញ្ញាតអោយប្រជាជនអាចទទួលបានដីដែលពួកគេកាន់កាប់មុនសម័យខ្មែរក្រហមឡើងវិញ ។ រីឯនៅភូមិទ្បេតៗ គេបែងចែកដីទៅតាមចំនួនសមាជិកគ្រួសារ ។ ទោះបីរូបមន្តសំរាប់បែងចែកដីប្រែប្រួលខុសគ្នាក្តី ក៏គ្រួសារដែលមានសមាជិកច្រើន តែងទទួលបានដីច្រើនជាងគ្រួសារដែលមានសមាជិកតិច ។ នៅភូមិខ្លះទៀត គ្រួសារទទួលបានចំណែកដីស្មើៗគ្នា ដោយមិនគិតពីទំហំគ្រួសារឡើយ ។ ម្យ៉ាងទៀត អ្នកដឹកនាំនៅមូលដ្ឋាន ក៏បានប្រឹងប្រែងបែងចែកដីមានគុណភាពប្រហាក់ប្រហែលគ្នាទៅអោយគ្រួសារនានាដែរ ។

សមត្ថភាពរបស់គ្រួសារក្នុងការទទួលបានដីបន្ថែម តាមរយៈការរានដីព្រៃ ត្រូវពឹងផ្អែកលើចំនួន និងចលនាកំលាំងពលកម្មដែលគេមាន ។ គ្រួសារធំៗដែលអាចទទួលបានដីច្រើនៗមកពីការបែងចែកដី ក៏ច្រើនមានលទ្ធភាពធំជាងក្នុងការទទួលបានដីច្រើនថែមទៀតពីការរានដីដែរ បើសិនស្ថានភាពមានសន្តិសុខល្អអាចអោយពួកគេរានដីបាន ។ ឧទាហរណ៍ នៅភូមិខ្សាច់ជីរស់ដែលស្ថិតក្នុងតំបន់ក្រហម អ្នកភូមិទទួលការអនុញ្ញាតឱ្យរានដីបន្ថែមទៀត ប៉ុន្តែជាទូទៅ មិនអាចធ្វើដូច្នេះបានទេ ព្រោះមានការវាយប្រយុទ្ធគ្នាខ្លាំងណាស់ និងមានមីនបង្កប់ក្នុងដីច្រើន ។ ចំពោះភូមិផ្សេងទៀត អ្នកដឹកនាំនៅមូលដ្ឋាន និងទាហាន បានដាក់កំហិតលើការដើរហើររបស់អ្នកភូមិ នៅក្នុងតំបន់ដែលទាហានខ្មែរក្រហមអាចធ្វើបាប រឺអូសទាញពួកគេ ។ ផ្ទុយទៅវិញ នៅភូមិបាបោង អ្នកភូមិបានរានដីបន្ថែមតាំងពីដើមឆ្នាំ១៩៨០ មកម្ល៉េះ ។

អំណោយផលភូមិសាស្ត្រ ដូចជា ដីមានជីជាតិ និងទីតាំង ក៏អាចកំណត់ពីកំរិតដែលគ្រួសារអាចប្រមូលបង្គរទ្រព្យសម្បត្តិមានផលិតភាព និងធ្វើចំរុះកម្មប្រភពចំណូលដែរ ។ ឧទាហរណ៍ នៅភូមិខ្សាច់ជីរស់ ដីដាំដុះមានគុណភាពអន់ណាស់ ដូច្នេះផលិតកម្មជារួមទទួលបានទិន្នផលតិច ។ កត្តានេះបានពន្យឺតដំណើរការរបស់សហគមន៍ និងចលនាឈានឡើងនៃជីវភាពគ្រួសារនានា ។ នៅភូមិក្រសាំង ជម្លោះតាមផ្លូវអាវុធ ក៏បានប៉ះពាល់ដល់ការធ្វើស្រែចំការដែរ ប៉ុន្តែមិនធ្ងន់ធ្ងរដូចនៅភូមិខ្សាច់ជីរស់ទេ ។ ដីមានជីជាតិ ធ្វើអោយប្រជាជនទទួលបានទិន្នផលប្រសើរអំពីដីអាចដាំដុះបាន ។ ប្រជាជនក៏មានទំនាក់ទំនងល្អជាមួយទីផ្សារ ដែលជួយពួកគេអោយធ្វើជំនួញបានខ្លះដែរ ។ ដូចនេះ ដីមានគុណភាព និងទីតាំងល្អ អាចសំរាលបានខ្លះនូវផលប៉ះពាល់នៃជម្លោះតាមផ្លូវអាវុធ ជួយជំរុញសហគមន៍ អោយមានដំណើរការកាន់តែប្រសើរ និងធ្វើអោយគ្រួសារអ្នកមានទ្រព្យធនអាចប្រមូលបង្គរទ្រព្យ សម្បត្តិបានកាន់តែច្រើន (ដូចជា គោយន្ត) សំរាប់ធ្វើប្រពលវប្បកម្មកសិកម្ម និងបង្កើនផលិតភាព ។

នៅតាមភូមិមួយចំនួន កាលៈទេសៈនៃការបញ្ចប់ជម្លោះតាមផ្លូវអាវុធ ក៏សំខាន់ណាស់ដែរសំរាប់ការទទួលបានដីធ្លី ។នៅភូមិអណ្តូងត្រាចដែលជាភូមិស្ថិតក្នុងតំបន់បែតង និងមានដំណើរការខ្លាំង មានប្រជាជនភៀសខ្លួនជាង ១០០គ្រួសារ បានមកតាំងទីលំនៅក្នុងឆ្នាំ១៩៩២ ។ជនមាតុភូមិនិវត្តន៍ស្ទើរតែទាំងអស់នៅពេលមកដល់មានជីវភាពក្រីក្រ ព្រោះគ្មានដីធ្លី និងមានធនធានហិរញ្ញវត្ថុតិចតួច ។ នៅឆ្នាំ១៩៩៤ ព្រៃលិចទឹកដែលកាលពីមុនចេញចូលមិនបាន ព្រោះមានកងទ័ពខ្មែរក្រហម ត្រូវបានបែងចែកទៅអោយជនមាតុភូមិនិវត្តន៍ ដោយគ្រួសារនីមួយៗទទួលបានដីប្រហែលមួយហិកតា ។ ប៉ុន្តែគ្រួសារជាច្រើនពុំមានធនធានហិរញ្ញវត្ថុ រឺមនុស្ស ដើម្បីរានដីទាំងនោះទេ ហើយក៏បានចាកចេញពីភូមិទៅវិញ ។

### ៣.២. ពេលបញ្ចប់ជម្លោះ

ពេលបញ្ចប់ការវាយប្រយុទ្ធគ្នា ក៏ជះឥទ្ធិពលខ្លាំងទៅលើសុខុមាលភាពរបស់សហគមន៍ និងចលនាឈានឡើងនៃជីវភាពគ្រួសារនានាដែរ ។ ទី១ ពេលវេលាបញ្ចប់ជម្លោះ វាជាប់ពាក់ព័ន្ធដល់សន្តិសុខសាធារណៈ ។ អ្នកភូមិស្ទើរតែគ្រប់គ្នាបានរាយការណ៍ពីបញ្ហាចោរកម្ម ជាពិសេសក្នុងអំឡុងពេលអន្តរកាលរវាងជម្លោះ និងសន្តិភាព ។ ភូមិនៅតំបន់បែតងមួយចំនួនបានរាយការណ៍ថា ចោរលួច និងចោរប្លន់ ហាក់ដូចបានកើនឡើងចាប់ពីដើមដល់ពាក់កណ្តាលទសវត្សរ៍១៩៩០ គឺព្រមគ្នានឹងអំឡុងពេលអ៊ុនតាក់ ។ ចំពោះភូមិនៅតំបន់ក្រហមវិញ ចោរលួច និងចោរប្លន់ ឃើញមានពាសពេញនៅអំឡុងពេលវាយប្រយុទ្ធគ្នា ហើយក្នុងករណីខ្លះៗបានរាលដាលកាន់តែខ្លាំង បន្ទាប់ពីការវាយប្រយុទ្ធបានបញ្ចប់ ។

ឧទាហរណ៍ ពួកអង្គភាពខ្មែរក្រហមបានមកបោះទីតាំងក្នុងតំបន់ព្រៃក្បែរភូមិខ្សាច់ជីរស់ ហើយបានធ្វើប្រតិបត្តិការសឹកចេញពីទីនោះ ។ ក្រោយពេលមានអង្គភាពជាច្រើនបានចុះចូលជាមួយនឹងរដ្ឋាភិបាល អង្គភាពដែលនៅសេសសល់ក្នុងព្រៃ ក៏ក្លាយជាចោរប្លន់ ។ ករណីជាក់ស្តែងមួយ គឺនៅភូមិកញ្ជរដែលមានការប្រយុទ្ធគ្នាខ្លាំង ចាប់ពីដើមដល់ពាក់កណ្តាលទសវត្សរ៍១៩៩០ ។ នៅពាក់កណ្តាលទសវត្សរ៍១៩៩០ អង្គភាពខ្មែរក្រហមមួយចំនួន បានចុះចូលជាមួយនឹងរដ្ឋាភិបាល ប៉ុន្តែអង្គភាពឯទៀតនៅបន្តការប្រយុទ្ធ ហើយក្រោយមកក៏ក្លាយជាចោរប្លន់ ។ ដូច្នេះ លំនាំនៃការបញ្ចប់ជម្លោះក្នុងភូមិតំបន់ក្រហម មិនមែនសុទ្ធតែការវាយប្រយុទ្ធគ្នាបានបញ្ចប់ភ្លាម រួចសន្តិភាព ក៏កើតឡើងភ្លាមៗនោះទេ ។ ផ្ទុយទៅវិញ ជម្លោះតាមតំបន់ជាក់លាក់ខ្លះបានក្លាយជាបញ្ហាសន្តិសុខ ដូចជាមានចោរប្លន់ ដែលអាចជះឥទ្ធិពលដល់សមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការរានយកដីថ្មី និងធ្វើពាណិជ្ជកម្ម ។

កត្តាទី ២ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅខាងក្រៅក្រោយពេលការវាយប្រយុទ្ធបានបញ្ចប់ ដូចជា គ្រោះទឹកជំនន់ និង រាំងស្ងួត និងសម្បទានព្រៃឈើ ។ ភូមិទាំង ៩ ធ្លាប់រងគ្រោះដោយសារទឹកជំនន់ និងការរាំងស្ងួតនៅអំឡុងពាក់កណ្តាលទី២ នៃការសិក្សា ។ ទោះយ៉ាងនេះក្តី គ្រួសារនៅភូមិបាបោង និងអណ្តូងត្រាច បន្ទាប់ពីជម្លោះក្នុងតំបន់នោះចប់អស់ ពួកគេនៅមានពេលគ្រប់គ្រាន់ដើម្បីប្រមូលទ្រព្យធនមានផលិតភាព និងធ្វើចំរុះកម្មប្រភពចំណូល ដែលអាចអោយអ្នកភូមិទប់ទល់បាននឹងផលប៉ះពាល់អវិជ្ជមានពីគ្រោះទឹកជំនន់/រាំងស្ងួតបាន ។ ចំពោះភូមិខ្សាច់ជីរស់ និងដងក្តារ ចន្លោះពេលរវាងការបញ្ចប់ជម្លោះ និងការកើតមានគ្រោះរាំងស្ងួត គឺមានរយៈពេលខ្លីណាស់ ។ គ្រួសារនៅភូមិទាំងពីរពុំមានពេលគ្រប់គ្រាន់ ដើម្បីប្រមូលទ្រព្យមានផលិតភាព ពង្រីកដីធ្លី និងអភិវឌ្ឍហេដ្ឋា

តារាង ២: អន្តរាគមន៍អភិវឌ្ឍន៍ តាមប្រភេទនៃជម្លោះ ពីឆ្នាំ១៩៩២-២០០៤/០៥

| | ភូមិតំបន់បៃតង | | | | | ភូមិតំបន់ក្រហម | | | |
|---|---|---|---|---|---|---|---|---|---|
| វិស័យ | បាបោង* | ព្រៃកក្អែង | អណ្ដូងត្រាច | ត្រពាំងព្រីយ៍ | កំពង់ត្នោត | ក្រសាំង* | កញ្ជូរ | ដងក្ដារ | ខ្សាច់ជីរស់ |
| កសិកម្ម | ៦ | - | ៥ | - | - | ៣ | - | - | ២ |
| ឥណទាន | ៤ | - | ៣ | ២ | ៤ | ៤ | - | - | ១ |
| ការថែទាំសុខភាព | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | - |
| ទឹកស្អាត | ៣ | ១ | ៣ | - | - | ១ | - | - | - |
| ផ្លូវថ្នល់ | - | - | ២ | ១ | ១ | ៣ | - | ១ | - |
| ការអប់រំ | - | ១ | ២ | ១ | ១ | - | - | ១ | ១ |
| សរុប | ១៤ | ៣ | ១៦ | ៥ | ៧ | ១៤ | ១ | ៣ | ៤ |

** បង្ហាញពីភូមិមានដំណើរការខ្លាំង*

រចនាសម្ព័ន្ធមុនពេលមានគ្រោះរាំងស្ងួតបាននោះទេ ។ ជាលទ្ធផល សុខុមាលភាពជារួមនៅក្នុងភូមិ នៅតែដដែល រឺធ្លាក់ចុះ ទោះបីមានគ្រួសារមួយចំនួនអាចទទួលបានផលចំណេញខ្លះក្ដី ។ នៅឯភូមិក្រសាំង និងកញ្ជូរវិញ ដីមានជីជាតិគឺមានច្រើនជាង ដូច្នេះក៏ជួយឱ្យអ្នកភូមិអាចទប់ទល់នឹងផលប៉ះពាល់នៃការវាយប្រយុទ្ធគ្នាយ៉ាងយូរ និងជួយអោយភូមិមានដំណើរការប្រសើរឡើងដែរ ។

ភូមិជាច្រើនក៏ទទួលផលពីកំណែលំអការបានប្រើធនធានធម្មជាតិ ដែលធ្វើអោយអ្នកភូមិអាចពង្រីកដីកសិកម្ម និង/រឺប្រមូលផលឈើនិងផលិតផលព្រៃផ្សេងទៀត រឺនេសាទត្រី កាន់តែចំហជាងមុន ។ ផ្ទុយទៅវិញ នៅតាម តំបន់ដូចជាភូមិដងក្ដារ សម្បទានិកព្រៃឈើបានកាន់កាប់ត្រួតត្រាដីព្រៃក្បែរនោះរួចទៅហើយនៅពេលភូមិទទួលបានសន្តិភាព ។ ដូចនេះ កំហិតលើការចូលទៅកាន់តំបន់ព្រៃ គឺមានរួចជាស្រេច ដែលបានកាត់បន្ថយលទ្ធភាពអ្នកភូមិក្នុងការកាប់រានដីព្រៃ រឺប្រមូលអនុផលពីព្រៃ ។ សរុបមក កំហិតបង្កឡើងដោយសារការវាយប្រយុទ្ធគ្នា គឺបានជំនួសដោយកំហិតបង្កឡើងដោយសម្បទានិកទៅវិញ ។ ចំណុចខុសគ្នាគួរកត់សំគាល់បំផុតគឺ ប្រជាជនមួយចំនួនអាចទទួលបានការងារពលកម្មស៊ីប្រាក់ឈ្នួលពីសម្បទានិក រឺឯអ្នកខ្លះទៀតដើរតួជា ភ្នាក់ងារដើរប្រមូលកំលាំងពលកម្ម ។

## ៣.៣. ជំនួយអភិវឌ្ឍន៍

បើមើលតែមួយភ្លែត កំរិតនៃជម្លោះហាក់ដូចមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងចំនួនអន្តរាគមន៍អភិវឌ្ឍន៍ ។[៣] តារាង ២ បង្ហាញថា នៅអំឡុងពេលសិក្សាក្នុងចំណោម ៤ភូមិនៅតំបន់ក្រហម មាន ៣ភូមិបានទទួលអន្តរាគមន៍អភិវឌ្ឍន៍តិចតួច រឺឯភូមិមួយនៅតំបន់បៃតងបានទទួលអន្តរាគមន៍អភិវឌ្ឍន៍ច្រើនជាងគេបំផុត ។ ទោះយ៉ាងនេះក្ដី កំរិតនៃជម្លោះនៅតំបន់ណាមួយ និងពេលបញ្ចប់ជម្លោះ មិនមែនសុទ្ធតែអាចបង្ហាញឱ្យដឹងពីកំរិត និងប្រភេទនៃជំនួយអភិវឌ្ឍន៍នោះទេ ។ ឧទាហរណ៍ ភូមិក្រសាំងដែលស្ថិតក្នុងតំបន់ក្រហម កន្លងមកបានទទួលអន្តរាគមន៍អភិវឌ្ឍន៍ច្រើនជាងគេបំផុត រឺឯភូមិកំពង់ត្នោតដែលស្ថិតនៅតំបន់បៃតង គឺមានតួលេខអន្តរាគមន៍កំរិតទាបជាងគេបំផុតទៅវិញ ។

វិសាលភាព និងទំហំនៃជម្លោះតាមផ្លូវអាវុធ និងពេលបញ្ចប់ជម្លោះ ពិតជាមានផលប៉ះពាល់ខ្លាំងទៅលើចំនួន និងប្រភេទនៃអន្តរាគមន៍អភិវឌ្ឍន៍នៅតាមភូមិខ្លះ ។ ភូមិបាបោង ដែលមានសន្តិភាព និងស្ថិរភាព តាំងពីដើមទសវត្សរ៍១៩៨០ មក បានទទួលអន្តរាគមន៍អភិវឌ្ឍន៍មួយចំនួនពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទ្រទ្រង់ផលិតកម្មកសិកម្ម និងសុខភាពសាធារណៈ ។ ក្រុមគ្រួសារមួយចំនួននៅភូមិក្រសាំង ក៏ហាក់ដូចបានទទួលផលដោយប្រយោលខ្លះៗពីជំនួយស្រដៀងគ្នានេះ ដែលបានផ្ដល់ទៅឱ្យភូមិនៅក្បែរនោះ ដែលមាន ៨០គ្រួសារមាតុភូមិនិវត្តន៍បានមកតាំងទីលំនៅ ។ ភូមិនោះបានទទួលជំនួយអភិវឌ្ឍន៍នៅចុងទសវត្សរ៍១៩៨០ ពីកម្មវិធីមួយរបស់រដ្ឋាភិបាល និងពីសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ។ ជាក់ស្ដែងនៅភូមិអណ្ដូងត្រាច ដែលជាភូមិមានដំណើរការខ្លាំងទី៣ គឺមានជំនួយអភិវឌ្ឍន៍ និងសាងសង់ឡើងវិញ បានផ្ដល់អោយប្រជាជន ប្រហែល ១០០គ្រួសារ ដែលធ្វើមាតុភូមិនិវត្តន៍មកពីជំរំជនភៀសខ្លួននៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ។

ភូមិមានដំណើរការខ្លាំងទាំង៣ សុទ្ធតែបានទទួលផលពីជំនួយដែលផ្ដោតចំគោលដៅ ។ នៅភូមិបាបោងដែលពុំមានជម្លោះ រដ្ឋាភិបាលអាចធ្វើអន្តរាគមន៍អភិវឌ្ឍន៍តាំងពីដំបូងៗបាន ហើយនៅភូមិអណ្ដូងត្រាច (និងភូមិក្រសាំងខ្លះដែរ) គឺមានអន្តរាគមន៍អភិវឌ្ឍន៍ជួយដល់ប្រជាជនដែលវិលមកពីជំរំជនភៀសខ្លួនក្រោយពេលមានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងសន្តិភាព ។ ក្នុងករណីនេះជំនួយអភិវឌ្ឍន៍ហាក់ដូចមានសព្វគ្រប់ជាង សំរាប់ជួយទ្រទ្រង់ ផលិតកម្មកសិកម្ម និងសេវាសង្គម ដោយមានដូចជា ការសាងសង់ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ (លើកលែងនៅ ភូមិអណ្ដូងត្រាច) សេវាឥណទាន ការផ្គត់ផ្គង់ទឹកស្អាត ជាពិសេស

៣ ចំនួនអន្តរាគមន៍អភិវឌ្ឍន៍ មិនបានឆ្លុះបញ្ចាំងពី វិសាលភាព និងទំហំនៃជំនួយបែបនោះទេ ដូច្នេះហើយបង្ហាញបានត្រឹមតែប្រហាក់ប្រហែលប៉ុណ្ណោះ ពីផលប៉ះពាល់សក្ដានុពលជាទូទៅនៃជំនួយ ។

សេវាថែទាំសុខភាព និងសាលារៀន ។

វិសាលភាព និងទំហំនៃជម្លោះតាមផ្លូវអាវុធ គួបផ្សំនឹងកត្តាទីតាំងនិងការទទួលបានជំនួយផ្សេងៗ បានរារាំងអន្តរាគមន៍អភិវឌ្ឍន៍ នៅឯ ៣ភូមិតំបន់ក្រហមផ្សេងទៀត ហើយអាចជួយពន្យល់ពីមូលហេតុដែលភូមិខ្សាច់ជីរស់ និងភូមិដងក្តារក្នុងចំណោមភូមិទាំងបីខាងលើ បានក្លាយជាភូមិដំណើរការខ្សោយ ។ ភូមិទាំងពីរនេះ ទទួលបានជំនួយតិចតួច ឬគ្មានសោះ សំរាប់ផលិតកម្មកសិកម្ម និងស្ទើរតែគ្មានជំនួយសោះសំរាប់ហេដ្ឋារចនាសម្ព័ន្ធ និងសុខភាពសាធារណៈ ។ ដូចគ្នានេះដែរ នៅភូមិកញ្ជរសឹងតែគ្មានអន្តរាគមន៍ជំនួយអភិវឌ្ឍន៍សោះ ព្រោះវាស្ថិតនៅដាច់ស្រយាល និងមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា ។

ភូមិនៅតំបន់បៃតងមួយចំនួន ក៏មិនបានទទួលអន្តរាគមន៍អភិវឌ្ឍន៍អ្វីច្រើនដែរ ដូចជា ភូមិកំពង់ត្នោតដែលមានដំណើរការខ្សោយ ព្រមទាំងភូមិព្រៃកក្អេង និងភូមិត្រពាំងព្រីយ៍ ដែលមានដំណើរការបង្គួរ ។ នៅភូមិទាំងបីនេះ ទីតាំងប្រហែលជាកត្តាសំខាន់ក្នុងការកំណត់ពីកំរិតជំនួយ ។ កត្តាមួយទៀតអាចមកពីភូមិទាំងនោះមិនស្ថិតក្នុង តំបន់គោលដៅរបស់សហគមន៍អភិវឌ្ឍន៍ ឬក៏មិនបានបំពេញលក្ខខណ្ឌសំរាប់ទទួលជំនួយ ។ នៅភូមិព្រៃកក្អេង ជំនួយអភិវឌ្ឍន៍ស្ទើរតែទទួលបានដោយចៃដន្យ នៅពេលដែលវិទ្យាស្ថាន CDRI បានផ្គត់ផ្គង់អណ្តូងទឹកស្អាតមួយចំនួន បន្ទាប់ពីបានចុះស្រាវជ្រាវនៅភូមិនោះ ។

### ៣.៤. ទីតាំង និងផ្លូវទាក់ទង

ទីតាំង និងការដឹកជញ្ជូន ជះឥទ្ធិពលដល់ ជំនួញ ច្រកទាក់ទងទីផ្សារ វត្តមានសេវាសង្គម ព្រមទាំងចំនួននិងប្រភេទជំនួយអភិវឌ្ឍន៍ ។ នៅភូមិបាបោងដែលស្ថិតក្នុងតំបន់បៃតង ផ្លូវចេញចូលមិនសូវល្អទេនៅទសវត្សរ៍១៩៩០ ប៉ុន្តែពុំមានបញ្ហាសន្តិសុខរាំងស្ទះឡើយ ហើយកសិករនៅតែអាចដឹកផលិតផលទៅកាន់ទីផ្សារជិតៗនោះបាន ។ ទីតាំងនិងស្ថានភាពអំណោយផលខាងកសិ-សេដ្ឋកិច្ច ព្រមទាំងសន្តិសុខនិងស្ថិរភាព បានធ្វើឱ្យភូមិនេះមានលក្ខណៈ ទាក់ទាញដល់ទុនវិនិយោគអភិវឌ្ឍន៍ ។ ផ្ទុយទៅវិញ ច្រកទាក់ទងនឹងទីតាំងមិនល្អ ធ្វើឱ្យភូមិនៅតំបន់បៃតង ផ្សេងទៀត ពុំអាចទាញយកចំណេញពីអវត្តមានជម្លោះ ។ ជាក់ស្តែងនៅភូមិកំពង់ត្នោត និងព្រៃកក្អេង ស្ថានភាពផ្លូវអន់ បានរាំងស្ទះដល់ទំនាក់ទំនងទីផ្សារ និងជំនួយអភិវឌ្ឍន៍នៅភូមិទាំងពីរនេះ ។

ទំនាក់ទំនងផ្ទាល់រវាងទីតាំង ការទទួលបានជំនួយផ្សេងៗ និងជម្លោះតាមផ្លូវអាវុធ អាចពិនិត្យឃើញនៅក្នុង ២ ភូមិតំបន់ក្រហម ដែលមានដំណើរការខ្សោយ គឺភូមិខ្សាច់ជីរស់ និងដងក្តារ ហើយនិងនៅភូមិតំបន់ក្រហមមានដំណើរការបង្គួរមួយ គឺភូមិកញ្ជរ ។ នៅភូមិទាំងបីនេះ កងទ័ពខ្មែរក្រហម បានបោះទីតាំងនៅក្នុងព្រៃជ្រៅដែលពិបាកចូលដល់ ដើម្បីគេចពីកងទ័ពរដ្ឋាភិបាល ។ ចំពោះភូមិខ្សាច់ជីរស់វិញ ច្រកទំនាក់ទំនងទៅកាន់ទីផ្សារឆ្ងាយៗ ត្រូវរាំងស្ទះដោយសារជម្លោះ អំពើចោរកម្ម និងកង្វះផ្លូវចេញចូល ។ ករណីនេះក៏កើតមានដូចគ្នាផងដែរចំពោះភូមិដងក្តារ និងកញ្ជរ ។

ជម្លោះតាមផ្លូវអាវុធ ក៏ប៉ះពាល់ផងដែរដល់ការធ្វើដំណើរចេញចូលទៅភូមិនៅតំបន់ក្រហម ដោយបានពន្យឺត ការកសាងផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ដែលប៉ះពាល់មិនល្អដល់ជំនួយដទៃទៀត ។ នៅភូមិដងក្តារ និងកញ្ជរ ផ្លូវថ្នល់ដែលតភ្ជាប់ពីភូមិទៅកាន់មជ្ឈមណ្ឌលរដ្ឋបាលនិងពាណិជ្ជកម្ម មិនទាន់កសាងទេរហូតដល់ឆ្នាំ២០០២ ។ ពិតមែនតែជំនួយមានតិចតួច ហើយផ្លូវថ្នល់បានកសាងរួចរាល់ក្តី ប៉ុន្តែផ្លូវថ្នល់សំខាន់ណាស់ក្នុងការ តភ្ជាប់ភូមិទៅនឹងទីផ្សារនៅក្នុងមូលដ្ឋាន និងបើកទ្វារទទួលសកម្មភាពផ្សេងៗ ។ នៅពេលមានផ្លូវហើយ គេត្រូវ ចំណាយពេលច្រើនទៀតដើម្បីធ្វើផែនការ និងប្រមូលធនធាន មុននឹងអាចអនុវត្តគំរោងអភិវឌ្ឍន៍ផ្សេងៗទៀត ។

## ៤. សេចក្តីសន្និដ្ឋាន

សន្តិភាព និងស្ថិរភាព ជាកត្តាជួយអោយភូមិមួយចំនួនមានដំណើរការល្អពីមួយឆ្នាំទៅមួយឆ្នាំ បើសិនមានលក្ខខណ្ឌអំណោយផល ដូចជា ដីមានជីជាតិ ច្រកទាក់ទងល្អ ទៅទីផ្សារ និងជំនួយឧបត្ថម្ភច្រើនគួរសមសំរាប់ការអភិវឌ្ឍសង្គម និងកសិកម្ម ។ គ្រួសារនានាអាចផ្តោតកំលាំងលើការប្រមូលបង្គរទ្រព្យសកម្ម ដែលជួយឱ្យពួកគេ អាចទប់ទល់នឹងគ្រោះរាំងស្ងួត/ទឹកជំនន់នាពេលអនាគត ។ ចំពោះភូមិផ្សេងទៀត ទីតាំងល្អ ដីមានជីជាតិ ព្រមទាំងមានជំនួយអភិវឌ្ឍន៍ច្រើន បានជួយកាត់បន្ថយផលប៉ះពាល់ពីជម្លោះរ៉ាំរ៉ៃក្នុងតំបន់ ។ ទោះបីជម្លោះដែលកំពុងកើតមាន បានកាត់បន្ថយលទ្ធភាពគ្រួសារភាគច្រើន ក្នុងការកាប់រាននិងធ្វើកសិកម្មលើដីបន្ថែមក្តី ប៉ុន្តែដីមានជីជាតិ និងទីតាំងងាយស្រួលទាក់ទងជួយអោយគ្រួសារទាំងនោះអាចផលិត និងលក់ដូរផលិតផល បានច្រើនជាងភូមិឯទៀត ក្នុងអំឡុងពេលមានការប្រយុទ្ធគ្នា ហើយពួកគេក៏អាចទប់ទល់នឹងការប៉ះទង្គិចផ្សេងៗ ជាយថាហេតុ ។

នៅពេលជម្លោះតាមផ្លូវអាវុធ គួបផ្សំជាមួយនឹងកាលៈទេសៈមិនអំណោយផលទៀតនោះ សុខុមាលភាពសហគមន៍ និងការឈានឡើងនៃគ្រួសារនានា គឺពិបាកនឹងសំរេចបានណាស់ ។ នៅតាមភូមិបែបនេះ ជម្លោះរ៉ាំរ៉ៃនិងអំពើចោរកម្ម បានកាត់បន្ថយសមត្ថភាពពង្រីកដីកាន់កាប់ និងធ្វើឱ្យប្រជាជនជួបការលំបាកកាន់តែខ្លាំងលើបញ្ហាដីគ្មានជីជាតិ ព្រមទាំងកង្វះទីផ្សារ ធនធានធម្មជាតិ និងជំនួយអភិវឌ្ឍន៍ ។ កត្តាទាំងនេះបានដាក់កំហិតដល់ផលិតកម្មកសិកម្ម សមត្ថភាពប្រមូលបង្គរទ្រព្យសកម្ម និងការធ្វើចំរុះកម្មប្រភពចំណូល ហើយធ្វើឱ្យចុះខ្សោយសមត្ថភាពទប់ទល់នឹងគ្រោះរាំងស្ងួត/ទឹកជំនន់ ដែលកើតមានភ្លាមៗ ក្រោយពេលបញ្ចប់សង្គ្រាម ។ ដោយសារភូមិទាំងនេះនៅដាច់ស្រយាល និងមានច្រកចេញចូលពិបាក ដូច្នេះភូមិក៏ទទួលបានជំនួយអភិវឌ្ឍន៍ តិចជាងគេទៀត ។

នៅពេលភូមិទទួលបានសន្តិភាព កិច្ចប្រឹងប្រែងរួមគ្នាដើម្បីកាត់បន្ថយភាពក្រីក្រ ត្រូវមានកំណត់ច្បាស់ពីទិសដៅ និងលំដាប់លំដោយនៃអន្តរាគមន៍អភិវឌ្ឍន៍ផ្សេងៗ ដើម្បីលើកស្ទួយចលនាឈានឡើងនៃជីវភាពគ្រួសារនានា និងសុខុមាលភាពរបស់សហគមន៍ ។ ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជន នឹងត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងការកែលំអផលិតភាព និងច្រកទាក់ទងទីផ្សារ ។ វិស័យនីមួយៗតែងមានឧត្តមភាពប្រៀបធៀបមួយចំនួន ដូច្នេះត្រូវមានការសម្របសម្រួលដើម្បីធានាថា អន្តរាគមន៍អភិវឌ្ឍន៍នានាវាបំពេញឱ្យគ្នាទៅវិញទៅមក ៕

# សន្តិសុខសង្គម និងគោលនយោបាយសង្គមនៅកម្ពុជា

*រៀបរៀងដោយ លោក ជា ចាន់ទុំ និង បណ្ឌិត Hildegard Lingnau*[1]

## ១. សិទ្ធិចំពោះសន្តិសុខសង្គម

សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៤៨) បានចែងក្នុងមាត្រា២២ ថា "ជនគ្រប់រូប... មានសិទ្ធិទទួលបាន សន្តិសុខសង្គម" និង ក្នុងមាត្រា២៥ ថា "មានសិទ្ធិទទួលបានសន្តិសុខក្នុងគ្រា គ្មានការងារធ្វើ មានជំងឺ ពិការភាព ភាពពោះម៉ាយ/មេម៉ាយ ជរាភាព ឬ កង្វះលទ្ធភាពចិញ្ចឹមជីវិត ដោយសារកាលៈទេសៈដែលស្ថិតនៅក្រៅ សមត្ថភាពគ្រប់គ្រងរបស់ពួកគេ" ។

សិទ្ធិទទួលបានសន្តិសុខសង្គម ត្រូវបានដាក់បញ្ចូលជាបន្តបន្ទាប់នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួន ជាពិសេសក្នុង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ (International Covenant on Economic, Social and Cultural Rights: ICESCR) ។ មាត្រា៩ នៃអនុសញ្ញា ICESCR ចែងថា "ជនគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខសង្គម ក្នុងនេះមានទាំង ការធានារ៉ាប់រងសង្គមផង" ។

យោងតាមគណៈកម្មាធិការខាងសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៃ ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ច នៃអង្គការសហប្រជាជាតិ (Committee on Economic, Social and Cultural Rights of the UN Economic and Social Council) សិទ្ធិទទួលបានសន្តិសុខសង្គម រាប់បញ្ចូលទាំង សិទ្ធិក្នុងការទទួលបាន និងរក្សាទុកអត្ថប្រយោជន៍ដោយគ្មានការរើសអើង ដើម្បីធានាបាននូវការគាំពារទាក់ទិននឹង:

- កង្វះខាតចំនួលពីការងារ ដោយសារមាន ជំងឺ ពិការភាព មាតុភាព របួសក្នុងពេលបំពេញការងារ ភាពគ្មានការងារធ្វើ ជរាភាព រឺ មរណភាពនៃសមាជិកគ្រួសារ ។
- ការថែទាំសុខភាពមានថ្លៃខ្ពស់ហួសលទ្ធភាព ។
- ការផ្គត់ផ្គង់គ្រួសារមិនបានគ្រប់គ្រាន់ ជាពិសេសសំរាប់កុមារ និងមនុស្សពេញវ័យក្នុងបន្ទុក ។

ក្រៅពីគ្រោងការជួយខ្លួនឯង និងគំរោងដំណើរការដោយឯកជន នៅមានវិធានការជាច្រើនទៀត ដែលត្រូវប្រើដើម្បីផ្តល់នូវ អត្ថប្រយោជន៍ជាសន្តិសុខសង្គមសំខាន់ៗដូចជា:

- គ្រោងការគ្មានការចូលរួមវិភាគទាន រឺគ្រោងការផ្អែកលើការធានារ៉ាប់រង (ដូចជា ការធានារ៉ាប់រងសង្គម) ដែលជាទូទៅត្រូវមានការចូលរួមជាកាតព្វកិច្ចពីសំណាក់អ្នកទទួលផល និយោជក និង ពេលខ្លះពីរដ្ឋទៀតផង ។
- គ្រោងការគ្មានការចូលរួមវិភាគទានសំរាប់ផ្តល់ជំនួយសង្គមជាទូទៅ រឺផ្តោតចំគោលដៅ ។

សមាសធាតុផ្សេងៗនៃសិទ្ធិទទួលបានសន្តិសុខសង្គមប្រែប្រួលខុសគ្នាទៅតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង ប៉ុន្តែគួរមាន ៩ផ្នែកសំខាន់ៗ ពោលគឺ ការថែទាំសុខភាព ការឈឺថ្កាត់ ជរាភាព ភាពគ្មានការងារធ្វើ របួសនៅពេលបំពេញការងារ ការផ្គត់ផ្គង់គ្រួសារនិងកុមារ មាតុភាព ពិការភាព អ្នករួចរស់ជីវិត និង កុមារកំព្រា (*ibid: 5*) ។

រដ្ឋទាំងអស់មានកាតព្វកិច្ចស្នូលមួយក្នុងការធានាអនុវត្តឱ្យបាននូវសិទ្ធិទទួលបានសន្តិសុខសង្គមមួយចំនួន ដែលចាំបាច់ៗ បំផុត (*ibid: 16*) ។ កាតព្វកិច្ចនេះតំរូវអោយរដ្ឋ :

- ធានាលទ្ធភាពបានប្រើប្រាស់គ្រោងការសន្តិសុខសង្គម ដែលផ្តល់អត្ថប្រយោជន៍ក្នុងកំរិតអប្បបរមាមួយដល់ បុគ្គលគ្រប់រូប និងក្រុមគ្រួសារ ធ្វើឱ្យពួកគេអាចទទួលបានយ៉ាងហោចណាស់ ការថែទាំសុខភាពដ៏ចាំបាច់ ទីជំរក អនាម័យ ទឹកស្អាត ម្ហូបអាហារ និងការអប់រំជាមូលដ្ឋានដ៏ចាំបាច់មួយ ។
- ធានានូវសិទ្ធិទទួលបានសន្តិសុខសង្គមដោយគ្មានការរើសអើង ជាពិសេសសំរាប់បុគ្គល/ក្រុម ដែលងាយទទួលរងគ្រោះ និងមានឋានៈអន់ខ្សោយ ។
- ការពារគ្រោងការសន្តិសុខសង្គមដែលមានស្រាប់ ទប់ទល់នឹងការជ្រៀតជ្រែកមិនសមហេតុផល ។
- អនុម័ត និងអនុវត្ត យុទ្ធសាស្ត្រសន្តិសុខសង្គម និងផែនការសកម្មភាពរបស់ជាតិមួយ ។
- ចាត់វិធានការជាជំហានៗនិងផ្តោតចំគោលដៅ ដើម្បីអនុវត្តគ្រោងការសន្តិសុខសង្គម ជាពិសេសគ្រោងការ សំដៅការពារក្រុម/ជន ងាយទទួលរងគ្រោះ និងមានឋានៈអន់ខ្សោយ ។
- តាមដានទំហំលទ្ធផលសំរេចបាន ក្នុងការអនុវត្តសិទ្ធិទទួលបានសន្តិសុខសង្គម ។

ក្នុងគោលគំនិតទាន់សម័យពីច្បាប់សិទ្ធិមនុស្ស គេឃើញមាន កាតព្វកិច្ចចំនួន ៣ គឺ (*ibid: 13ff*):

- ***កាតព្វកិច្ចគោរព*** ដែលតំរូវអោយរដ្ឋជៀសវាងចូលជ្រៀតជ្រែកដោយផ្ទាល់ រឺដោយប្រយោល ទៅក្នុងការប្រើប្រាស់សិទ្ធិទទួលបានសន្តិសុខសង្គម ។
- ***កាតព្វកិច្ចការពារ*** តំរូវអោយរដ្ឋទប់ស្កាត់កុំអោយមានជនទីបីចូលជ្រៀតជ្រែកតាមមធ្យោបាយបែបណាមួយ ទៅក្នុងការប្រើសិទ្ធិទទួលបានសន្តិសុខសង្គម ។
- ***កាតព្វកិច្ចបំពេញឱ្យបាន*** តំរូវអោយរដ្ឋចាត់វិធានការចាំបាច់ផ្សេងៗ ដូចជាការអនុវត្តគ្រោងការសន្តិសុខសង្គម ជាដើម ដែលសំដៅញ៉ាំងឱ្យមានការអនុវត្តយ៉ាងពេញលេញនូវសិទ្ធិទទួលបានសន្តិសុខសង្គម ។

កាតព្វកិច្ចបំពេញឱ្យបាន អាចបែងចែកជា កាតព្វកិច្ចជួយសំរួល កាតព្វកិច្ចជំរុញ និងកាតព្វកិច្ចផ្គត់ផ្គង់:

- ***កាតព្វកិច្ចជួយសំរួល*** តំរូវអោយរដ្ឋចាត់វិធានការវិជ្ជមានផ្សេងៗ ដើម្បីជួយដល់បុគ្គល និងសហគមន៍ អោយបាន ប្រើសិទ្ធិទទួលបានសន្តិសុខសង្គម (ការទទួលស្គាល់សិទ្ធិក្នុងប្រព័ន្ធច្បាប់និងនយោបាយជាតិ ការអនុម័តយុទ្ធសាស្ត្រជាតិសំរាប់សន្តិសុខសង្គម និង ផែនការសកម្មភាពជាតិសំរាប់សន្តិសុខសង្គម ជាដើម) ។
- ***កាតព្វកិច្ចជំរុញ*** តំរូវអោយរដ្ឋអនុវត្តជំហាននានា ដើម្បីធានាឱ្យមានការ

[1] លោក ជា ចាន់ទុំ ជាប្រធាននាយកដ្ឋានផែនការសង្គមកិច្ច ហើយបណ្ឌិត Hildegard Lingnau ជាទីប្រឹក្សាជាន់ខ្ពស់នៃក្រសួងផែនការ ។ អ្នកនិពន្ធ សូមអរគុណ លោក Julian Hansen, លោក Gijs Koop, និង លោកស្រី Nina Siegert ដែលបានជួយផ្តល់ព័ត៌មាន។

យល់ដឹងជាសាធារណៈ និងការអប់រំសមស្រប ស្ដីពីសិទ្ធិបានប្រើប្រាស់គ្រោងការសន្តិសុខសង្គម ។

- ***ភាពពុកិច្ចផ្ដត់ផ្គង់*** តំរូវអោយរដ្ឋបង្កើតគ្រោងការគ្មានការចូលរួមវិភាគទានវិធានការជួយឧបត្ថម្ភខាងសង្គម ផ្សេងៗ ដើម្បីផ្ដល់ការគាំទ្រដល់អ្នកដែលមិនអាចចូលរួមបានគ្រប់គ្រាន់ក្នុងការការពារខ្លួនគេផ្ទាល់ ។

ក្នុងការពិតជាក់ស្ដែង ការអនុវត្តសិទ្ធិទទួលបានសន្តិសុខសង្គម មានការរីកចំរើនតិចតួចណាស់ ដោយបច្ចុប្បន្នប្រជាជន ៨០% លើសកលលោក គ្មានលទ្ធភាពទទួលបានសន្តិសុខសង្គមជាផ្លូវការទេ (*ibid: 3*) ។

## ២. ស្ថានភាពជាក់ស្ដែងនៅកម្ពុជា

ប្រទេសកម្ពុជាមានប្រជាជនប្រហែល ១៤លាននាក់ ដែលមានអត្រាកំនើនប្រមាណ ២% ក្នុងមួយឆ្នាំ ។ ប្រជាជន កម្ពុជាប្រហែល ៥០% មានអាយុក្រោម ២០ឆ្នាំ ។ តំបន់ជនបទគឺជាកន្លែងរស់នៅរបស់ប្រជាជនប្រហែល ៨០% ក្នុងនេះមានប្រហែល ៩០% នៃប្រជាជនក្រីក្រនៅកម្ពុជា ។ នៅឆ្នាំ២០០៧ ផសស គិតក្នុងមនុស្សម្នាក់ គឺ ៥៩៨ដុល្លារ ហើយ ប្រជាជន ៣០,១% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ (Ministry of Planning 2008) ។ ការសិក្សាប្រៀបធៀប ដែលធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចុះកិច្ចសន្យាអោយធ្វើ បានរកឃើញថា សន្ទស្សន៍គាំពារសង្គមកម្ពុជា គឺ ០,១៨ ធ្វើអោយកម្ពុជាស្ថិតនៅលំដាប់ថ្នាក់ទី២៥ ក្នុងចំនោម ៣១ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិកដែលមានគណនាសន្ទស្សន៍នេះ (ADB & Halcrow Group 2007: 20) ។ លំដាប់ថ្នាក់នេះទាបជាខ្លាំងជាងកំរិតមធ្យមរបស់អាស៊ី (០,៣៦%) ប៉ុន្តែវាប្រហាក់ប្រហែលនឹងសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស និងលំដាប់ថ្នាក់ ផសស គិតក្នុងមនុស្សម្នាក់របស់កម្ពុជា ។ សរុបមក ប្រជាជនកម្ពុជាភាគច្រើន គ្មានប្រព័ន្ធសុវត្ថិភាពទេ ហើយនៅពេលឈឺថ្កាត់ ពួកគេពុំមានធនធានគ្រប់គ្រាន់ ដើម្បីទទួលបានការព្យាបាលដ៏សមស្របឡើយ " (*Cambodia Daily*, 22 October 2008) ។

ជារឿយៗ ប្រព័ន្ធសុវត្ថិភាពសង្គមតែមួយគត់ដែលប្រជាជនកម្ពុជាភាគច្រើនអាចពឹងផ្អែកបានគឺ ក្រុមគ្រួសាររបស់ខ្លួន ។ នៅឆ្នាំ២០០៦ អង្កេតពីសុខភាព និងប្រជាសាស្ត្រនៅកម្ពុជា របស់រាជរដ្ឋាភិបាល (RGC 2006) បានផ្ដល់ព័ត៌មានមួយចំនួនពីគ្រួសារនៅកម្ពុជា ដូចជា:

- គ្រួសារមានសមាជិកជាមធ្យម ៥នាក់ ហើយគ្រួសារនៅជនបទមានទំហំតូចជាងគ្រួសារនៅទីក្រុងបន្តិច ។
- គ្រួសារ ២៥% មានមេគ្រួសារជាស្ត្រី ។
- ក្មេងអាយុក្រោម១៨ឆ្នាំ ប្រហែល ៧៩% រស់នៅជាមួយឪពុកម្ដាយ ។
- ស្ត្រីពុំមានសំលេងអ្វីច្រើនទេ ក្នុងការសំរេចចិត្តលើបញ្ហាសំខាន់ៗពាក់ព័ន្ធដល់ខ្លួនគេ និងក្រុមគ្រួសាររបស់ពួកគេ ។ សូម្បីតែអាពាហ៍ពិពាហ៍ ក៏ច្រើនតែសំរេចដោយឪពុកម្ដាយ ជាជាងគូស្វាមីភរិយាដែរ (ពិសេសនៅតំបន់ជនបទ) ហើយស្ត្រី ៥២% មិនបានចូលរួមបន្តិចសោះ ក្នុងការជ្រើសរើសស្វាមីរបស់ខ្លួន ។

ការគាំពារសង្គមជាផ្លូវការ និងការផ្ដល់សេវាសង្គមរបស់រដ្ឋ មានតិចតួចណាស់ ហើយ "ប្រព័ន្ធសន្តិសុខសង្គមជាផ្លូវការ (ដែលជាខ្វង់មួយដ៏ធំនៅក្នុងមុខចំនាយគាំពារសង្គមរបស់ប្រទេសឯទៀតជាច្រើន) ... បានផ្ដល់អត្ថប្រយោជន៍តិចតួច ដល់អ្នកក្រ" (ADB & Halcrow Group 2007: 20) ។ សំរាប់អ្នកខ្វះខាត និងអ្នកក្រ ចំណាយគាំពារសង្គមផ្ដោតចំគោលដៅ គឺមានសារៈសំខាន់ជាង ។ ក្នុងរឿងនេះ ស្ថានភាពមិនអាក្រក់ដូចការគិតទេ ។ តាមការសិក្សារបស់ធនាគារ ADB នៅក្នុងចំណាយលើការគាំពារសង្គមសរុប ៧៨លានដុល្លារ (១,៤% នៃ ផសស) មានប្រហែល ៦០% (៤៨លានដុល្លារ) បានផ្ដល់អត្ថប្រយោជន៍ដល់អ្នកក្រ ។ បើធៀបនឹងអត្រាភាពក្រីក្រប្រមាណ ៣០% នោះ គេឃើញថា កម្មវិធីចំណាយខាងសង្គមមានការផ្ដោតចំគោលដៅជួយដល់អ្នកក្រកំរិតខ្ពស់ (*ibid*) ។

គ្រោងការគាំពារសង្គមភាគច្រើន ពឹងផ្អែកជាខ្លាំងលើអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយអន្តរជាតិ ជាពិសេសក្នុងផ្នែកថែទាំសុខភាព ។ សារព័ត៌មាន Cambodia Daily ចេញផ្សាយថ្ងៃទី២២ តុលា ២០០៨ បានរាយការណ៍ថា ប្រជាជនដែលពុំមានលទ្ធភាពបង់ថ្លៃប្រើប្រាស់សេវាថែទាំសុខភាព ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើ មន្ទីរពេទ្យសប្បុរសធម៌ដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល ។ មន្ទីរពេទ្យ និងមជ្ឈមណ្ឌលថែទាំសុខភាពសាធារណៈ ជួបការលំបាកដោយទទួលបានថវិកាពីរដ្ឋ ប្រាក់ខែ និងប្រាក់លើកចិត្តតិចតួចពេក ដែលបានប៉ះពាល់មិនល្អដល់ការផ្ដល់សេវា (RGC 2008a) ។ ប៉ុន្តែជាភ័ព្វល្អ សព្វថ្ងៃមានយន្តការផ្ដល់ហិរញ្ញប្បទានថែទាំសុខភាពជាច្រើនកំពុងផុសឡើង និងរីកលូតលាស់ ដូចជា ប្រព័ន្ធមូលនិធិសមធម៌ថែទាំសុខភាព សំរាប់ជួយអ្នកក្រឱ្យទទួលបានសេវាថែទាំសុខភាព (Health Equity Fund: HEF) ការធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍សំរាប់វិស័យមិនផ្លូវការ (Community-based health insurance: CBHI) និង ការធានារ៉ាប់រងសុខភាពសង្គមជាកាតព្វកិច្ចសំរាប់វិស័យផ្លូវការ (Social Health Insurance: SHI) ។ យន្តការនេះសំខាន់ខ្លាំងណាស់ ពីព្រោះការឈឺថ្កាត់ជាមូលហេតុធំបំផុតនៃការធ្លាក់ចូលក្នុងភាពក្រីក្រ (World Bank 2006: xii) ។

## ៣. គោលនយោបាយសង្គម

គ្រោងការនិងគោលនយោបាយសង្គមកម្ពុជានាបច្ចុប្បន្ន ស្ថិតក្រោមសិទ្ធិអំនាចរបស់ក្រសួងមួយចំនួន ។ តារាងខាងក្រោម បង្ហាញថា គោលនយោបាយសង្គមកម្ពុជាមិនគ្រាន់តែផ្ដោតលើក្រុមនានាដូចមានរៀបរាប់ក្នុង "ផ្នែកសំខាន់ៗទាំង ៩ នៃសន្តិសុខសង្គម" និង "ក្រុមគោលដៅសំខាន់ៗទាំង ៧ ដែលត្រូវទទួលការគាំពារពីសង្គម" ប៉ុណ្ណោះទេ ប៉ុន្តែមានរួមបញ្ចូលផងដែរនូវ ជនក្រីក្រទូទៅ យុវជន ជនរងគ្រោះពីគ្រោះធម្មជាតិ អតីតយុទ្ធជន អ្នកញៀនថ្នាំ ជនរងគ្រោះពីការលក់ដូរមនុស្ស នារីរងគ្រោះ និងជនគ្មានជំរក ។ ទោះយ៉ាងនេះក្ដី មានតំរុយតិចតួចណាស់ដែលបង្ហាញថា គេបានគិតគូរដល់ ជនគ្មានការងារធ្វើពេញលេញ ស្ត្រីមានគភ៌ ស្ត្រីទើបសំរាលកូន រឺជនរួចរស់ជីវិតពីគ្រោះថ្នាក់ ។

របាយការណ៍ក្រសួងផែនការឆ្នាំ២០០៨ បង្ហាញថា ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ គោលនយោបាយសង្គមបានរីកចំរើនទៅមុខ ដូចជា :

- នៅឆ្នាំ២០០៧ អត្រាភាពក្រីក្រធ្លាក់ចុះមកត្រឹម ៣០,១% ធៀបនឹងអត្រា ៣៤,៧% នៅឆ្នាំ២០០៤ ។ ការសិក្សារបស់ធនាគារ ADB បញ្ជាក់ច្បាស់ថា "កម្មវិធីចំណាយខាងសង្គមបានផ្ដោតច្រើនលើអ្នកក្រ ហើយវាឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងយ៉ាងខ្លាំងរបស់ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយអន្តរជាតិនានា ដើម្បីតំរង់ទិសកម្មវិធីគាំពារសង្គមទៅជួយអ្នកក្រ" (ADB & Halcrow 2007: 20) ។
- យន្តការហិរញ្ញប្បទានខាងសន្តិសុខសង្គម និងថែទាំសុខភាពមួយចំនួន កំពុង

| ផ្នែកសំខាន់ៗទាំង៩ នៃសន្តិសុខសង្គម (ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ច នៃ UN ឆ្នាំ២០០៨) | ក្រុមគោលដៅសំខាន់ៗទាំង ៧ ដែលត្រូវទទួលការគាំពារពីសង្គម (ADB & Halcrow 2007) | ចំណុចអាទិភាពខាងគោលនយោបាយសង្គមនៅកម្ពុជា |
|---|---|---|
| ការថែទាំសុខភាព | | • ការថែទាំសុខភាពដោយឥតគិតថ្លៃ សំរាប់អ្នកក្រ (HEF)<br>• CBHI សំរាប់វិស័យមិនផ្លូវការ<br>• SHI ជាកាតព្វកិច្ចសំរាប់ វិស័យផ្លូវការ |
| ការឈឺថ្កាត់ | អ្នកមានជំងឺ | • ការថែទាំសុខភាពដោយឥតគិតថ្លៃ សំរាប់អ្នកក្រ (HEF)<br>• CBHI សំរាប់វិស័យមិនផ្លូវការ<br>• SHI ជាកាតព្វកិច្ចសំរាប់ វិស័យផ្លូវការ |
| ជរាភាព | ជនចាស់ជរា | មូលនិធិជាតិសំរាប់សន្តិសុខសង្គម (National Social Security Fund: NSSF) រឺ មូលនិធិសន្តិសុខសង្គមសំរាប់មន្ត្រីរាជការស៊ីវិល |
| ភាពគ្មានការងារធ្វើ | ជនគ្មានការងារធ្វើ | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ |
| | ជនមិនមានការងារធ្វើពេញលេញ | |
| របួសដោយការបំពេញការងារ | | មូលនិធិសន្តិសុខសង្គមជាតិ (National Social Security Fund: NSSF) រឺ មូលនិធិសន្តិសុខសង្គមសំរាប់មន្ត្រីរាជការស៊ីវិល |
| ការផ្គត់ផ្គង់គ្រួសារ និងកុមារ | | • គ្រួសារមានស្ត្រីជាមេគ្រួសារ<br>• យុវនីតិសម្បទា និងសុខមាលភាពកុមារ |
| មាតុភាព | | |
| ពិការភាព | ជនពិការ | ជនពិការ |
| ជនរួចរស់ជីវិត និង កុមារកំព្រា | | កុមារកំព្រា |
| | ជនក្រីក្រ | ជនក្រីក្រ (ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ-IDPoor...) |
| | កុមារមានតំរូវការពិសេស | យុវនីតិសម្បទា និងសុខមាលភាពកុមារ |
| | | ជំនួយបន្ទាន់ដល់ជនរងគ្រោះពីគ្រោះធម្មជាតិ និងមហន្តរាយផ្សេងៗ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ឬ អគ្គីភ័យ |
| | | មូលនិធិសោធននិវត្តន៍សំរាប់មន្ត្រីរាជការ |
| | | អតីតយុទ្ធជន |
| | | អ្នកញៀនថ្នាំ |
| | | ជនរងគ្រោះពីការជួញដូរ |
| | | នារីរងគ្រោះ |
| | | ជនគ្មានទីជំរក |

បង្កើតឡើង និងពង្រីកថែម នាពេលបច្ចុប្បន្ន ។

- កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (IDPoor) ត្រូវបានបង្កើតឡើង ។
- សេចក្តីព្រាងច្បាប់ស្តីពី ការគាំពារ និងលើកស្ទួយសិទ្ធិជនពិការ បានផ្ញើរួចរាល់ទៅរដ្ឋសភាដើម្បីសុំអនុមតិ ។
- សមាគមអតីតយុទ្ធជនកម្ពុជាត្រូវបានបង្កើតឡើង ដើម្បីលើកស្ទួយសាមគ្គីភាព ការជួយថែទាំគ្នាទៅវិញទៅមក និង ជីវភាពរស់នៅរបស់អតីតយុទ្ធជន ។
- កុមារល្មើសច្បាប់រាប់ពាន់នាក់ អ្នកញៀនថ្នាំ ជនគ្មានទីជំរក និងកុមាររស់នៅតាមចិញ្ចើមថ្នល់រាប់រយនាក់ បានទទួលអត្ថប្រយោជន៍ពី សេវាអប់រំ/ថែទាំសុខភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរៀបចំឱ្យចូលរួមរស់ក្នុងសហគមន៍វិញ ។
- ព្រមជាមួយការបង្កើតមជ្ឈមណ្ឌលសំរាប់ជនរងគ្រោះពីការជួញដូរ មានការស្តារលទ្ធភាពពលកម្ម និងការផ្តល់សេវាអប់រំថែទាំសុខភាពដោយគ្មានរើសអើងដល់កម្មករ និងជនរងគ្រោះពីការជួញដូរផ្លូវភេទ ។
- ចំនួនអ្នកគ្មានទីជំរក បានថយចុះ ។

ទោះយ៉ាងនេះក្តី បញ្ហាប្រឈមធំៗនៅតែមានមួយចំនួន ជាអាទិ៍:

- អត្រាគ្របបណ្តប់សំរាប់ក្រុមគោលដៅសំខាន់ៗ ជាទូទៅមានកំរិតទាបគឺ : "អត្រាគ្របដណ្តប់សំរាប់កម្មវិធីជំនួយសង្គម មាន ១៦% នៃប្រជាជនក្រីក្រ ហើយអត្រាសំរាប់ក្រុមគោលដៅសំខាន់ៗឯទៀតនៅទាបជាង ១០% ដែលបញ្ជាក់ពីអវត្តមាននៃកម្មវិធីសំខាន់ៗមួយចំនួនសំរាប់ក្រុមទាំងនោះ" (*ibid*) ។
- បញ្ហាប្រឈមធំបំផុតគឺ ការផ្តល់សេវាថែទាំសុខភាព និងសន្តិសុខសង្គមដល់អ្នកក្រយ៉ាងច្រើននាក់នោះ ។
- បញ្ហាប្រឈមបន្ទាន់មួយ គឺការផ្តល់ឧបត្ថម្ភធន ឬការលើកលែងពន្ធឱ្យចំមុខផលិតផលសំខាន់ៗ ដើម្បីជួយទប់ទល់ផលប៉ះពាល់ពីការឡើងថ្លៃម្ហូបអាហារ ។

## ៤. ការបកស្រាយលំអិតពីគំនិតផ្តួចផ្តើមមួយចំនួន

ការថែទាំសុខភាពជាចំណុចមួយដ៏សំខាន់បំផុតនៃសន្តិសុខសង្គម: "ភាគីរដ្ឋមានកាតព្វកិច្ចធានានូវការបង្កើត ប្រព័ន្ធថែទាំសុខភាព ដើម្បីឱ្យគ្រប់ៗគ្នាមានលទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាពយ៉ាងគ្រប់គ្រាន់ ។ ក្នុងករណីដែលប្រព័ន្ធថែទាំសុខភាពមានគិតបញ្ចូល ផែនការឯកជន ឬផែនការចំរុះផង ផែនការទាំងនោះគួរមានតំលៃសមរម្យ អាចប្រើប្រាស់បាន ..." (UN Economic and Social Council 2008: 5) ។

ប្រទេសកម្ពុជា បានជួបឧបសគ្គជាច្រើនក្នុងការធ្វើហិរញ្ញប្បទានសំរាប់ការថែទាំសុខភាព និងការផ្តល់ការគាំពារសុខភាពសង្គម ដោយប្រើថវិការដ្ឋាភិបាល ។ ជាជំហានដំបូង ប្រទេសកម្ពុជាបានអនុម័តផែនការមេសំរាប់ការធានារ៉ាប់រងសុខភាពសង្គមនៅឆ្នាំ២០០៥ និង ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់ផ្តល់ហិរញ្ញប្បទានថែទាំសុខភាពនៅឆ្នាំ២០០៨ ។ គេសង្ឃឹមថា ផែនការមេថ្មីមួយសំរាប់ការគាំពារសុខភាពសង្គម (RGC 2008a) នឹងនាំឱ្យមាន ប្រព័ន្ធគាំពារសុខភាពសង្គមរួមបញ្ចូលគ្នាតែមួយ និងសេវាថែទាំសុខភាពដែលគ្របដណ្តប់លើគ្រប់គ្នាទាំងអស់ ។

គំនិតផ្តួចផ្តើម និងគោលនយោបាយផ្សេងៗខាងសន្តិសុខសង្គម រួមមាន HEF, CBHI, NSSF និង IDPoor ។

### *៤.១. មូលនិធិសមធម៌ខាងសុខភាព*

ការផ្តួចផ្តើមគំនិតសំខាន់បំផុតក្នុងការផ្តល់សេវាសង្គម អាចជាប្រព័ន្ធ HEF ដែលសំដៅជួយអោយអ្នកក្រ ទទួលបានសេវាថែទាំសុខភាពតាមរយៈការបង់ថ្លៃឱ្យអ្នកផ្តល់សេវា ដើម្បីអោយគេផ្តល់សេវាថែទាំសុខភាពដល់ អ្នកដែលពុំមានលទ្ធភាពបង់កំរៃថែទាំសុខភាពតាមធម្មតាបាន ។ HEFs គឺជាប្រព័ន្ធគាំពារសុខភាពសង្គមចំបងគេ សំរាប់ជួយដល់អ្នកក្រ និងជនងាយរងគ្រោះ ។

កន្លងមកគេបានដកពិសោធន៍ប្រើគ្រោងការប្រភេទផ្សេងៗ អស់រយៈពេលជាច្រើនឆ្នាំ ។ នៅឆ្នាំ១៩៩៦ ការអនុម័ត ធម្មនុញ្ញជាតិស្តីពីហិរញ្ញប្បទានថែទាំសុខភាព បានផ្តល់នូវក្របខ័ណ្ឌច្បាប់មួយសំរាប់គ្រោងការហិរញ្ញប្បទានថែទាំសុខភាព ។ នៅឆ្នាំ១៩៩៧ មានការសាកល្បងយកកំរៃអ្នកប្រើប្រាស់ជាផ្លូវការនៅតាមកន្លែងថែទាំសុខភាពរបស់រដ្ឋមួយចំនួន ។ ការយកកំរៃពីអ្នកប្រើប្រាស់នេះ មានគោលដៅបង្កើតប្រាក់ចំណូលបន្ថែមយ៉ាងទៀងទាត់ និងជួយសំរួលអោយមានការគ្រប់គ្រងល្អ ។ ក្នុងគ្រោងការក៏មានប្រព័ន្ធលើកលែងមួយ ដើម្បីជួយអោយអ្នកក្របំផុត អាចប្រើប្រាស់សេវាបាន ។ នាបច្ចុប្បន្ន សេវាសុខភាពសាធារណៈស្ទើរតែទាំងអស់សុទ្ធតែយកកំរៃពីអ្នកប្រើប្រាស់ ហើយប្រព័ន្ធឥតបង់ថ្លៃ មិនទាន់មានដំណើរការល្អគួរជាទីពេញចិត្តទេ ។

ដោយសារមូលហេតុខាងលើ នៅឆ្នាំ២០០០ ប្រព័ន្ធ HEFs ត្រូវបានបង្កើតឡើងដើម្បីបង្កើនលទ្ធភាពឱ្យអ្នកក្រ ។ អ្នកទទួលផលដែលមានសិទ្ធិទទួលរបបអនុគ្រោះ ត្រូវបានកំណត់ នៅកំរិតសហគមន៍មុនពេលសាមីជនត្រូវការសេវាថែទាំសុខភាព(កំណត់អត្តសញ្ញាណជាមុន) ឬ នៅមណ្ឌលសុខភាពតាមរយៈសំភាសន៍ (កំណត់អត្តសញ្ញាណជាក្រោយ) ។ អ្នកជំងឺដែលមានសិទ្ធិ គឺទទួលបានជំនួយទាំងស្រុងលើថ្លៃព្យាបាល និងជំនួយមួយចំនែក ឬទាំងស្រុងសំរាប់ចំណាយធ្វើដំណើរ និងចំនាយផ្សេងទៀតក្នុងពេលសំរាកព្យាបាលនៅមន្ទីរពេទ្យ ។ បទពិសោធន៍កន្លងមកបង្ហាញថា ប្រព័ន្ធ HEFs បានធ្វើឱ្យអ្នកក្រទទួលបានសេវាថែទាំសុខភាពកាន់តែច្រើន ។

ប្រព័ន្ធ HEFs បានក្លាយជាសមាសភាគមួយយ៉ាងសំខាន់នៃ ផែនការយុទ្ធសាស្ត្រសំរាប់វិស័យសុខាភិបាល(២០០៣-២០០៧) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ(២០០៣-២០០៥) និង ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០) ។ ស្របគ្នានេះ នៅខែកញ្ញា ២០០៥ ក្រសួងសុខាភិបាល បានកសាងក្របខ័ណ្ឌតាមដាននិងអនុវត្ត មូលនិធិសមធម៌ជាតិ ។ ម្យ៉ាងទៀត នៅខែវិច្ឆិកា ២០០៦ ក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសរួមគ្នាមួយ សំរាប់ការបែងចែកថវិការដ្ឋដល់បណ្តាមន្ទីរពេទ្យជាតិ និងការិយាល័យស្រុកប្រតិបត្តិ ដើម្បីផ្តល់ឧបត្ថម្ភធនដល់សេវាថែទាំសុខភាពសំរាប់ជនក្រីក្រ ។

ការមិនយកកំរៃលើសេវាសុខភាពសំរាប់ជនក្រីក្រតាមរយៈប្រព័ន្ធ HEFs បានអនុវត្តនៅ ៣៧ស្រុកប្រតិបត្តិ ធៀបនឹង ១៧ស្រុកប្រតិបត្តិនៅឆ្នាំ២០០៤ ។ ផែនការសុខាភិបាលឆ្នាំ២០០៨-១៥ សំដៅពង្រីកប្រព័ន្ធ HEFs ឱ្យបានទូទាំង ប្រទេស ។

ប្រព័ន្ធ HEFs មានប្រយោជន៍ណាស់ ក្នុងការជួយជនក្រីក្រអោយទទួលបានសេវាថែទាំសុខភាព និង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចជាទូទៅ ។ បច្ចុប្បន្ននេះ បញ្ហាប្រឈមចំបង គឺការពង្រីកប្រព័ន្ធ HEFs អោយបានដល់ប្រជាជនក្រីក្រនៅទូទាំងប្រទេស ។

### *៤.២ ការធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍*

ការធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍ (Community-Based Health Insurance: CBHI) គឺជាគ្រោងការអភិវឌ្ឍន៍ ដ៏សំខាន់មួយទៀត ។ គ្រោងការ CBHI ផ្ដោតលើ វិស័យមិនផ្លូវការដែលមាន ៨៥% នៃប្រជាជនសរុប (Ministry of Economy and Finance 2008) ក្នុងនេះភាគច្រើន ជាពិសេសអ្នកនៅតំបន់ជនបទ មិនបានទទួល សេវាគាំពារសុខភាពសង្គមបែបណាមួយនោះទេ (RGC 2008a) លើកលែងតែក្នុងស្រុកខ្លះដែលគ្រោងការ CBHI បានចុះទៅដល់ ។

ក្នុងគ្រោងការ CBHI មានការបង់ប្រាក់ជាមុនដោយស្ម័គ្រចិត្ត ជាលក្ខណៈឯកជន តែមិនស្វែងរកចំណេញ ។ គ្រោងការនេះផ្ដោតលើ អ្នកមានជីវភាពខ្ពស់ជាងបន្ទាត់ភាពក្រីក្របន្តិច និងមានលទ្ធភាពបង់ថ្លៃធានារ៉ាប់រងសុខភាព ។

បញ្ហាប្រឈមចំបង គឺការពង្រីកគ្រោងការ CBHI ឱ្យគ្របដណ្ដប់ទូទាំងប្រទេស ។

### *៤.៣. ការធានារ៉ាប់រងសុខភាពសង្គម និង មូលនិធិជាតិសំរាប់សន្តិសុខសង្គម*

សំរាប់វិស័យផ្លូវការទាំងខាងសាធារណៈនិងឯកជន ត្រូវមានការផ្ដល់សន្តិសុខសង្គម (ជាកាតព្វកិច្ច) តាមរយៈប្រព័ន្ធ SHI ។ មានផែនការមួយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្ដោតលើមន្ត្រីរាជការ និងផែនការមួយទៀតរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលផ្ដោតលើវិស័យផ្លូវការ ។ ប្រព័ន្ធSHI ទទួលថវិកាពីរដ្ឋ តាមរយៈ មូលនិធិជាតិសំរាប់សន្តិសុខសង្គម (National Social Security Funds: NSSF) ដែលបានមកពីការកាត់ទុកប្បៀវត្សរ៍របស់បុគ្គលិករដ្ឋ និង ការបង់វិភាគទានរបស់និយោជក (០.៨% នៃពន្ធលើប្រាក់ប្បៀវត្សរ៍) ។ ដូចនេះ ប្រព័ន្ធ SHI មានប្រភពថវិកាពីរ ។

មូលនិធិជាតិសំរាប់សន្តិសុខសង្គម (មន្ត្រីរាជការស៊ីវិល) នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាផ្ដោតលើមន្ត្រីស៊ីវិលពោលគឺវិស័យសាធារណៈ ។ មូលនិធិនេះត្រូវបានអនុម័តនៅខែកុម្ភៈ ២០០៨ ហើយគ្របដណ្ដប់ (ចាប់ពីឆ្នាំ ២០០៩ ទៅ) លើសោធន ពិការភាព/ការបាត់បង់សមត្ថភាពពលកម្ម មាតុភាព គ្រោះថ្នាក់ចរាចរ របួសនៅពេលបំពេញការងារ និងមរណភាព (RGC 2008b) ។

មូលនិធិរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (NSSF) ផ្ដោតលើនិយោជិតក្នុងវិស័យឯកជន ហើយទទួលការអនុម័ត នៅខែមីនា ២០០៧ ។ ក្នុងជំហានដំបូង មូលនិធិ NSSF ផ្ដល់ប្រាក់ឧបត្ថម្ភសំរាប់ការរងរបួសនៅពេលធ្វើការ ហើយនឹងមាន ចាប់ពីឆ្នាំ២០១០ នូវការធានារ៉ាប់រងលើសុខភាព និងចាប់ពីឆ្នាំ២០១២ នូវមូលនិធិសោធននិវត្តន៍ (*Phnom Penh Post, 19 August 2008*) ។

ដើម្បីកែលំអសន្តិសុខសង្គមសំរាប់អ្នកបំរើការក្នុងវិស័យផ្លូវការ គេត្រូវធ្វើសុខដុមនីយកម្ម (ជាពិសេស ទាក់ទិននឹងអត្ថប្រយោជន៍) និងបង្កើតបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធ SHI ជាពិសេសស្ដីពី ក្របខ័ណ្ឌ និងការអនុវត្តច្បាប់ (RGC 2008a) ។ មូលនិធិ NSSF ក៏ត្រូវពង្រីកទៅគ្របដណ្ដប់លើវិស័យឯកជនដែលមានលក្ខណៈមិនផ្លូវការ រឺប្រកបមុខរបរដោយខ្លួនឯង ក្នុងនេះមានជាអាទិ ប្រជាជនជនបទដែលភាគច្រើនមិនមានគេជួលឱ្យធ្វើការ ហើយក៏គ្មានអ្នកណាបង់វិភាគទានចូលមូលនិធិ NSSF អោយពួកគេ ។

### *៤.៤. កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (IDPoor Programme)*

នៅឆ្នាំ២០០៥ រដ្ឋាភិបាល បានចាត់ឱ្យក្រសួងផែនការ ដឹកនាំការកសាង និងអនុវត្តនីតិវិធីជាតិស្ដង់ដារ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។ ក្នុងនេះបានបង្កើតក្រុមការងារថ្នាក់ជាតិមួយ ហើយនៅឆ្នាំ២០០៦ បានបង្កើតកម្មវិធី IDPoor ដោយមានជំនួយបច្ចេកទេសពីប្រទេសអាល្លឺម៉ង់តាមរយៈអង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) ។ មុនពេលបង្កើតកម្មវិធីនេះ មានការប្រឹងប្រែងជាច្រើនដើម្បីធ្វើផែនការអភិវឌ្ឍន៍ សំដៅកាត់បន្ថយភាពក្រីក្រ និងផ្ដល់សេវាដល់គ្រួសារក្រីក្រ ប៉ុន្តែមិនទាន់មានវិធីសាស្ត្រស៊ីសង្វាក់គ្នាសំរាប់កំណត់អត្តសញ្ញាណអ្នកទទួលផល និងផ្ដល់ទិន្នន័យនេះដល់អ្នកផ្ដល់សេវាទេ ដោយស្ថាប័ននីមួយៗបានបង្កើត និងប្រើប្រាស់នីតិវិធី/លក្ខណៈវិនិច្ឆ័យរៀងៗខ្លួន ។

គោលដៅសំខាន់ៗនៃ កម្មវិធី IDPoor គឺដើម្បី :

- កសាង និងអនុវត្តនីតិវិធីបែបស្ដង់ដារសំរាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។
- ពង្រីកការគ្របដណ្ដប់តាមលទ្ធភាពធនធាន ឱ្យដល់គ្រប់តំបន់ជនបទ (លក្ខណៈវិនិច្ឆ័យសំរាប់តំបន់ទីក្រុង មិនទាន់បានបង្កើតទេ) តាមរយៈការដាក់បញ្ចូលទៅក្នុងការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ និងអង្គភាពជំនួយរបស់ពួកគេ ។
- ផ្ដល់ព័ត៌មានច្បាស់លាស់ពីគ្រួសារក្រីក្រ ដើម្បីអោយអ្នកផ្ដល់សេវាអាចផ្ដោតកាន់តែចំអ្នកក្រ ។

ទិន្នន័យបានពីកម្មវិធី IDPoor អាចប្រើ និងកំពុងតែប្រើសំរាប់សេវា និងជំនួយជាច្រើន ដូចជា សេវាថែទាំសុខភាព ដោយឥតគិតថ្លៃ រឺដោយមានឧបត្ថម្ភធនតាមរយៈប្រព័ន្ធ HEFs រឺ CBHI, អាហាររូបករណ៍សំរាប់សិស្ស/និស្សិតក្រីក្រ, សម្បទានដីសង្គមកិច្ច, សេវាខាងកសិកម្ម, និង កម្មវិធីផ្ទេរប្រាក់ផ្សេងៗ ។

កម្មវិធី IDPoor កំណត់អត្តសញ្ញាណគ្រួសារតាមទីតាំង និងលេខសំគាល់ខ្លួនមួយ ហើយផ្ដល់ទិន្នន័យលើសមាជិកគ្រួសារម្នាក់ៗ ដូចជា ឈ្មោះ ភេទ ឆ្នាំកំណើត និងទំនាក់ទំនងជាមួយមេគ្រួសារ ។ ម្យ៉ាងទៀតមានការថតរូប និងចេញប័ណ្ណសមធម៌ អោយគ្រួសារក្រីក្រ ហើយទិន្នន័យទាំងអស់បានដាក់បញ្ចូលក្នុងកំរងទិន្នន័យជាតិ ។

ដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ មានច្រើនជំហានសំខាន់ៗ:[2]

- ការបណ្ដុះបណ្ដាលតួអង្គអ្នកធ្វើការ (ពិសេស អ្នកសម្របសម្រួលថ្នាក់ឃុំ និងសមាជិកក្រុមតំណាងភូមិដែល អ្នកភូមិបានបោះឆ្នោតជ្រើសតាំង)
- សំភាសន៍គ្រួសារដោយប្រើបញ្ជីសំនួរស្ដង់ដារមួយ
- ការបង្ហាញនូវបញ្ជីព្រាងគ្រួសារក្រីក្រ
- ការប្រជុំពិគ្រោះយោបល់ក្នុងភូមិ និងការពិចារណាលើសំណើ និងការតវ៉ារបស់អ្នកភូមិ ទាក់ទងនឹងបញ្ជីព្រាង
- ការត្រួតពិនិត្យឡើងវិញ និងការអនុម័តបញ្ជី ដោយក្រុមប្រឹក្សាឃុំ
- ការបញ្ចូលទិន្នន័យដោយមន្ទីរផែនការខេត្ត ទៅក្នុងទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ
- ការចែកប័ណ្ណសមធម៌ដល់គ្រួសារក្រីក្រ ។ ប័ណ្ណនេះជួយអ្នកផ្ដល់សេវាឱ្យ

---

២ សំរាប់ព័ត៌មានបន្ថែម សូមចូលទៅ វេបសាយ www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx

កំណត់បានយ៉ាងលឿនពី អត្តសញ្ញាណគ្រួសារក្រីក្រ ព្រមទាំងលើកកំពស់ការយល់ដឹងរបស់គ្រួសារក្រីក្រក្នុងការទាមទារសិទ្ធិរបស់ខ្លួន ដូចជា សិទ្ធិស្វែងរកសេវានិងជំនួយ ព្រមទាំងសិទ្ធិអនុវត្តសិទ្ធិទទួលបានសេវានិងជំនួយទាំងនោះ ។

គ្រួសារក្រីក្រអាចទទួលបានចំណាត់ថ្នាក់ ក្រកំរិតទី១ (ក្រីក្របំផុត) រឺក្រកំរិតទី២ (ក្រីក្រ) អាស្រ័យលើពិន្ទុក្នុងបញ្ជីសំនួរ និងការពិចារណាលើស្ថានភាពពិសេសរបស់គ្រួសារនោះ ។ សមាមាត្រគ្រួសារដែលស្ថិតក្នុងកំរិតទាំងពីរត្រូវបានក្រិតអោយស្របទៅនឹង លទ្ធផលនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ (ដោយអាចមានគំលាតខ្លះ សំរាប់ ការប្រែប្រួលតាមពេលវេលា) ។ ក្រកំរិតទី១ សំដៅដល់ គ្រួសារដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រខាងម្ហូបអាហារ កំណត់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ហើយក្រកំរិតទី២ គឺគ្រួសារដែលស្ថិតនៅចន្លោះបន្ទាត់ភាពក្រីក្រខាងម្ហូបអាហារ និងបន្ទាត់ភាពក្រីក្រ ។ ជាមធ្យម មានគ្រួសារប្រមាណមួយភាគបី ស្ថិតក្នុង ក្រកំរិតទី១ ឬ ក្រកំរិតទី២ ។

នៅខែតុលា ២០០៨ ក្រសួងផែនការបានអនុវត្តកម្មវិធី IDPoor នៅទូទាំងខេត្តឧត្តរមានជ័យ សៀមរាប និងក្រចេះ ព្រមទាំង ៣ស្រុកប្រតិបត្តិក្នុងខេត្តកំពង់ចាម និង ២ស្រុកប្រតិបត្តិក្នុងខេត្តព្រៃវែង ។ នៅឆ្នាំ២០០៩ ក្រសួងនឹងអនុវត្ត កម្មវិធី IDPoor នៅ ស្រុកប្រតិបត្តិថ្មីៗទៀត ចំនួន ២ក្នុងខេត្តកំពង់ចាម ១ក្នុងខេត្តបន្ទាយមានជ័យ ១ក្នុងខេត្តពោធិ៍សាត់ និងនៅទូទាំងខេត្តកំពត កំពង់ធំ និងស្វាយរៀង ។ លើសពីនេះ អ្នកដំណើរការប្រព័ន្ធ HEF និងដៃគូនានារបស់ខ្លួនក៏កំពុងអនុវត្តនីតិវិធីនេះនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងកំពង់ចាម ហើយនឹងពង្រីកយ៉ាងហោចណាស់ឱ្យដល់ខេត្តព្រះវិហារ រតនគីរី មណ្ឌលគីរី និងកោះកុង នៅឆ្នាំ២០០៩ ។ផ្អែកតាមមូលនិធិផ្តល់ឱ្យ កម្មវិធី IDPoor នឹងត្រូវអនុវត្តជាកម្មវិធីថ្នាក់ជាតិនៅគ្រប់តំបន់ជនបទ ព្រមទាំងធ្វើបច្ចុប្បន្នភាពនៅរៀងរាល់ពីរឆ្នាំម្តង ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សន្តិសុខសង្គម និងគោលនយោបាយសង្គមនៅកម្ពុជា មានលក្ខណៈក្មេងខ្ចីនៅឡើយ ។ ដើម្បីធានាការគាំពារសង្គមសំរាប់ប្រជាជនទាំងមូល គេត្រូវធ្វើការយ៉ាងច្រើនទៀត ។ កំណើន ផសស ខ្ពស់ និងចំណូលគ្រោងទុកពីប្រេងនិងឧស្ម័នអាចអោយរដ្ឋាភិបាលបង្កើន ចំនាយខាងសង្គម វិនិយោគខាងអភិវឌ្ឍន៍សង្គម និងកសាងថែមទៀតនូវគោលនយោបាយបែងចែកចំណូលឡើងវិញ ដើម្បីធានាការផ្តល់សេវាថែទាំសុខភាព និងសេវាសង្គម ឱ្យបានដល់ប្រជាជនគ្រប់រូប ។

ការបង្កើតប្រព័ន្ធធានារ៉ាប់រងសុខភាព គឺជាសមាសធាតុមួយដ៏សំខាន់ជាពិសេសបើសិនអាចដាក់គ្រោងការនានាដែលមានស្រាប់ ឱ្យស្ថិតក្រោមស្ថាប័នគ្រប់គ្រងថ្នាក់ជាតិតែមួយ ។ បណ្តាគ្រោងការដែលដាច់ពីគ្នាជាបំណែកៗ មិនមានប្រសិទ្ធិភាពទេ ។ ការរៀបចំឱ្យស្ថិតនៅក្រោមស្ថាប័នថ្នាក់ជាតិតែមួយ ធ្វើឱ្យគេអាចប្រមូលផ្តុំហានិភ័យ និងបែងចែកបន្ទុកចំនាយ បានកាន់តែប្រសើរ ។ ប្រព័ន្ធបែបនេះ ត្រូវមានយន្តការសមស្របសំរាប់ផ្តល់ថវិកា ពោលគឺ ការបង់ថ្លៃធានារ៉ាប់រងដោយនិយោជក ព្រមទាំង ការចូលរួមបង់ថ្លៃដោយពលករ និង/រឺ រដ្ឋាភិបាលតាមរយៈពន្ធដារ ។ ផែនការមេសំរាប់ការគាំពារសុខភាពសង្គមដែលកំពុងតាក់តែងនៅពេលនេះ សំដៅដោះស្រាយបញ្ហាប្រឈមជាច្រើន ។ ផែនការមេនេះ មានគោលដៅកសាង និងអនុវត្តប្រព័ន្ធថ្នាក់ជាតិប្រកបដោយចីរភាពសំរាប់គាំពារសុខភាពសង្គម ហើយនឹងជួយធានាការគាំពារសុខភាពសង្គមដល់ប្រជាជនគ្រប់រូប ជាពិសេសជនក្រីក្រ ។

បញ្ហាប្រឈមនាពេលខាងមុខមានច្រើនទៀត ដូចជា :

- បន្ត និងកែលំអគោលនយោបាយជួយដល់អ្នកក្រ
- កសាងគោលនយោបាយបែងចែកចំណូលឡើងវិញ
- បង្កើនចំនាយលើវិស័យសង្គម
- ពង្រីកប្រព័ន្ធ HEF ឱ្យបានទូទាំងប្រទេស
- ពង្រីកប្រព័ន្ធ CBHI
- អនុវត្តប្រព័ន្ធ SHI និង មូលនិធិ NSSF ប្រកបដោយប្រសិទ្ធិភាព
- ពង្រីកដែនគ្របដណ្តប់នៃនីតិវិធីស្តង់ដារសំរាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងបង្កើនការប្រើប្រាស់ទិន្នន័យ សំរាប់កំណត់ទិសដៅផ្តល់សេវា និងជំនួយ
- អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច
- ពង្រីកដែនគ្របដណ្តប់នៃប្រព័ន្ធមីក្រូឥណទាន
- អនុវត្តកម្មវិធីស្បៀងពលកម្មឱ្យបានកាន់តែច្រើន
- បន្ត និង ពង្រីកអន្តរាគមន៍ផ្តោតចំគោលដៅក្នុងវិស័យសង្គម សំរាប់ជួយក្រុមផ្សេងៗដែលត្រូវយកចិត្តទុកដាក់ជាពិសេស ។

សរុបសេចក្តីមក គេត្រូវដោះស្រាយឱ្យបានជាបណ្តើរៗនូវសិទ្ធិទទួលបានសន្តិសុខសង្គម ដោយគ្មានការរើសអើងចំពោះបុគ្គលណាឡើយ ៕

### ឯកសារយោង


ADB & Halcrow Group (2007): *Scaling Up of the Social Protection Index for Committed Poverty Reduction*, Vol. 2: Summary of Country Reports (London: Halcrow China Limited)

Ministry of Economy and Finance (2008): "*Draft Sub-decree on Microinsurance*" (Phnom Penh: RGC)

Ministry of Planning (2008): *The National Strategic Development Plan Mid Term Review* (Phnom Penh: RGC)

Ministry of Social Affairs, Veterans and Youth Rehabilitation (2004): *Action Programs of the Ministry of Social Affairs, Veterans and Youth Rehabilitation 2004-2008* (Phnom Penh: RGC)

Royal Government of Cambodia (2002): *Law on social security schemes for persons defined by the provisions of the labour law* (Phnom Penh: RGC)

Royal Government of Cambodia (2006): *Cambodia Demographic and Health Survey 2005* (Phnom Penh: RGC)

Royal Government of Cambodia (2008a): *Draft Master Plan for Social Health Protection* (Phnom Penh: RGC)

Royal Government of Cambodia (2008b): *Sub-decree on Establishment of the National Social Security Fund* (Phnom Penh: RGC)

UN Economic and Social Council Committee on Economic, *Social and Cultural Rights* (2008): The Right to Social Security, General Comment No. 19 (New York/Geneva: United Nations)

World Bank (2006): *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (Phnom Penh: World Bank)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍មួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន នៅអាស៊ីខាងកើត នៅត្រីមាសទី២ ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី២ ឆ្នាំ២០០៨ កំណើន ផសស ពិត របស់ សហរដ្ឋអាមេរិក នៅតែមានកំរិតខ្លាំងដដែល គឺ ២,៨% ។ កំណើននេះអាចជំរុញ ដោយការនាំចេញ ចំនាយប្រើប្រាស់ផ្ទាល់ខ្លួន ចំនាយលើអាគារមិនសំរាប់ស្នាក់នៅ ហើយនិងចំនាយរបស់រដ្ឋាភិបាលសហព័ន្ធ រដ្ឋនានា និងអាជ្ញាធរមូលដ្ឋាន ។ តំបន់អឺរ៉ូមានសេដ្ឋកិច្ចកើនយឺតត្រឹម ១,៤% ធៀបនឹងត្រីមាសទី២ឆ្នាំមុន ដោយសារ តំរូវការខាងវិនិយោគ និងការប្រើប្រាស់ថយចុះ ។ នៅជប៉ុន កំណើនផលិតផលពិតក្នុងរយៈមួយឆ្នាំ មានត្រឹមតែ ១% ប៉ុណ្ណោះ ព្រោះនៅអាមេរិកខាងជើង និងអឺរ៉ុប ក៏ដូចជានៅប្រទេសជប៉ុនផ្ទាល់ តំរូវការបានធ្លាក់ចុះយ៉ាងខ្លាំង ។

នៅត្រីមាសទី២ ឆ្នាំ២០០៨ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅចិន បន្តធ្លាក់ចុះអស់ ៤ឆ្នាំជាប់ៗគ្នា ដោយសារជាសំខាន់ ការធ្លាក់ចុះការនាំចេញ ។ នៅកូរ៉េខាងត្បូង ផលិតផលពិតសរុបកើន ៤,៨% ធៀបនឹងឆ្នាំមុន ប៉ុន្តែវាថយចុះបន្តិចធៀបនឹងត្រីមាសមុន ព្រោះមានកំណើនអវិជ្ជមានខាងផ្នែកសាងសង់ និង កំណើនយឺតខាងផលិតផលម្ហូបអាហារនិងភេសជ្ជៈ ព្រមទាំង វាយនភ័ណ្ឌ និង ផលិតផលធ្វើពីស្បែក ។ នៅហុងកុង និង តៃវ៉ាន់ ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំកើន ៤,២% និង ៤,៣% តែវាថយចុះ ធៀបនឹងអត្រាកំណើន ៦,៨ និង ៦,៤% នៅត្រីមាសមុន ។ ការថយចុះកំណើន ផសស នៅហុងកុង បណ្តាលមកពីការថយចុះនៃ ការបង្កើតមូលធនជាប់លាប់ និងចំណាយប្រើប្រាស់ឯកជន ។

នៅម៉ាឡេស៊ី ផលិតផលពិតកើន ៦,៣% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៧ តែវាថយចុះធៀបនឹងអត្រាកំណើន ៧,១% នៅត្រីមាសមុន ដោយសារមានការថយចុះយ៉ាងខ្លាំងនៃ ចំណាយប្រើប្រាស់ឯកជននិងសាធារណៈ និងការនាំចេញសុទ្ធ ។ ក្នុងរយៈ១២ខែ ផសស ពិត នៅសិង្ហបុរី កើន ១,៩% តែវាថយចុះធៀបនឹងអត្រា ៨,២% សំរាប់រយៈ១២ខែមុននោះទៀត ព្រោះផ្នែកឧស្សាហកម្មផលិត មានកំណើនអវិជ្ជមាន (-៤,៩%) ។ នៅត្រីមាសទី២ ឆ្នាំ២០០៨ កំណើន ផសស ពិត នៅថៃ នៅតែខ្ពស់ដដែល ទោះបីវាចុះទាបជាងត្រីមាសមុនបន្តិចក្តី ។ កំណើននេះឆ្លុះបញ្ចាំងពី ការនាំចេញដែលនៅតែលូតលាស់ខ្លាំង និងដែលបានជួយប៉ះប៉ូវលើការថយចុះតំរូវការក្នុងស្រុក ។ការអូសបន្លាយចលាចលខាងនយោបាយ និង ការខ្វល់ខ្វាយអំពីការឡើងថ្លៃទំនិញប្រើប្រាស់ កាន់តែធ្វើអោយអ្នកប្រើប្រាស់ទំនិញក្នុងស្រុកបាត់ទំនុកចិត្ត ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០០៨ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក មានអត្រា ៤,៤% រីកើនឡើងបន្តិចធៀបនឹងត្រីមាសមុន ដែលបណ្តាលជាសំខាន់មកពីកំណើនថ្លៃម្ហូបអាហារ និងថាមពល ។ នៅតំបន់អឺរ៉ូ ថ្លៃទំនិញប្រើប្រាស់ទូទៅកើន ៣,៨% ធៀបនឹងអត្រា ១,៩% នៅត្រីមាសដូចគ្នាឆ្នាំមុន ។ នៅជប៉ុន ទំនិញប្រើប្រាស់ ក៏មានអតិផរណាខ្ពស់ដែរគឺ ១,៤% ធៀបនឹងអត្រាអវិជ្ជមានកាលពីមួយឆ្នាំមុន -0,១% ។ នៅសហរដ្ឋអាមេរិក និង ជប៉ុន ទំនិញប្រើប្រាស់មានអតិផរណាខ្ពស់ដោយសារជាសំខាន់មានកំណើនថ្លៃម្ហូបអាហារ និងថាមពល ។

នៅត្រីមាសទី២ ឆ្នាំ២០០៨ នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ប្រាក់ដុល្លារUS ឡើងថ្លៃទល់នឹង ប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន ១០១៨,៨វ៉ុន/ដុល្លារUS ប៉ុន្តែវាធ្លាក់ថ្លៃទល់នឹង ប្រាក់យ៉ុនចិន ប្រាក់យ៉េនជប៉ុន និងប្រាក់អឺរ៉ូ ដោយប្តូរបាន ៦,៩យ៉ុន/ដុល្លារUS ១០៤,៥យ៉េន/ដុល្លារUS និង 0,៦អឺរ៉ូ/ដុល្លារUS ។ ទល់នឹងប្រាក់ដុល្លារហុងកុង និងប្រាក់បាតថៃ ប្រាក់ដុល្លារUS នៅថេរដដែល ធៀបនឹងត្រីមាសមុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០០៨ ការប្រមើលឃើញសំរាប់ផលិតករខាងកសិកម្ម នៅតែល្អប្រសើរដដែល ព្រោះ ចាប់តាំងពីត្រីមាសទី៣ និងទី៤ ឆ្នាំ២០០៧ មក ពោត ប្រេងឆា សណ្តែកសៀង និងអង្ករ នៅតែបន្តឡើងថ្លៃ ដោយពោតឡើងថ្លៃ ៦៣%, ប្រេងឆា ៥៧%, សណ្តែកសៀង ៨៥%, និង អង្ករឡើងថ្លៃមួយជាបី ធៀបនឹងកាលពីមួយឆ្នាំមុន ។ ប្រេងឆៅឡើងថ្លៃជិត ៨០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដល់ ១១៧,៥ដុល្លារUS/ធុង ហើយសាំង និងម៉ាស៊ូតឡើងថ្លៃ ៤០% និង ៧៧% ។ ការឡើងថ្លៃថាមពល និងការធ្លាក់ចុះទំនុកចិត្តរបស់អ្នកប្រើប្រាស់ក្នុងស្រុក បានបង្កការបារម្ភដល់ប្រទេសដែលពឹងផ្អែកលើការនាំចេញ ដូចជា សហរដ្ឋអាមេរិក ជប៉ុន ចិន ឥណ្ឌា និង សហគមន៍អឺរ៉ុប ៕

*រៀបរៀងដោយ*

*សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q2 | 2007 Q3 | 2007 Q4 | 2008 Q1 | 2008 Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | 10.1 | 8.1 | 13.6 | - | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | 6.4 | 6.5 | 6.5 | 6.3 | 6.4 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 5.7 | 6.7 | 7.3 | 7.1 | 6.3 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 8.2 | 8.9 | 6.0 | 7.2 | 1.9 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 4.4 | 4.8 | 5.7 | 6.0 | 5.3 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.5 | 11.4 | 11.2 | 10.6 | 10.1 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 6.9 | 6.2 | 6.7 | 6.8 | 4.2 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 4.5 | 5.2 | 5.7 | 5.7 | 4.8 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 5.07 | 6.9 | 6.4 | 6.4 | 4.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 2.5 | 2.7 | 2.2 | 2.2 | 1.4 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 2.3 | 1.9 | 2.0 | 1.3 | 1.0 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 3.8 | 4.9 | 2.5 | 2.5 | 2.8 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q2 | 2007 Q3 | 2007 Q4 | 2008 Q1 | 2008 Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 4.6 | 6.0 | 9.6 | 16.5 | 24.9 |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.0 | 6.5 | 6.7 | 7.6 | 10.1 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 1.4 | 1.8 | 2.2 | 2.6 | 4.8 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 1.0 | 2.7 | 4.1 | 6.6 | 7.5 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 1.9 | 1.7 | 2.9 | 5.0 | 7.7 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 7.4 | 8.6 | 10.7 | 16.4 | 24.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 3.6 | 6.1 | 6.6 | 8.0 | 7.8 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 1.3 | 1.6 | 3.5 | 4.6 | 5.7 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.4 | 2.3 | 3.3 | 3.7 | 4.8 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 0.3 | 1.4 | 4.5 | 2.3 | 4.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.9 | 1.9 | 2.9 | 3.4 | 3.8 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | -0.1 | -0.1 | 0.5 | 1.0 | 1.4 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 2.7 | 2.4 | 3.9 | 4.1 | 4.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q2 | 2007 Q3 | 2007 Q4 | 2008 Q1 | 2008 Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4065.7 | 4078 | 4026 | 3995.3 | 4030.3 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 8968.3 | 9257.8 | 9246.3 | 9248.2 | 9265.3 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.43 | 3.46 | 3.35 | 3.22 | 3.21 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.52 | 1.52 | 1.45 | 1.41 | 1.37 |
| ថៃ (បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 32.5 | 31.4 | 33.87 | 32.37 | 32.25 |
| វៀតណាម (ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,070 | 16,206 | 16,084 | 15,896 | 16,881 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.68 | 7.55 | 7.43 | 7.16 | 6.96 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.82 | 7.81 | 7.77 | 7.79 | 7.80 |
| កូរ៉េខាងត្បូង (វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 929 | 927 | 921.23 | 955.89 | 1018.84 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 33.1 | 32.9 | 32.4 | 31.52 | 30.45 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.74 | 0.73 | 0.69 | 0.7 | 0.64 |
| ជប៉ុន (យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 120.8 | 117.7 | 113.07 | 105.2 | 104.53 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q2 | 2007 Q3 | 2007 Q4 | 2008 Q1 | 2008 Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 146.10 | 139.81 | 156.9 | 198.39 | 238.03 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 691.44 | 745.86 | 841.39 | 1048.49 | 1086.89 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 283.89 | 304.75 | 323.92 | 444.43 | 839.58 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 259.95 | 299.99 | 366.59 | 449.64 | 479.97 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 65.41 | 72.48 | 82.88 | 93.77 | 117.48 |
| សាំង - US Gulf Coast (សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 57.93 | 55.49 | 59.48 | 64.21 | 80.90 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 53.90 | 56.62 | 66.54 | 73.99 | 95.37 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០០៨ អនុមតិគំរោងវិនិយោគសរុប កើនឡើងយ៉ាងខ្លាំង ដល់ ៤១៧៦,៥លានដុល្លារ ធៀបនឹង ២៥៣,៤លានដុល្លារ នៅត្រីមាសមុន ។ កំនើននេះបានមកពីកំនើនយ៉ាងខ្ពស់នៃអនុមតិគំរោងសេវាកម្ម ដល់ ៤០៦៤,៩លានដុល្លារ ធៀបនឹង ១៤៨,២លានដុល្លារ នៅត្រីមាសមុន ដែលក្នុងនោះ ៩៤% បានមកពីការវិនិយោគអភិវឌ្ឍឆ្នេរសមុទ្រកោះកុងរបស់អ្នកវិនិយោគចិន ។ ទន្ទឹមគ្នានេះ អនុមតិគំរោងវិនិយោគខាងឧស្សាហកម្មកើន ៧៣% ធៀបនឹងត្រីមាសមុន ដល់ ៩១,៣លានដុល្លារ ដែលក្នុងនោះ អនុមតិគំរោងកាត់ដេរកើន ១៣% ដល់ ៤៧,៨លានដុល្លារ ។ អនុមតិគំរោងកសិកម្ម ធ្លាក់ចុះ ៦១% មកត្រឹម ២០,៤លានដុល្លារ ។ គំរោងបានអនុម័តក្នុងគ្រប់វិស័យ មានសរុប ២៩គំរោង ក្នុងនោះ ខាងឧស្សាហកម្មមាន ២៤គំរោង, សេវាកម្មមាន ៣គំរោង និងកសិកម្ម ២គំរោង ។ ប្រសិនបើគំរោង ទាំងអស់បានអនុវត្តពេញលេញ គេត្រូវការកម្លាំងពលកម្មសរុបប្រមាណ ៦២.៦១៥នាក់ ក្នុងនោះ ខាងសេវាកម្មត្រូវការ ៣១.២៥៤នាក់, កសិកម្ម ២០២៤នាក់ និង ឧស្សាហកម្ម ២៩.៣៣៧នាក់ ។

អាគារខ្ពស់ៗដែលកំពុងសាងសង់នៅក្រុងភ្នំពេញ បង្ហាញពីការរីកចំរើនខាងផ្នែកសាងសង់ ។ សកម្មភាពពាណិជ្ជកម្មធំៗ និងកំណើនប្រជាជនក្នុងទីក្រុង បានបង្កើតសក្តានុពលខាងសំណង់កាន់តែច្រើនឡើង ។ នៅអំឡុងត្រីមាសទី២ ឆ្នាំ២០០៨ អនុមតិគំរោងសាងសង់សរុបនៅភ្នំពេញកើន ២,៦% ធៀបនឹង ត្រីមាសមុន ដល់ ១៤០,៩លានដុល្លារ ។ អនុមតិគំរោងសាងសង់ផ្ទះល្វែងកើន ៣៥% ដល់ ៥៥,១លានដុល្លារ រីឯអនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ថយចុះ ៦១% មកត្រឹម ១៧,៦លានដុល្លារ ។ ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៧ អនុមតិគំរោងសាងសង់សរុប ថយចុះ ២,៦% ។

នៅត្រីមាសទី២ ឆ្នាំ២០០៨ កម្ពុជា មានឱនភាពពាណិជ្ជកម្មកាន់តែធ្ងន់ធ្ងរដល់ ៦៣៨,៩លានដុល្លារ ធៀបនឹង ១៨០,៧លានដុល្លារ នៅត្រីមាសមុន ។ ការនាំចេញធ្លាក់ចុះប្រហែល ២៤% មកត្រឹម ៥៣៩,៦លានដុល្លារ ដែលក្នុងនោះ ការនាំចេញផលិតផលកាត់ដេរធ្លាក់ចុះ ៤០% ធៀបនឹងត្រីមាសមុន មកត្រឹម ៤៦៣,៨លានដុល្លារ រីឯការនាំចេញផលិតផលកសិកម្មចំនួន ៣មុខ កើន ៤៦% ដល់ ១១,៣លានដុល្លារ ។ ការនាំចេញកៅស៊ូកើន ៥៧% ដល់ ១១,០លានដុល្លារ រីឯការនាំចេញត្រីថយចុះ ៥៨% មកត្រឹម ០,៣លានដុល្លារ ។ ដោយសារការនាំចេញសំលៀកបំពាក់រួមចំណែកយ៉ាងសំខាន់ដល់ ការនាំចេញសរុប ការធ្លាក់ចុះការនាំចេញខាងផ្នែកនេះ ធ្វើឱ្យការនាំចេញសរុបធ្លាក់ចុះគួរអោយកត់សំគាល់ ។ ការថយចុះការនាំចេញវាយនភ័ណ្ឌ អាចបណ្តាលមកពីការថយចុះតំរូវការអន្តរជាតិ និងការប្រកួតប្រជែងកាន់តែខ្លាំងនៅក្នុងតំបន់ ។

ការនាំចូលកើន ២០% ធៀបនឹងត្រីមាសមុន ដល់ ១១៧៨,៥លានដុល្លារ ។ ការនាំចូលបារីកើនឡើងមួយជាពីរ ដល់ ៤១,៥លានដុល្លារ, ការនាំចូលស៊ីម៉ង់ត៍កើន ១២% ដល់ ១៣,០លានដុល្លារ រីឯដែកថែបនៅថេរត្រឹម ១៥,៨លានដុល្លារ ។ ការនាំចូលផលិតផលប្រេងកាតកើន ៧,៦% ដល់ ៦៤,៦លានដុល្លារ ។ ការនាំចូលក្រណាត់ និងខោអាវប្រើហើយ កើន ១៣% ធៀបនឹងត្រីមាសមុន ដល់ ១៦,៦លានដុល្លារ ក្នុងនោះ ក្រណាត់កើន ៨,៩% ដល់ ២,០លានដុល្លារ ហើយខោអាវប្រើហើយកើន ១៤% ដល់ ១៤,៦លានដុល្លារ ។

នៅត្រីមាសទី២ ឆ្នាំ២០០៨ ភ្ញៀវមកដល់កម្ពុជា មាននិន្នាការធ្លាក់ចុះជាលក្ខណៈរដូវកាល ។ ភ្ញៀវមកដល់សរុបមានចំនួន ៤៥៤.០៣១នាក់ ឬធ្លាក់ចុះ ៣០% ធៀបនឹងត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាសធ្លាក់ចុះ ៣៥% មកត្រឹម ២៦២.០២៥នាក់ ដែលក្នុងនោះ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបាន ៤៩% ។ ភ្ញៀវមកដល់តាមផ្លូវគោកថយចុះ ១៦% មកត្រឹម ១៨០.៨៨៩នាក់ រីឯភ្ញៀវមកដល់តាមផ្លូវទឹកធ្លាក់ចុះយ៉ាងខ្លាំងអស់ ៥៩% មកត្រឹម ១១.១១៧នាក់ ។ ភ្ញៀវមកសំរាកលំហែធ្លាក់ចុះ ៣២% មកត្រឹម ៣៩៤.១៧៦នាក់ រីឯភ្ញៀវមកធ្វើជំនួញធ្លាក់ចុះ ៣,៤% មកត្រឹម ៣៦.១៨៤ នាក់ ។ ខេត្តសៀមរាបទទួលបានភ្ញៀវ ២២២.៤០៤នាក់ ។ កូរ៉េខាងត្បូងជាប្រទេសនាំមុខគេខាង ភ្ញៀវធ្វើដំណើរមកដល់កម្ពុជា ដោយមាន ៦២.៩១០នាក់ បន្ទាប់មក គឺវៀតណាម ៥១.៨៨៩នាក់ និងថៃ ៣២.០២៨នាក់ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឆ្នាំ២០០៨ ប្រតិបត្តិការថវិការបស់រដ្ឋាភិបាលមានសភាពកាន់តែយ៉ាប់យ៉ឺនឡើង ។ ថវិកាមានឱនភាព ២៨១,១ពាន់លានរៀល ធៀបនឹងត្រីមាសមុនដែលថវិកាមានអតិរេក ១៣៥,០ពាន់លានរៀល ។ ចំនូលសរុប រួមទាំងចំនូលពន្ធ និងមិនមែនពន្ធ កើន ២៣% ដល់ ១៤៦៣,៦ពាន់លានរៀល ។ ពន្ធក្នុងស្រុកកើន ៣៣% ដល់ ៩៥៥,៥ពាន់លានរៀល រីឯពន្ធលើពាណិជ្ជកម្មអន្តរជាតិកើន ១៦% ដល់ ២៩៩,៥ពាន់លានរៀល ។ ចំនូលពន្ធសរុបកើន ២៨% ដល់ ១២៥៥,០ពាន់លានរៀល ។ ចំនូលមិនមែនពន្ធធ្លាក់ចុះ ៩,១% មកត្រឹម ១៩២,១ពាន់លានរៀល ដែលក្នុងនោះ ការលក់ទំនិញ និងសេវាកម្ម រួមទាំង កំរៃរដ្ឋបាលយកលើវិស័យឯកជន និងការបើកក្រុមហ៊ុនថ្មីផងធ្លាក់ចុះ ១៩% មកត្រឹម ៩៦,៣ពាន់លានរៀល ។ ចំនូលបានពីទ្រព្យសម្បត្តិ កើនយ៉ាងខ្លាំង ដល់ ៥៣,៩ពាន់លានរៀល ធៀបនឹងចំនូល ២,៩ពាន់លានរៀលនៅត្រីមាសមុន ដោយកំនើននេះបានជាចំបងពីថ្លៃឈ្នួលដី (២៨,៤ពាន់លានរៀល) ។ ទន្ទឹមគ្នានេះ ចំនូលមូលធនបានពីវិនិយោគហិរញ្ញវត្ថុផ្សេងៗ កើនពី ៤,៨ពាន់លានរៀល ដល់ ១៦,៥ពាន់លានរៀល ។

នៅត្រីមាសទី២ ចំណាយសរុបកើន ៦៥% ដល់ ១៧៤៤,៧ពាន់លានរៀល ។ ចំណាយចរន្តកើន ៦៩% ដល់ ១០៩៦,៥ពាន់លានរៀល ហើយចំនាយមូលធនកើន ៥៨% ដល់ ៦៤៨,២ពាន់លានរៀល ។ ចំនាយលើប្រាក់បៀវត្សរ៍កើន ៤៦% ដល់ ៣៦៧,០ពាន់លានរៀល ហើយជំនួយសង្គមកើនដល់ ៣២៥,៧ពាន់លានរៀល ។ សំរាប់ចំនាយមូលធនមាន ៣១% ទទួលបានហិរញ្ញប្បទានពីក្នុងស្រុក និង ៦៩% ទទួលបានហិរញ្ញប្បទានពីក្រៅប្រទេស ។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

អតិផរណា បន្តកើនឡើងចាប់តាំងពីត្រីមាសទី២ ឆ្នាំ២០០៧ មក ។ នៅត្រីមាសទី២ ឆ្នាំ២០០៨ ថ្លៃទំនិញទូទៅពីមួយឆ្នាំទៅមួយឆ្នាំ កើន ២៤,៩% ធៀបនឹងកំណើន ១៦,៥% នៅត្រីមាសមុន ។ ក្នុងរយៈ១២ខែ ដល់ត្រីមាសទី២ ឆ្នាំ២០០៨ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៤៣,៥% ធៀបនឹងកំណើន ២៧,៦% នៅត្រីមាសមុន និងកំណើន ៤,៦% នៅត្រីមាសទី២ឆ្នាំមុន ។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ (NIS) ប្រជាជនកម្ពុជាចំនាយជាចំបងប្រហែល ៣៩% នៃចំនាយសរុបរបស់ខ្លួនទៅលើម្ហូបអាហារ ។ ការដឹកជញ្ជូនបានជះឥទ្ធិពលដោយប្រយោលលើការឡើងថ្លៃម្ហូបអាហារ ។ ក្នុងរយៈ១ឆ្នាំដល់ ត្រីមាសទី២ ឆ្នាំ២០០៨ ចំនាយលើការដឹកជញ្ជូនកើន ២៥,៣% ហើយអត្រាកំនើនប្រចាំឆ្នាំ គឺ ១៨,៨% នៅត្រីមាសមុន និង ៥,០% នៅឆ្នាំមុន ។ ចំនាយលើការថែទាំសុខភាព កើន ១៦,៧% ក្នុងរយៈ១២ខែ រីឯអត្រាកំណើន គឺ ១៦,២% នៅត្រីមាសមុន និង ១,៥% នៅឆ្នាំមុន ។

នៅអំឡុងត្រីមាសទី២ ឆ្នាំ២០០៨ ប្រាក់រៀលធ្លាក់ថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារUS ដោយប្តូរបាន ៤០៣០,២រៀល/ដុល្លារUS ។ ធៀបនឹងត្រីមាសមុន ប្រាក់រៀលឡើងថ្លៃ ២,៩% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១២៥,៤រៀល/បាត ហើយឡើងថ្លៃ ១,២% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ២៤,៩រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែមិថុនា ២០០៨ រូបិយវត្ថុទូទៅ (M2) កើន ៤៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ១២.៦៩៧,៩ ពាន់លានរៀល ។ ប្រាក់រៀលចរាចរកើន ៤០% ដល់ ២៣៤៨,៧ពាន់លានរៀល ហើយបញ្ញើជារៀលកើន ៦២% ដល់ ២៦៧,៨ពាន់លានរៀល ។ ចំំនែកបញ្ញើជាដុល្លារកើន ៤៣% ដល់ ១០.០៨១,៣ពាន់លានរៀល ។

នៅខែមិថុនា ២០០៨ ឥណទានក្នុងស្រុកដែលជាទ្រព្យសកម្មមួយរបស់ធនាគារកណ្តាល កើនដល់ ៦៥២៧,៣ពាន់លានរៀល ធៀបនឹងឥណទាន ៣១៣៦,១ពាន់លានរៀល នៅឆ្នាំមុន ។ ក្នុងនោះ ឥណទានដល់វិស័យឯកជន កើនឡើងមួយជាពីរ ដល់ ៩២០៥,៨ពាន់លានរៀល រីឯ ឥណទានដល់រដ្ឋាភិបាល ថយចុះ ៩,១% មកត្រឹម ២៧០,៥ពាន់លានរៀល ។ បញ្ញើរបស់រដ្ឋាភិបាលកើន ៧៣% ដល់ ២៩៤៨,៨ពាន់លានរៀល ។ ប្រាក់បញ្ញើតាមកំហិត មូលធន និង បំណុលផ្សេងៗ ដែលតំកល់ទុកនៅធនាគារកណ្តាល កើន ៥៧% ដល់ ៥១៨២,១ពាន់លានរៀល ។ ឥណទានក្នុងស្រុក និង បំណុលផ្សេងៗ បានផ្តល់ជាសញ្ញាវិជ្ជមានសំរាប់ទ្រព្យសកម្មក្នុងស្រុកសុទ្ធ (១៣៤៥,៣ពាន់លានរៀល) ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ២៥% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១១.៣៥២,៦ពាន់លានរៀល ៕

*រៀបរៀងដោយ ប៉ុន ដូរីណា និង ផាន់ ដាលីស*

---

*តពីទំព័រ ២៣* **ព័ត៌មានថ្មីៗ ...**

ផ្នែកនេះបានរៀបចំការបណ្តុះបណ្តាលស្តីពីការចុះអង្កេតជាមូលដ្ឋាន និងបានធ្វើតេស្តសាកល្បង ប្រើបញ្ជីសំនួរ នៅមុនពេលចុះធ្វើអង្កេតទ្រង់ទ្រាយធំ ។

*ផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ* បានបញ្ចប់រួចរាល់នូវការប្រមូលទិន្នន័យបែបគុណភាពនៅ ភូមិគោលដៅចំនួន ៩ សំរាប់ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ហើយការងារនេះបានដំណើរការតាមពេលកំនត់ ។ បុគ្គលិកម្នាក់បានចូលរួមវគ្គបណ្តុះបណ្តាលមួយនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ស្តីពី "ការបំបាត់ភាពក្រីក្រតាមរយៈវិធីសាស្ត្ររាប់បញ្ចូលរបស់សង្គមៈ ស្ថានភាពបច្ចុប្បន្ននៃទ្វីបអាស៊ី និងអូសេអានី នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកល" ដែលរៀបចំដោយបណ្តាញជប៉ុន-អាស៊ីខាងកើតសំរាប់ការផ្លាស់ប្តូរសិស្ស-និស្សិត និងយុវជន (JENESYS) ។ បុគ្គលិកម្នាក់បានចូលរួម សន្និសីទបណ្តាញគោលនយោបាយស្រាវជ្រាវពីគោលនយោបាយសេដ្ឋកិច្ច (Policy Economic Policy Research Network: PEP) លើកទី៧ និងការប្រជុំទូទៅ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្រោមប្រធានបទ "ការជំជែកដេញដោលពី ផលប៉ះពាល់នៃការឡើងថ្លៃទំនិញ ទៅលើភាពក្រីក្រ និងការវិភាគពីភាពក្រីក្រ" ហើយបុគ្គលិកម្នាក់ទៀតបានចូលរួមការប្រជុំថ្នាក់តំបន់នៅទីក្រុងម៉ានីលដែរ ស្តីពី "ការកែលំអសុខភាពរបស់ក្មេងជំទង់" ។ ការវិភាគទិន្នន័យសំរាប់ គំរោងវិភាគស្ថានភាពយុវជន ដោយសហការជាមួយកម្មវិធីអភិវឌ្ឍន៍សង្គម ត្រូវបានបញ្ចប់រួចរាល់ ។ របាយការណ៍ព្រាងដំបូងបានទទួលការជួយយោបល់ ហើយរបាយការណ៍ព្រាងលើកទី២ បានដាក់ជូនសុំយោបល់ចុងក្រោយហើយ ។ ឯកសារសង្ខេបគោលនយោបាយស្តីពី ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារលើសន្តិសុខស្បៀង ផលិតផល កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ កំពុងរៀបចំចងក្រង ។

ចាប់ពីតាំងឆ្នាំ២០០៧ ជារៀងរាល់ពីរខែម្តង វិទ្យាស្ថាន CDRI រៀបចំធ្វើសិក្ខាសាលាស្រាវជ្រាវមួយខ្សែ លើបញ្ហាអភិវឌ្ឍន៍ ដើម្បីចែករំលែករបកគំហើញនៃការស្រាវជ្រាវនិងពង្រឹងគុណភាពស្រាវជ្រាវតាមរយៈការពិភាក្សាលើលទ្ធផលការកែលំអវិធីសាស្ត្រស្រាវជ្រាវ ព្រមទាំង ការបង្កើតគោលគំនិត និងការវិភាគលើប្រធានបទស្រាវជ្រាវ ។ អ្នកផ្តល់បទបង្ហាញក្នុងសិក្ខាសាលាទាំងនេះ មានមកពីវិទ្យាស្ថានCDRI និង ស្ថាប័ន/អង្គការមិនមែនរដ្ឋាភិបាលនានា នៅទីក្រុងភ្នំពេញ ។ ចាប់ពីខែកញ្ញាមក អ្នកផ្តល់បទបង្ហាញមកពីខាងក្រៅ CDRI មានដូចជា បណ្ឌិត Alexander C. Chandra ទីប្រឹក្សានយោបាយជាន់ខ្ពស់ស្តីពីអាស៊ាន មកពី Oxfam, លោកស្រី ហាក់ សុចន្ទី និងក្រុមការងារមកពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ។ ចំំនែកអ្នកធ្វើបទបង្ហាញមកពី CDRI វិញ មានដូចជា បណ្ឌិត ហ៊ាន ភូមិន្ទ លោក នេត នាថ និង កញ្ញា អ៊ូច ច័ន្ទតារ៉ានី ។ ប្រធានបទមានជាអាទិ ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ចពាណិជ្ជកម្ម និង ធនធានធម្មជាតិនិងកសិកម្ម ៕

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 0.0 | 154.6 | 19.1 | 2.1 | 12.0 | 102.4 | 52.3 | 20.4 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 171.7 | 76.6 | 142.7 | 51.2 | 187.2 | 328.0 | 52.9 | 91.3 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *23.2* | *26.1* | *36.6* | *24.3* | *40.7* | *69.1* | *42.3* | *47.8* |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 94.5 | 740.7 | 335.7 | 138.0 | 957.7 | 311.1 | 148.2 | 4064.9 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *3.5* | *315.3* | *140.3* | *55.0* | *653.8* | *199.2* | *93.7* | *4015* |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 | 4176.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -88.6 | 265.1 | -48.8 | -61.6 | 504.7 | -35.9 | -78.1 | 1548.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | -34.1 | 715.4 | 118.9 | 91.8 | 334.6 | -23.7 | -49.1 | 2083.2 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 7.6 | 9.7 | 14.4 | 22.8 | 21.7 | 20.2 | 45.3 | 17.6 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 67.1 | 54.5 | 88.9 | 33.2 | 117.5 | 57.6 | 40.9 | 55.1 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 20.8 | 13.9 | 35.9 | 88.8 | 40.6 | 94.3 | 51.2 | 68.2 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 95.5 | 78.2 | 139.2 | 144.7 | 179.7 | 172.2 | 137.3 | 140.9 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 16.1 | -18.1 | 78.0 | 3.9 | 24.2 | -4.2 | -1.4 | 2.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | 24.8 | 8.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 | -2.6 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 807.5 | 736.7 | 707.8 | 705.0 | 890.8 | 793.4 | 803.1 | 539.6 |
| រួមមាន: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027 | 2253.3 | 782.0 | 716.0 | 677.5 | 688.2 | 846.1 | 727.1 | 773.4 | 463.8 |
| *- ទៅសហរដ្ឋអាមេរិក* | 943.4 | 1099.8 | 1270.9 | 1546.1 | 522.8 | 483.2 | 499.1 | 451.2 | - | - | - | - |
| *- ទៅសហគមន៍អឺរ៉ុប* | 356.3 | 414.7 | 590.8 | 503.1 | 188.1 | 160.1 | 106.3 | 163.1 | - | - | - | - |
| *- ប្រទេសផ្សេងទៀត* | 56.1 | 113.8 | 165.3 | 204.1 | 71.0 | 72.8 | 72.0 | 73.8 | - | - | - | - |
| កសិកម្ម | 97.3 | 79.7 | 81.2 | 99.5 | 25.5 | 20.7 | 30.3 | 16.8 | - | - | - | - |
| *- កៅស៊ូ* | 29.7 | 35.1 | 38.3 | 36.7 | 13.6 | 10.2 | 8.4 | 6.9 | 11.7 | 14.6 | 7.0 | 11.0 |
| *- ឈើ* | 16.0 | 10.2 | 11.1 | 10.3 | 2.5 | 1.7 | 2.1 | 2.0 | 0.0 | 0.0 | 0.0 | 0.0 |
| *- ត្រី* | 4.3 | 2.8 | 10.6 | 10.1 | 1.6 | 1.4 | 0.7 | 0.4 | 1.2 | 0.9 | 0.7 | 0.3 |
| *- ផ្សេងៗ* | 47.4 | 31.6 | 21.3 | 42.6 | 7.7 | 7.5 | 19.0 | 7.5 | - | - | - | - |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513.0 | 784.3 | 807.1 | 790.9 | 911.6 | 924.5 | 982.7 | 983.8 | 1178.5 |
| រួមមាន: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 62.4 | 58.7 | 66.5 | 68.5 | 71.0 | 58.9 | 60.0 | 64.6 |
| សាំង | 25.9 | 33.2 | 30.2 | 40.2 | 13.1 | 13.2 | 15.7 | 20.2 | - | - | - | - |
| ម៉ាស៊ូត | 100.8 | 109.6 | 109.4 | 93.1 | 30.1 | 27.2 | 31.9 | 36.6 | - | - | - | - |
| សំភារ:សំណង់ | 12.9 | 80.8 | 95.3 | 134.7 | 42.5 | 35.8 | 44.1 | 31.6 | 34.9 | 32.5 | 39.7 | 40.7 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245 | 698.5 | 731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 | 1073.2 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | 23.2 | -70.4 | -83.1 | -208.1 | -30.7 | -189.3 | -180.7 | -638.9 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | 23.6 | -8.4 | -5.4 | 1.6 | 22.9 | -14.1 | 6.4 | -40.0 |
| ការនាំចេញសរុប | - | - | - | - | 23.7 | -8.8 | -3.9 | 0.4 | 26.4 | -10.9 | 1.2 | -32.8 |
| ការនាំចូលសរុប | - | - | - | - | 1.2 | 2.9 | -2.0 | 15.3 | 1.4 | 6.3 | 0.1 | 19.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | -54.1 | -64.9 | 291.4 | 10.2 | 19.1 | 19.2 | 8.8 | 8.2 | 1.6 | 14.2 | -32.6 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 10.6 | 14.3 | 17.3 | 8.0 | 10.3 | 7.7 | 13.5 | -23.5 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 24.0 | 16.8 | 14.5 | 17.6 | 17.9 | 21.7 | 24.4 | 29.3 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by NBC*

តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 224.2 | 325.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 | 262.0 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 146.4 | 191.0 | 177.2 | 148.9 | 153.3 | 239.2 | 242.2 | 192.0 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 370.6 | 516.0 | 550.8 | 424.5 | 431.8 | 608.0 | 644.2 | 454.0 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 4.1 | 39.2 | 6.7 | -22.9 | 1.7 | 40.8 | 6.0 | -29.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 14.7 | 24.1 | 20.4 | 19.2 | 16.5 | 17.8 | 17.0 | 6.9 |

*Source: Ministry of Tourism*

### តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០២-០៨ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 1744 | 1764 | 2126 | 2625 | 732.2 | 1199.6 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 | 1463.6 |
| ចំណូលចរន្ត | 1728 | 1733 | 2107 | 2474 | 716.8 | 844.9 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 | 1447.0 |
| ចំណូលពន្ធ | 1227 | 1220 | 1577 | 1911 | 565.8 | 661.8 | 699.9 | 887.7 | 844.6 | 965.2 | 978.0 | 1255.0 |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 | 955.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 | 299.5 |
| ចំណូលមិនមែនពន្ធ | 501 | 513 | 530 | 563 | 151.0 | 183.1 | 125.0 | 124.7 | 186.9 | 176.4 | 211.4 | 192.1 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 | 53.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 | 96.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | - | - | 8.3 | 16.2 | 72.0 | 38.5 | 89.6 | 41.9 |
| ចំណូលជាមូលធន | 16 | 31 | 19 | 152 | 15.4 | 354.7 | 0.0 | 4.5 | 0.0 | 4.5 | 4.8 | 16.5 |
| ចំណាយសរុប | 2948 | 2757 | 2932 | 3295 | 1030.6 | 1191.9 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 | 1744.7 |
| ចំណាយជាមូលធន | 1388 | 1171 | 1163 | 1328 | 423.8 | 429.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 | 648.2 |
| ចំណាយចរន្ត | 1560 | 1586 | 1769 | 1967 | 606.9 | 762.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 | 1096.5 |
| បៀវត្សរ៍ | 587 | 615 | 640 | 711 | 230.6 | 240.6 | 199.7 | 242.7 | 253.4 | 362.6 | 250.7 | 367.0 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 | 325.7 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | - | - | 295.2 | 254.9 | 402.6 | 325.5 | 193.1 | 403.8 |
| សមតុល្យជាទូទៅ | -1204 | -993 | -806 | -706 | -298.5 | 7.7 | -99.0 | -81.9 | -78.7 | -543.6 | 135.0 | -281.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249 | 886 | 864 | 1127 | 335.2 | 376.2 | 344.0 | 313.9 | 290.3 | 741.5 | 299.2 | 615.8 |
| ហិរញ្ញប្បទានក្នុងស្រុក | -45 | 106 | 148 | -396 | -36.7 | -383.9 | -245.0 | -213.0 | -148.0 | -185.8 | -294.1 | -236.5 |

*Provisional for 2007. Source: MEF web site. * revised data*

### តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (October-December 2006:100) | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ខេត្ត | 0.9 | 4.4 | 14.4 | 16.4 | 8.5 | 7.2 | 4.2 | 4.6 | - | - | - | - |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 3.3 | 1.1 | 3.9 | 5.8 | 4.9 | 3.4 | 3.0 | 4.6 | 6.0 | 9.7 | 16.5 | 24.9 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.8 | 1.5 | 6.4 | 8.6 | 5.8 | 3.3 | 3.0 | 7.2 | 11.3 | 18.1 | 27.6 | 43.5 |
| - ដឹកជញ្ជូន | 0.3 | 4.9 | 9.7 | 11.4 | 10.1 | 6.8 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 | 4030.2 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 110.3 | 113.0 | 113.7 | 118.0 | 130.0 | 129.3 | 129.1 | 125.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 24.9 | 25.0 | 24.6 | 24.7 | 25.3 | 25.2 | 25.2 | 24.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 73.0 | 72.8 | 77.7 | 79.8 | 80.8 | 94.4 | 111.6 | 107.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521 | 1508 | 2088 | 2633 | 3333 | 3250 | 3067 | 3100 | 3203 | 3679 | 3982 | 4975 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084 | 2150 | 2833 | 3442 | 4200 | 4050 | 3750 | 3900 | 4002 | 4368 | 4580 | 5171 |

*Sources: NIS, NBC & CDRI. *The data for consumer price index are available to January 2008.*

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | | 2007 | | | | 2008 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ពាន់លានរៀល | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737 | 4027 | 4797 | 5475 | 6958 | 7224 | 8056 | 9048 | 9768 | 10735 | 10911 | 11353 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849 | -698 | -467 | -450 | -497 | -282 | -263 | -172 | 140 | 576 | 1136 | 1345 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119 | -128 | -209 | -421 | -892 | -953 | -1176 | -1403 | -1547 | -1816 | -2400 | -2678 |
| ឥណទានដល់ផ្នែកឯកជន | 1059 | 1337 | 1817 | 2394 | 3288 | 3628 | 4066 | 4537 | 5376 | 6386 | 8050 | 9206 |
| រូបិយវត្ថុទូទៅ M2 | 2888 | 3329 | 4330 | 5025 | 6461 | 6942 | 7793 | 8876 | 9908 | 11311 | 12047 | 12698 |
| រូបិយវត្ថុ M1 | 813 | 937 | 1153 | 1323 | 1563 | 1658 | 1794 | 1748 | 1750 | 2052 | 2389 | 2467 |
| រូបិយវត្ថុផ្សេងៗ | 2075 | 2392 | 3177 | 3702 | 4898 | 5285 | 5999 | 7128 | 8158 | 9259 | 9658 | 10231 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 29.4 | 38.2 | 36.5 | 46.8 | 53.4 | 62.9 | 54.5 | 43.1 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 22.2 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 | 41.1 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 31.9 | 42.7 | 40.7 | 57.3 | 66.5 | 75.2 | 61.0 | 43.5 |

*Source: National Bank of Cambodia*

### តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2007 | | |
| | វិច្ឆិកា | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

* *Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ ...**

**ផ្នែកស្រាវជ្រាវ**

ពីខែកញ្ញា ដល់ ធ្នូ ២០០៨ វិទ្យាស្ថាន CDRI មានសកម្មភាពស្រាវជ្រាវ និងសកម្មភាពទាក់ទងនឹងការស្រាវជ្រាវ តាមផ្នែកជំនាញដូចតទៅ:

*ផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ* បានបង្ហើយឯកសារពិភាក្សាចំនួន ២ ដំបូង លើការសិក្សាស្ដីពីការដឹកនាំក្នុងនយោបាយនៅតាមមូលដ្ឋានប្រទេសកម្ពុជា ។ ដោយផ្អែកលើការសិក្សាទាំងមូល អត្ថបទសង្ខេបមួយបានតាក់តែងឡើងសំរាប់របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ។គំរោងខាងអភិបាលកិច្ចធនធានទឹក បានចងក្រងផ្នែកផ្សេងៗនៃរបាយការណ៍ ហើយបង្កើតបានជាឯកសារព្រាងដំបូងសំរាប់ការពិនិត្យផ្ទៀងផ្ទាត់ផ្ទៃក្នុង នៅដើមខែមករា ២០០៩ ។ ក្រុមប្រឹក្សាដែលមានភារកិច្ចជួយ រៀបចំគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដើម្បីកសាងកម្មវិធីជាតិសំរាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្ដល់របាយការណ៍បំផុសគំនិតចំនួនពីរ ស្ដីពីច្បាប់អង្គការ និងស្ដីពីការផ្ទេរមុខងារ ។ សិក្ខាសាលាផ្លាស់ប្ដូរយោបល់មួយចំនួន បានរៀបចំឡើងដើម្បីផ្សព្វផ្សាយពី គោលបំណងនៃកំណែទម្រង់វិសហមជ្ឈការ ទិសដៅធំៗសំរាប់បណ្ដាក្រសួងពាក់ព័ន្ធ ការផ្ទេរមុខងារ និង ជំរើសសំរាប់ការផ្ទេរ ។ សិក្ខាសាលាសំខាន់មួយទៀតបានធ្វើឡើង ដើម្បីប្រមូលមតិ/ព័ត៌មានត្រឡប់លើការប្រជុំលើកមុនៗ ។ ផ្នែកនេះបានអនុវត្តសឹងតែរួចរាល់ ការធ្វើអង្កេតសំរាប់គំរោងស្ដីពីថវិកា នយោបាយ និងការអភិវឌ្ឍតំបន់ជនបទកម្ពុជា និងបានធ្វើបទបង្ហាញផ្ទៃក្នុងមួយ ដើម្បីបង្ហាញពីរបកគំហើញដំបូងៗ និងប្រមូលមតិ/ព័ត៌មានត្រឡប់ផ្សេងៗ ។គំរោងសិក្សាថ្នាក់បណ្ឌិតស្ដីពី ប្រជាធិបតេយ្យនិងវិសហមជ្ឈការនៅកម្ពុជាក្រោយពេលបញ្ចប់ជំលោះ បានឈានដល់ដំណាក់កាលបញ្ចប់ហើយ ។

*ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់* បានបង្ហើយការធ្វើអង្កេតពីទស្សនៈរបស់ ពួកអ្នកគ្រប់គ្រង ដើម្បីធ្វើការវាយតំលៃពីតំរូវការ និងឱកាសនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មផ្នែកសេវាកម្ម ហើយរបាយការណ៍សំរេចនៃអង្កេតនេះក៏បានសរសេររួចរាល់ សំរាប់ដាក់ជូនអ្នកពាក់ព័ន្ធពិនិត្យនៅដើមខែធ្នូនេះ ។ សេចក្ដីព្រាងឯកសារសង្ខេបសំរាប់គោលនយោបាយ ចំនួន ៣ លើការសិក្សាពីភាពប្រកួតប្រជែង បានបង្ហើយរួចរាល់ ហើយបញ្ជីសំនួរសំរាប់ការប្រមូលទិន្នន័យបែបបរិមាណ និងបែបគុណភាព ក៏បានតាក់តែងរួចរាល់ដែរ ។ការប្រមូលទិន្នន័យសំរាប់ការសិក្សាពីការនាំចេញសេវាកម្ម បានរីកលូតលាស់ទៅមុខ ហើយក្រុមស្រាវជ្រាវក៏បាន ចាប់ផ្ដើមសរសេរផ្នែកខ្លះនៃរបាយការណ៍នេះដែរ ។ សំរាប់គំរោងកំពុងដំណើរការមួយទៀតដែលសិក្សាពី សេដ្ឋកិច្ចនយោបាយនៃសមាហរណកម្មមហាអនុតំបន់មេគង្គ (GMS) ការងារចុះអង្កេតនឹងចាប់ផ្ដើមនៅខែធ្នូ ហើយការវិភាគទិន្នន័យនិងការរៀបចំរបាយការណ៍ នឹងធ្វើឡើងតាមការគ្រោងទុក ។ អ្នកស្រាវជ្រាវពីរនាក់ បានទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិត នៅប្រទេសអេស្បាញ និងជប៉ុន ។

*ផ្នែកសន្តិសុខមនុស្ស កសាងសន្តិភាព និងបំប្លែងទំនាស់* បានបញ្ចប់ដោយជោគជ័យនូវ វគ្គបណ្ដុះបណ្ដាលស្នូលមួយស្ដីពី "ការកសាងសន្តិភាព" ។នាពេលថ្មីៗក្រុមបណ្ដុះបណ្ដាល បានរៀបចំវគ្គថ្មីមួយទៀតស្ដីពី "តួនាទីសារព័ត៌មានក្នុងការកសាងសន្តិភាព" ដែលមានសារៈសំខាន់ខ្លាំងសំរាប់អោយអ្នកសារព័ត៌មាន បង្កើនការយល់ដឹងពីបញ្ហាពាក់ព័ន្ធនឹងសន្តិភាព និងសារព័ត៌មាន ។ នេះជាវគ្គបណ្ដុះបណ្ដាលលើកទី១របស់ផ្នែកនេះ ដែលផ្ដោតលើអ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ ។ វគ្គនេះបានរៀបចំឡើង ដើម្បីបំពេញតំរូវការដែលពិនិត្យឃើញក្នុងឱកាសចុះវាយតំលៃ នៅមុនពេលរៀបចំការបណ្ដុះបណ្ដាល និងដើម្បីឆ្លើយតបនឹងតំរូវការរបស់សមាគមអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មាន ។ វគ្គនេះសំដៅលើកកម្ពស់ សមត្ថភាពអ្នកសារព័ត៌មានលើជំនាញកសាងសន្តិភាព និងបង្ការទំនាស់ ដែលមានបញ្ចូលទាំងទ្រឹស្ដី និងរបៀបអនុវត្តជាក់ស្ដែងនៃការអប់រំខាងសន្តិភាព វប្បធម៌សន្តិភាព និងវិធីសាស្ត្រអហិង្សា ក្នុងវិស័យផ្សេងៗដែលពួកគេត្រូវធ្វើការ ។ ម៉ូឌុលទី១ បានបង្រៀននៅខែមេសា សំរាប់ថ្នាក់ដឹកនាំ ដែលមានជាអាទិ៍ នាយក ប្រធាន និង/រឺ អ្នកដឹកនាំសមាគមអ្នកសារព័ត៌មាន ហើយម៉ូឌុលទី២ គឺសំរាប់អ្នកយកព័ត៌មាន ។

ក្រុមបណ្ដុះបណ្ដាលនឹងដំណើរការផងដែរនូវ "ការបណ្ដុះបណ្ដាលពិសេស" នៅខេត្តរតនគិរី សំរាប់សមាជិកក្រុមប្រឹក្សាឃុំ ដែលភាគច្រើនជាជនជាតិដើមភាគតិច ។ វគ្គនេះសំដៅបំពេញតំរូវការរបស់ក្រុមអ្នកធ្វើការដែលមានសមត្ថភាពតិចក្នុងមុខជំនាញនេះ ហើយកំពុងតែប្រឈមមុខ នឹងបញ្ហាថ្មីៗ និងលំបាកៗដែលផុសឡើងនៅក្នុងសហគមន៍របស់ពួកគេ ។

*ផ្នែកធនធានធម្មជាតិ និងបរិស្ថាន* បានបញ្ចប់អង្កេតជាមូលដ្ឋានខាងសេដ្ឋកិច្ចសំរាប់ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវពីការគ្រប់គ្រងធនធានទឹក (WRMRCDP) ហើយ បញ្ជីសំនួរពីរប្រភេទ នឹងត្រូវប្រើសំរាប់អង្កេតនេះ ដោយបញ្ជីសំនួរមួយជាម៉ូឌុលស្នូល និងមួយទៀតជាម៉ូឌុលបំពេញបន្ថែម ។ ផ្នែកនេះបានគ្រោងអនុវត្ត ម៉ូឌុលស្នូលនៃអង្កេតសេដ្ឋកិច្ច នៅខែធ្នូ ២០០៨ ។ផ្នែកនេះបានបញ្ជូនបុគ្គលិកពីររូប ទៅចូលរួម សិក្ខាសាលាអន្តរជាតិមួយ នៅទីក្រុងឡុងប្រទេសអង់គ្លេស ស្ដីពី "អេកូឡូស៊ីខាងនយោបាយនៃការស្រាវជ្រាវស្ដីពីការគ្រប់គ្រងធនធានទឹក ក្នុងបរិបទនៃការអភិវឌ្ឍធារាសាស្ត្រ: ករណីសិក្សានៅកម្ពុជា" ។ កញ្ញា ខៀវ ដារ៉ាវី បានវិលត្រលប់ពីការសិក្សានៅសកលវិទ្យាល័យស៊ីដនី និងបានចូលរួមក្នុងកម្មវិធី WRMRCDP ដើម្បីចុះធ្វើអង្កេត សំរាប់កម្មវិធីថ្នាក់អនុបណ្ឌិតរបស់ខ្លួន ។ ផ្នែកនេះ បានបញ្ចប់ការចុះអង្កេតដល់កន្លែងលើកទី៤ សំរាប់គំរោងរួមគ្នាមួយស្ដីពី ព្រៃត្រូពិចសំរាប់ការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសចំនួន ៥ ដោយធ្វើវិភាគតាំងពីទិន្នន័យគ្រួសារ រហូតដល់កំរិតសកល ។ ផ្នែកនេះ ក៏បានរៀបចំសិក្ខាសាលាអន្តរជាតិមួយស្ដីពី "ការវិភាគទិន្នន័យអង្កេតដល់កន្លែង" ដោយមានការចូលរួមពីប្រទេស ហ្គាណា ដាណឺម៉ាក ប៊ឺគីណាហ្វាសូ និងកម្ពុជា ។ គោលបំណងចំបងនៃសិក្ខាសាលា នេះគឺ (១) ណែនាំអ្នកចូលរួមពីកម្មវិធី Stata ដែលជាកម្មវិធីកុំព្យូទ័រមួយសំរាប់វិភាគស្ថិតិ និងទិន្នន័យ (២) ត្រួតពិនិត្យឡើងវិញនូវការចុះអង្កេតដល់កន្លែង និង (៣) ឯកភាពគ្នាពីសកម្មភាពផ្សេងៗសំរាប់ឆ្នាំ២០០៩ ។ គំរោងស្ដីពីការកសាងសមត្ថភាពសហគមន៍សំរាប់ការផ្ដួចផ្ដើមកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប ដែលទទួលថវិកាពី មូលនិធិជប៉ុនសំរាប់កាត់បន្ថយភាពក្រីក្រ បានចុះធ្វើអង្កេតជាមូលដ្ឋានជាបណ្ដើរៗនៅតំបន់ជុំវិញទន្លេសាប ។

*(តទៅទំព័រ ២០)*

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

នៅដើមខែតុលា ២០០៨ សំរាប់ដំណាក់កាលបញ្ចប់នៃការបូកសរុបលទ្ធផលពាក់កណ្តាលអាណត្តិ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-១០ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានសំរាកដកឃ្លាទៅប្រជុំថ្នាក់គ្រប់គ្រង-បុគ្គលិកប្រចាំឆ្នាំរយៈពេលពីរថ្ងៃកន្លះ នៅឯក្រុងព្រះសីហនុក្នុងបំណងជំរុញកំណែលំអគុណភាពស្រាវជ្រាវ ការប្រស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ការពង្រឹងស្មារតីក្រុម និងការកសាងទំនុកចិត្តនៅក្នុង CDRI ។ ការសំរាកដកឃ្លា ទៅប្រជុំលើកនេះ ផ្តោតលើ ១០ចំនុចអាទិភាពដែលក្រុមប្រឹក្សាភិបាលនៃ CDRI បានអនុម័តសំរាប់ឆ្នាំ២០០៨-១០ ហើយនិងដំណោះស្រាយលើ បញ្ហារកឃើញតាមរយៈអង្កេតអំពីកំរិតនៃការពេញចិត្តរបស់បុគ្គលិក និងការពិនិត្យឡើងវិញពីប្រព័ន្ធនិងគោលនយោបាយគ្រប់គ្រងធនធានមនុស្ស ដែលវិទ្យាស្ថាន CDRI បានចុះកិច្ចសន្យាឱ្យក្រុមហ៊ុនមួយធ្វើ ។ តាមការណែនាំពីក្រុមប្រឹក្សាភិបាលនៃ CDRI ចំនុចអាទិភាពសំរាប់រយៈពេលនៅសល់នៃផែនការយុទ្ធសាស្ត្របច្ចុប្បន្ន គឺ ការកសាងយុទ្ធសាស្ត្រស្រាវជ្រាវពីប្រទេសកម្ពុជាសំរាប់ CDRI ។ យុទ្ធសាស្ត្រនេះត្រូវមានលក្ខណៈឯករាជ្យ និងក្លាយជាមូលដ្ឋានសំរាប់ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ ខាងមុខ ដែល CDRI នឹងស្វែងរកការគាំទ្រផ្នែកធនធាន ដោយមានការសំរបសំរួលគ្នាអំពីបណ្តាដៃគូអភិវឌ្ឍន៍សំខាន់ៗរបស់កម្ពុជា ។

នៅថ្ងៃទី២២-២៣ ខែតុលា នាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមម្តងទៀតក្នុងការប្រជុំប្រចាំឆ្នាំនៃ វេទិកាវិទ្យាស្ថាននៅអាស៊ីខាងកើត ដែលរៀបចំឡើងដោយវិទ្យាស្ថានកូរ៉េ សំរាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP) នៅទីក្រុងសេអ៊ូល កូរ៉េខាងត្បូង ។ វេទិកាឆ្នាំនេះមានប្រធានបទថា "សមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីខាងកើត : បញ្ហាបច្ចុប្បន្ន និង ទិសដៅខាងគោលនយោបាយ" និងបានប្រមូលផ្តុំថ្នាក់ដឹកនាំពីបណ្តាវិទ្យាស្ថានឈានមុខខាងស្រាវជ្រាវ និងសិក្សាពីគោលនយោបាយ នៅក្នុងបណ្តាប្រទេសអាស៊ាន ចិន កូរ៉េ និងជប៉ុន ។ វេទិកាឆ្នាំនេះផ្តោតលើពាណិជ្ជកម្ម វិនិយោគ សហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងផលប៉ះពាល់លើអាស៊ីខាងកើតនៃ វិបត្តិហិរញ្ញវត្ថុសកល ។ វេទិកានេះតែងផ្តល់ឱកាសដ៏វិសេសសំរាប់ការកសាងបណ្តាញថ្នាក់ខ្ពស់ និងដាក់បញ្ចូលការងាររបស់ CDRI ទៅក្នុងបរិបទធំទូលាយនៃការងារអភិវឌ្ឍន៍នៅតំបន់អាស៊ីខាងកើត ។

នៅចុងឆ្នាំ២០០៨ វិទ្យាស្ថាន CDRI នឹងចូលរួមក្នុងការវាយតម្លៃពីកម្មវិធីនៅប្រទេសកម្ពុជា របស់អង្គការ DFID ដើម្បីប៉ាន់ប្រមាណពីប្រសិទ្ធភាព និងកែលំអជំនួយអភិវឌ្ឍន៍ទៅអនាគតទៀត ។ វិទ្យាស្ថាន CDRI នឹងចូលរួមផងដែរក្នុងការប្រជុំបូកសរុបលទ្ធផលពាក់កណ្តាលអាណត្តិរបស់ Sida-DFID លើជំនួយថវិកាស្នូលសំរាប់ចំណាយប្រតិបត្តិការរបស់ CDRI (ដូចជា ការកសាងសមត្ថភាពបុគ្គលិក) និងជំនួយសំរាប់កម្មវិធីកំណែទម្រង់វិស័យសាធារណៈនិងអភិបាលកិច្ចបែបប្រជាធិបតេយ្យ ។ នៅខែវិច្ឆិកា ២០០៨ ក្រុមហ៊ុនគណនេយ្យ Price Waterhouse-Coopers នឹងចាប់ផ្តើមធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំជាបណ្តោះអាសន្ន ហើយនឹងចេញរបាយការណ៍សំរេច នៅខែកុម្ភៈ ២០០៩ សំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាលនៃ CDRI ពិនិត្យនៅពេលប្រជុំពេញអង្គប្រចាំឆ្នាំ នាថ្ងៃទី២៧ កុម្ភៈ ២០០៩ ។

បច្ចុប្បន្ននេះ ផែនការផ្សេងៗកំពុងលូតលាស់ទៅមុខសំរាប់សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ដែលជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារ ANZ Royal ហើយគ្រោងធ្វើនៅក្រុងភ្នំពេញ នៅថ្ងៃទី២៦ ខែកុម្ភៈ ២០០៩ លើប្រធានបទ "**ការអភិវឌ្ឍវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ វិស័យឯកជន និងធនធានមនុស្ស**" ។ វិទ្យាស្ថាន CDRI បានសូមអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ ។ ព្រមពេលគ្នាជាមួយសន្និសីទចក្ខុវិស័យ វិទ្យាស្ថាន CDRI នឹងចេញផ្សាយ របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ សំរាប់ឆ្នាំ២០០៨-០៩ ។

(តទៅទំព័រ ២៣)

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១២ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៨

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh

website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ

កែសំរួលផលិតកម្ម: គីម ចិត្រា និង អ៊ុំ ចាន់ថា

ជំនួយការកែសំរួល: ទូច ដារិទ្ធរង្សី

រោងពុម្ពដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ឱ្យដោយឥតគិតថ្លៃតាមរយៈវេបសាយ: http://www.cdri.org.kh